MARUHAN
JAPAN BANK

# របាយការណ៍ប្រចាំឆ្នាំ ២០១៥






# មាតិកា


| | |
|---|---|
| ជីវប្រវត្តិធនាគារ | ១ |
| ក្រមសីលធម៌ និងភាពសុចរិតរបស់ ម៉ារ៉ូហាន់ | ២ |
| សារពីប្រធានក្រុមប្រឹក្សាភិបាល | ៣ |
| ជោគជ័យ និងមហិច្ឆិតា ក្នុងឆ្នាំទី៦ | ៤ |
| រចនាសម្ព័ន្ធរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន | ៥ |
| ណែនាំអំពីក្រុមការងាររបស់យើងខ្ញុំ សមាជិកក្រុមប្រឹក្សាភិបាល | ៦ |
| សេចក្តីសង្ខេបពីស្ថានភាពហិរញ្ញវត្ថុ លទ្ធផលរបស់យើងខ្ញុំ | ៧ |
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ៨ - ១០ |
| របាយការណ៍របស់សវនករឯករាជ្យ | ១១ |
| តារាងតុល្យការរួម | ១២ |
| របាយការណ៍លទ្ធផលរួម | ១៣ |
| របាយការណ៍បម្រែបម្រួលមូលធនរួម | ១៤ |
| របាយការណ៍លំហូរសាច់ប្រាក់រួម | ១៥ |
| តារាងតុល្យការដាច់ដោយឡែក | ១៦ |
| របាយការណ៍លទ្ធផលដាច់ដោយឡែក | ១៧ |
| របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក | ១៨ |
| របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក | ១៩ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ២០ - ៧៤ |
| ទំនួលខុសត្រូវសង្គមរបស់ធនាគារ | ៧៥ |
| បណ្តាញប្រតិបត្តិការ អេធីអឹម | ៧៦ |

ម៉ារូហាន់ ធនាគារជប៉ុន

# ជីវប្រវត្តិធនាគារ

ម៉ារូហាន់ ធនាគារជប៉ុន បានបើកសម្ភោធនៅឆ្នាំ២០០៨ជាធនាគារពាណិជ្ជជប៉ុនដំបូងគេបង្អស់ក្នុងប្រទេសកម្ពុជាដែលមានអាជ្ញាប័ណ្ណពេញលេញ។

យើងត្រូវបានបង្កើតឡើងដើម្បីគាំទ្រដល់ចំណងមិត្តភាពដែលមានរវាង ប្រទេសជប៉ុននិងកម្ពុជា ដើម្បីចូលរួមចំណែកដល់ការរីកចំរើន និងការអភិវឌ្ឍន៍ប្រទេសកម្ពុជា និងដើម្បីលើកតម្កើនស្តង់ដារសេវាអតិថិជនក្នុងវិស័យធនាគារ ដែលនេះជាអ្វីដែលយើងមានហើយនឹងបន្តធ្វើ ជាបន្តទៀត។

ទោះបីជាយើងជាធនាគារពាណិជ្ជជប៉ុន តែយើងមានឫសគល់នៅប្រទេសកម្ពុជា។ យើងជាធនាគារ កម្ពុជា ហើយយើងប្រើប្រាស់នូវជំនាញ និងស្តង់ដារខ្ពស់បែប ជប៉ុន ដើម្បីផ្តល់នូវផលិតផលនិងសេវាកម្មស្តង់ដារអន្តរជាតិជូនប្រជាជនកម្ពុជានិងអ្នកគ្រប់គ្នាដែលរស់នៅនិងប្រកបអាជីវកម្មក្នុងប្រទេសកម្ពុជា ដែលអាច អោយពួកគេបំពេញនូវសក្តានុពលផ្ទាល់ខ្លួន និងប្រទេសរបស់ពួកគេ។









## បេសកម្មរបស់យើងខ្ញុំ

១. ជាដៃគូរពាណិជ្ជកម្ម និងហិរញ្ញវត្ថុដែលឈានមុខគេនិងមានការទទួលស្គាល់សំរាប់អតិថិជនប្រកបរបរអាជីវកម្ម និងមិនប្រកបរបរអាជីវកម្ម ដោយផ្តល់ជូននូវផលិតផលសេវាកម្ម និងដំណោះ ស្រាយហិរញ្ញវត្ថុដែលមានគុណភាពខ្ពស់មានភាពងាយស្រួល និងឮតម្រូវទៅតាមអតិថិជន។

២. ដើម្បីក្លាយជាសាជីវកម្មគំរូ។

៣. ដើម្បីបំពេញតម្រូវការអតិបរមាជូនភាគីពាក់ព័ន្ធទាំងអស់។

## ចក្ខុវិស័យរបស់យើងខ្ញុំ

យើងខ្ញុំប្រើប្រាស់ កម្លាំងកាយ កម្លាំងចិត្ត ប្រសិទ្ធភាព ជំនាញ សេចក្តីសារទេរ និងការប្តេជ្ញា ដើម្បីបង្កើតផ្គត់ផ្គង់យ៉ាងទូលំទូលាយនូវសេវាកម្មថ្មី ប្រកបដោយវិជ្ជាជីវៈតម្លៃសមរម្យនិងងាយស្រួលប្រើប្រាស់។ យើងខ្ញុំនឹងប្រើជំនាញរបស់យើងខ្ញុំនៅក្នុង "ទំនាក់ទំនងធនាគារ" ដើម្បីផ្តល់នូវស្តង់ដារដែលគ្មានគូរប្រដូច ចំពោះសេវាអតិថិជន ការប្រតិបត្តិផលិតផល ជំរើសសន្តិសុខ ការគ្រប់គ្រងនិងលក្ខណ:សកល ហើយយើងខ្ញុំនឹងផ្តល់នូវអ្វីទាំងអស់នេះតាមបែបស្វាគមន៍យ៉ាងកក់ក្តៅរបស់ ជប៉ុន ដែលល្បីល្បាញ ពេញពិភពលោក។

## ការសន្យារបស់យើងខ្ញុំ

យើងខ្ញុំបានរៀបចំឡើងដើម្បីគាំទ្រនូវចំណងមិត្តភាពដែលមានស្រាប់រវាងប្រទេស ជប៉ុន នឹងប្រទេសកម្ពុជា ហើយចូលរួមចំណែកដល់ការរីកចំរើន នឹងការអភិវឌ្ឍន៍ ក្នុងប្រទេស កម្ពុជានិងតំបន់ទាំងមូលហើយទាំងនេះជាអ្វីដែលយើងត្រូវធ្វើយ៉ាងពិតប្រាកដ!

# ក្រមសីលធម៌ និងភាពសុច្ចរិត

# ម៉ារ៉ូហាន់និយម

កេរ្តិ៍ឈ្មោះរបស់យើងអាស្រ័យលើភាពសុច្ចរិតព្រមទាំង ប្រសិទ្ធិភាព និងគុណភាពនៃសេវាកម្មរបស់យើងខ្ញុំ។ យើងខ្ញុំត្រូវការធានាដាច់ខាតនៃការស្មោះត្រង់ និងភាពសុច្ចរិតរបស់បុគ្គលិកយើងទាំងអស់។ ទាំងនៅកន្លែងធ្វើការ និងនៅក្នុង សង្គម ភាពស្មោះត្រង់ជាកត្តាចាំបាច់បំផុតព្រោះកិត្តិយសដែលពិបាកនឹងកសាងរបស់យើងខ្ញុំអាចត្រូវបានបំផ្លាញដោយជនណាម្នាក់ ប្រសិនបើមិនបានប្រព្រឹត្តិតាមគោលការណ៍និងស្តង់ដារអាកប្បកិរិយាខ្ពស់បំផុតនោះទេ។ យើងខ្ញុំ មានមោទនភាពក្នុងការកំណត់នូវស្តង់ដារថ្មីនេះសម្រាប់អាជីវកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំបានបង្កើតនូវ "ឧបករណ៍" និងទម្រង់ការក្រមសីលធម៌ ជាច្រើនដូចជា ក្រមសីលធម៌របស់និយោជិតដើម្បីជួយយើងខ្ញុំបំពេញនូវបេសកកម្មរបស់យើងខ្ញុំ។

## ក្រមសីលធម៌

គោលការណ៍ដែលមាននៅក្នុងក្រមសីលធម៌នេះជាផ្លូវសម្រាប់បង្ហាញដល់អាកប្បកិរិយារបស់យើងខ្ញុំនិងជាការណែនាំដល់របៀបដែលយើងខ្ញុំធ្វើការទោះជា ម៉ារ៉ូហាន់ ធនាគារជប៉ុន ប្រតិបត្តិការនៅទីណាក៏ដោយ។

## ភាពស្មោះត្រង់ និងសុច្ចរិតភាព

និយោជិករបស់យើងខ្ញុំ នឹងមិនធ្វើការអត្ថាធិប្បាយការសន្យា ឬការប្តេជ្ញាណាដែលពួកគាត់ជឿថាមិនត្រឹមត្រូវ ឬអ្វីដែលពួកគាត់ ឬ ម៉ារ៉ូហាន់ធនាគារជប៉ុនពុំមានបំណង ឬមិនអាចអោយ តម្លៃបាននោះទេ។ ពួកគាត់នឹងធ្វើអ្វីៗដោយភាពស្មោះត្រង់ និងសុច្ចរិត ហើយស្របជាមួយនឹងតម្លៃរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន។ ពួកគាត់នឹងមិន និយាយឃ្លាដែលមិនពិតដោយចេតនា ឬធ្វើអោយនរណាម្នាក់យល់ច្រឡំ ឬដោយលុបបំបាត់ឡើយ។ រាល់ពេលពួកគាត់នឹងទាក់ទងដោយយុត្តិធម៌ ស្មើភាព និងសុទ្ធចិត្ត ជាមួយអតថិជនអ្នកផ្គត់ផ្គង់ ដៃគូប្រគួតប្រជែង និងអ្នក កាន់ច្បាប់ ព្រមទាំងសហាសេវិកនិងភាគីដទៃទៀត។ ពួកគាត់នឹងរាប់អានមនុស្សទាំងអស់ប្រកបដោយការគោរពហើយនឹងប្រកាន់តួនាទីរបស់ពួកគាត់ដោយការយកចិត្តទុកដាក់ជាទីបំផុត។ ពួកគាត់នឹងការពារផលប្រយោជន៍កេរ្តិ៍ឈ្មោះ និងទ្រព្យសម្បត្តិរបស់ម៉ារ៉ូហាន់ ធនាគារជប៉ុន។

## ការជួញដូរ និងផលប្រយោជន៍របស់ខ្លួន

ទំនាក់ទំនងផ្ទាល់ខ្លួនរបស់និយោជិតយើងខ្ញុំនឹងត្រូវទុកដោយឡែកពីទំនាក់ទំនងរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន។ ពួកគាត់នឹងមិនប្រើប្រាស់ ឈ្មោះរបស់ម៉ារ៉ូហាន់ ធនាគារជប៉ុន ឬក៏ព័ត៌មានដែលបានមកនៅពេលធ្វើការអោយម៉ារ៉ូហាន់ ធនាគារជប៉ុន ឬក៏បានពីមុខតំណែងរបស់ពួកគាត់ដើម្បីបន្ថែមការជួញដូរ ឬ ផលប្រយោជន៍ផ្ទាល់ខ្លួន ឬក៏ដើម្បីទទួលបានផលចំណេញណា (ជាហិរញ្ញវត្ថុ ឬ បែបណាក្តី) សម្រាប់បុគ្គល អង្គការ ឬ ក្រុមហ៊ុនដទៃឡើយ។ ពួកគាត់នឹង មិនធ្វើការជួញដូរ ឬ សើបសួរព័ត៌មានអ្វីដោយប្រើឈ្មោះពួកគាត់ហើយមិនស្វះស្វែង ធ្វើជំនួញសកម្ម តែជាមនុស្ស ដែលពួកគាត់ស្គាល់។ ពួកគាត់នឹងផ្តល់សេវាកម្មដល់ពួកគេដូចដែលពួកគាត់ផ្តល់ដល់អ្នកដែលពួកគាត់មិនស្គាល់ដែរ។

ពួកគាត់នឹងប្រើប្រាស់ផលិតផល សេវាកម្ម និងគ្រឿងសម្ភារៈដែលផ្តល់អោយដោយម៉ារ៉ូហាន់ ធនាគារជប៉ុន តាមការណែនាំ អោយបានខ្ជាប់ខ្ជួន ហើយធ្វើយ៉ាងណាអោយរបស់ទាំងនោះត្រូវបានការពារយ៉ាងត្រឹមត្រូវ។

## ភាពសម្ងាត់នៃព័ត៌មាន

ពួកគាត់នឹងរក្សាការសម្ងាត់របស់អ្នកដទៃ។ ពួកគាត់នឹងធ្វើយ៉ាងណាអោយព័ត៌មានសម្ងាត់ត្រូវបានការពារយ៉ាងខ្ជាប់ខ្ជួនដោយមិនអោយរបូតទៅជនទីបីឡើយ លើកលែងតែការងាររបស់ពួកគាត់តម្រូវអោយធ្វើដូច្នោះក្រោមច្បាប់ទាក់ទិនឬក៏មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីនិយោជិកមានសមត្ថកិច្ចរបស់ ម៉ារ៉ូហាន់ ធានាគារជប៉ុន។

## ជម្លោះផលប្រយោជន៍

និយោជិតរបស់យើងខ្ញុំយល់ច្បាស់ថាភក្តីភាពក្នុងជំនួញចម្បងរបស់ពួកគាត់គឺមានចំពោះ ម៉ារ៉ូហាន់ ធនាគារជប៉ុន ភី.អិល.ស៊ី ហើយពួកគាត់នឹងរាយការណ៍គ្រប់ជ្រុងជ្រោយនិងលឿនបំផុតអំពីបញ្ហាផ្ទាល់ខ្លួនដែលអាចឈានទៅដល់ជម្លោះផលប្រយោជន៍។ ទំនាក់ទំនងរបស់ពួកគាត់ជាមួយអតិថិជន អ្នកផ្គត់ផ្គង់និងភាគីដទៃទៀត នឹងនៅតែមានតម្លាភាពនិងបើកចំហដើម្បី ជៀសវាងជម្លោះផលប្រយោជន៍ដែលអាចកើតមាន។

## ការគោរពតាមច្បាប់

និយោជិករបស់យើងខ្ញុំនឹងគោរពតាមច្បាប់ និងក្រមសីលធម៌នេះ។ ពួកគាត់នឹងមិនធ្វើសកម្មភាព ឬ បណ្តោយអោយមានការលុបបំបាត់ណាមួយដែលល្មើសច្បាប់ ឬ បទបញ្ញានោះទេ។ ពួកគាត់នឹងរាយការណ៍អំពីការល្មើសនានាលើក្រមនេះ ឬច្បាប់ ឬបទបញ្ញាដើម្បីអោយមានការចាត់វិធានការសមស្របណាមួយ។ ពួកគាត់ដឹងថា ប្រសិនបើពួកគាត់ល្មើសច្បាប់ ឬបទបញ្ញាឬក្រមណាមួយករណីល្មើសនោះនឹងត្រូវគេស៊ើបអង្កេតហើយឈានទៅដល់ករណីពិន័យ។

## ការបង់ប្រាក់ អំណោយ ឬ ការកំសាន្ត

និយោជិករបស់យើងខ្ញុំនឹងមិនទទួល ឬ ផ្តល់ការឧបត្ថម្ភ អំណោយឬការកំសាន្តនានាដែលមានលក្ខណៈជាអំណោយការកំសាន្តឬបដិសណ្ឋារកិច្ចពីក្រុមហ៊ុន អង្គការ ឬជនណាម្នាក់ដែល កាលពីអតីត នាបច្ចុប្បន្ន ឬនាពេលអនាគត នឹងមានធ្វើជំនួញឬទំនាក់ទំនងការងារជាមួយ ម៉ារ៉ូហាន់ ធនាគារជប៉ុន។ ពួកគាត់នឹងមិនផ្តល់ការសន្យា ឬទទួលសំណូកក្នុងរូបភាពណាក្តីពីជនណាឡើយទោះដោយផ្ទាល់ ឬដោយប្រយោលក្តី។

## សារពី៖

# ប្រធានក្រុមប្រឹក្សាភិបាល



បណ្ឌិត ហាន់ ចាងវូ
ប្រធានក្រុមប្រឹក្សាភិបាល
និងនាយកប្រតិបត្តិ សម្ព័ន្ធ ម៉ារ៉ូហាន់

ភាគីពាក់ព័ន្ធផ្សេងៗជាទីរាប់អាន ៖

ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី ជាធនាគារជប៉ុន ដំបូងបង្អស់នៅកម្ពុជា ដែលបានចាប់ផ្ដើមបង្កើត និងដំណើរការ នៅក្នុងឆ្នាំ២០០៨ យើងបានចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមរយៈការផ្ដល់នូវសេវាធនាគារដ៏សំបូរបែបក៏ដូចជាការទាក់ទាញការវិនិយោគអោយចូលមកក្នុងប្រទេសកម្ពុជា។

នៅខែ ធ្នូឆ្នាំ២០១២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត បានក្លាយជាសមាជិកមួយនៃសាជីវកម្ម ម៉ារ៉ូហាន់ តាមរយៈការទទួលយក ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី ជាភាគទុនិកសក្ដានុពលសំខាន់របស់ខ្លួន។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត កំពុងនិងបន្តការចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសកម្ពុជាតាមរយៈការពង្រីក តំបន់ប្រតិបត្តិការរបស់ខ្លួនគ្របដណ្ដប់ទូទាំងប្រទេសដែលបច្ចុប្បន្នមានចំនួន ១៤០ ការិយាល័យប្រតិបត្តិការ។

ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី មានគោលបំណងបង្កើតប្រតិបត្តិការរបស់ខ្លួនទូទាំងប្រទេស ដោយបច្ចុប្បន្ននេះយើងកំពុងផ្ដល់សេវាហិរញ្ញវត្ថុជាលក្ខណៈខ្នាតធំដល់អតិថិជនរបស់ខ្លួន។ ចំណែកឯគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត វិញបាននឹងកំពុងផ្ដល់សេវាហិរញ្ញវត្ថុរបស់ខ្លួនជាលក្ខណៈខ្នាតតូច ហើយមានមហិច្ឆតាចង់ក្លាយខ្លួនជាធនាគារពាណិជ្ជ។ ស្ថាប័នទាំងពីរមានគោលបំណងប្រហាក់ប្រហែលគ្នាជាច្រើននិងយល់ឃើញថាអាចសហការណ៍ជាផ្លូវមួយបានហេតុដូចនេះ ហើយយើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាការរួមបញ្ចូលគ្នារវាង ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត ( ដោយប្រើចំណុចខ្លាំង រៀងៗខ្លួន ) នឹងធ្វើអោយយើងក្លាយជាធនាគារដ៏ខ្លាំងមួយនៃប្រទេសកម្ពុជា។

ពេលដែលសំលឹងមើលប្រជាជនកម្ពុជា ធ្វើអោយខ្ញុំនឹកឃើញដល់អតីតកាលរបស់ខ្លួនដែលកើតនៅក្នុងត្រកូលកសិករ រកមួយថ្ងៃស៊ីមួយថ្ងៃមានជីវភាពលំបាកលំបិនខ្លាំងណាស់។ កាលពី៥៧ឆ្នាំមុនខ្ញុំបានបង្កើតអាជីវកម្មខ្នាតតូចមួយ ដោយប្រើប្រាស់ប្រាក់ក្នុងដៃបន្តិចបន្តួចនៅស្រុកដាច់ស្រយាលមួយនៃភាគខាងជើងទីក្រុង ក្យូតូ (KYOTO) ហើយអាជីវកម្មតូចនេះបច្ចុប្បន្នបានក្លាយជាសាជីវកម្មកំសាន្តដ៏ធំមួយដែលមានបុគ្គលិកលើសពី ១៥,០០០នាក់ និងមណ្ឌលកំសាន្ត ៣០០ កន្លែង សម្រាប់ផ្ដល់សេវាកម្មទូទាំងប្រទេស ក៏ដូចជាក្លឹបវាយកូនហ្គោលលំដាប់ ថ្នាក់ទីមួយ (FIRST-CLASS) ចំនួន ១៧ កន្លែងផងដែរ។ មុននឹងក្លាយខ្លួនមកដល់បច្ចុប្បន្ន សាជីវកម្មយើងបានឆ្លងកាត់ភាពលំបាកផ្សេងៗជាច្រើន។ ខ្ញុំគិតថាការដែលក្លាយខ្លួនដូចសព្វថ្ងៃនេះដោយសារតែស្មារតីស្រែកឃ្លានពុះពារប្រឈមមុខរាល់បញ្ហា និងឆន្ទៈមិនបោះបង់មិនរាថយដាច់ខាត។ មិនមែនមានតែ ប្រទេសជប៉ុនទេប្រទេសជឿនលឿនលើពិភពលោកក៏សុទ្ធតែចាប់ផ្ដើមពីភាពក្រីក្រ។ ខ្ញុំមានជំនឿដ៏មុតមាំថាថ្ងៃអនាគតកម្ពុជានឹងក្លាយជាប្រទេសជឿនលឿនដូចប្រទេសជប៉ុនដែរ។

ពួកយើងបានបង្កើតធនាគារនេះឡើងក៏ដោយសារតែពួកយើងចង់គាំទ្រជួយជ្រោមជ្រែងដល់ប្រជាពលរដ្ឋកម្ពុជាដែលប្រឹងប្រែងចូលរួមអភិវឌ្ឍន៍លើកស្ទួយប្រទេសដោយឆន្ទៈ ស្មារតីស្រែកឃ្លាន និង ពុះពារ។ ខ្ញុំមានកិត្តិយសនិងត្រេកអរក្រៃលែងដែលធនាគារថ្មីគឺ ធនាគារ ស្ថាបនា ភីអិលស៊ីអាចចូលរួមចំណែកដោះស្រាយបញ្ហាហិរញ្ញវត្ថុ និងបញ្ហាសង្គមនានាក្នុងកម្ពុជា។



បណ្ឌិត ហាន់ ចាងវូ
韓 昌祐
ប្រធានក្រុមប្រឹក្សាភិបាល
និងនាយកប្រតិបត្តិសម្ព័ន្ធ ម៉ារ៉ូហាន់

# ជោគជ័យ និងមហិច្ឆិតាក្នុងឆ្នាំទី៧



យើងខ្ញុំមានភាពរីករាយណាស់ដែលការបំពេញមុខងារក្នុងឆ្នាំ២០១៥នេះសមស្របទៅនឹងក្តីរំពឹង និង យុទ្ធសាស្ត្រអាជីវកម្មរបស់យើងខ្ញុំ។

ជោគជ័យ សំខាន់ៗរបស់យើងខ្ញុំមមាន៖

- ចាប់ផ្តើមដំណើរការដោយជោគជ័យនូវសេវាកម្ម អ៊ីនធឺណែតប៊ែងឃីង
- ចាប់ផ្តើមដំណើរការដោយជោគជ័យនូវសេវាកម្ម ហិរញ្ញប្បទានពាណិជ្ជកម្ម
- ចាប់ផ្តើមដំណើរការដោយជោគជ័យនូវការសហការសេវាផ្ទេរប្រាក់មិនគិតថ្លៃពីគ្រប់សាខារបស់ ស្ថាបនា លីមីតធីត
- ចាប់ផ្តើមដំណើរការដោយជោគជ័យនូវសេវាកម្ម ឥណទានបំរុងសំរាប់ម្ចាស់គណនីប្រាក់បញ្ញើមានកាលកំណត់
- ចាប់ផ្តើមដំណើរការដោយជោគជ័យក្នុងការពង្រីកបន្ថែមទៀតនូវ សេវាកម្ម អេធីអឹម ចំនួន ១០ទីតាំង

ទោះជាមានជោគជ័យគួរអោយកត់សម្គាល់ក្នុងឆ្នាំ២០១៥ ក៏ដោយក៏យើងខ្ញុំនៅមានការងារជាច្រើន ដែលត្រូវបំពេញដើម្បីឈានទៅរកគោលដៅក្នុងការកំណត់ស្តង់ដាថ្មីសម្រាប់វិស័យធនាគារ។ ក្នុងឆ្នាំ២០១៦យើងខ្ញុំនឹងផ្តោតទៅលើ៖

- ផ្តោតសំខាន់ទៅលើការរួមបញ្ចូលគ្នារវាង ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី នឹង មីក្រូហិរញ្ញវត្ថុ ស្ថាបនា លីមីតធីត អោយទៅជាធនាគារថ្មីមួយ ដែលមានឈ្មោះថា ធនាគារ ស្ថាបនា ភីអិលស៊ី ។
- អនុវត្តនូវសម្ព័ន្ធសេវាផ្ទេរប្រាក់ជាមួយ ស្ថាបនា លីមីតធីត ដៃគូមីក្រូហិរញ្ញវត្ថុរបស់យើងខ្ញុំដែលនឹងអាចអោយយើងខ្ញុំផ្តល់សេវាដល់អតិថិជនទូទាំងប្រទេសដោយប្រើប្រាស់នូវប្រព័ន្ធ និងហេដ្ឋារចនាសម្ព័ន្ធរបស់ ស្ថាបនា ដែលមានស្រាប់។
- បន្តវិនិយោគ និងពង្រីកហេដ្ឋារចនាសម្ព័ន្ធអាជីវកម្មរបស់យើងខ្ញុំ ដែលរួមបញ្ចូលទាំងក្នុងស្រុក ក្នុងតំបន់ និងបណ្តាញសកល។
- យុទ្ធសាស្ត្រដែលនឹងអនុញ្ញាតិអោយយើងអភិវឌ្ឍអាជីវកម្មមានស្រាប់និងបណ្តាញថ្មី រវាងប្រទេសជប៉ុន និងប្រទេសកម្ពុជា។



# ប្តេជ្ញាដើម្បីក្លាយជាអ្នកផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អបំផុតរបស់កម្ពុជា

ដោយផ្អែកលើទស្សន:ដែលធនាគារជាឧស្សាហាកម្មសេវាកម្ម យុទ្ធសាស្ត្ររបស់យើងខ្ញុំគឺផ្តល់ជូនអតិថិជននូវសេវាហិរញ្ញវត្ថុប្រកបដោយគុណភាពដែលយើងខ្ញុំខ្លួនឯងចង់ទទួលបាន។ យើងខ្ញុំចាត់ទុកខ្លួនឯងជាអ្នកជំនាញផ្នែក “ទំនាក់ទំនងធនាគារ“ ហើយសម្រាប់យើងខ្ញុំ អតិថិជនតែងមានអាទិភាព។

ម៉ារ៉ូហាន់ ធនាគារជប៉ុន គឺប្តេជ្ញាក្នុងការក្លាយខ្លួនជាធនាគារជម្រើសសម្រាប់បុគ្គល គ្រឹះស្ថាន និង សាជីវកម្ម ដែលអោយតម្លៃទៅលើស្តង់ដារសេវាកម្មនិងការប្រតិបត្តិគ្មានគូប្រៀប ទាំងប្រទេសនិងក្នុងតំបន់។

យើងខ្ញុំជាធនាគារពាណិជ្ជជប៉ុនតែមួយគត់របស់កម្ពុជា ដូច្នេះហើយយើងខ្ញុំផ្តល់នូវភាពកក់ក្តៅ និងការស្វាគមន៍យ៉ាងកក់ក្តៅ សម្រាប់ប្រជាជនជប៉ុន និងវិនិយោគិនដែលមានចំណាប់អារម្មណ៍ និងធ្វើអាជីវកម្មក្នុងប្រទេសកម្ពុជា ហើយយើងខ្ញុំផ្តល់នូវសេវាកម្ម គុណភាពជប៉ុនដល់អតិថិជនកម្ពុជា។

ក្រុមការងាររបស់យើងខ្ញុំ គឺដឹកនាំដោយអ្នកឯកទេសដែលមានបទពិសោធន៍ផ្នែកធនាគារ ដែលធ្លាប់ទទួលបានជោគជ័យក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុក និងបរទេស។ ក្រុមការងារអន្តរជាតិ និងកម្ពុជារបស់យើងខ្ញុំរួមគ្នាផ្តល់នូវលំដាប់សេវាកម្មស្តង់ដាអន្តរជាតិជាមួយ ភាពរួសរាយយ៉ាងកក់ក្តៅបែបជប៉ុន ដល់បុគ្គលអាជីវករ ឬតំណាងភ្នាក់ងារផ្តល់ជំនួយគ្រប់ទិសទី។

ម៉ារ៉ូហាន់ ធនាគារជប៉ុន

# រចនាសម្ព័ន្ធ



## ណែនាំអំទីក្រុមការងាររបស់យើងខ្ញុំ

# សមាជិកក្រុមប្រឹក្សាភិបាល



**លោកបណ្ឌិត ហាន់ ចាងវូ** ជាអ្នកបង្កើត និងជាប្រធានក្រុមប្រឹក្សាភិបាលនៃសាជីវកម្ម ម៉ារ៉ូហាន់ ដែលមានចំណូលប្រចាំឆ្នាំ ២៥ពាន់លានដុល្លារអាមេរិក ជាក្រុមហ៊ុនដ៏ជោគជ័យមួយរបស់ ជប៉ុន។ គាត់ជាអ្នកអភិរក្សសិល្បៈ និងសកម្មក្នុងការផ្តល់មូលនិធិ និងគាំទ្រនូវ សប្បុរសធម៌ វប្បធម៌ និងសមាគមអប់រំ និងអង្គការជាច្រើន។



**លោក ហាន់ យូ** ជាប្រធាន និងនាយកប្រតិបត្តិ នៃសាជីវកម្ម ម៉ារ៉ូហាន់។ បន្ទាប់ពីទទួលបាន បរិញ្ញាប័ត្រពី សកលវិទ្យាល័យ ហូសី ប្រទេសជប៉ុន គាត់បានចូលរួមជាមួយ ម៉ារ៉ូហាន់ ក្នុងឆ្នាំ១៩៩០ ហើយបានក្លាយជាអនុប្រធានក្នុងឆ្នាំ២០០៦ និងក្លាយជាប្រធានក្នុងឆ្នាំ២០០៨។ គាត់បានដឹកនាំសាជីវកម្មដែលមាននិយោជិក ១៥.០០០នាក់ និងទទួលខុសត្រូវក្នុងការអភិវឌ្ឍន៍ សាជីវកម្ម ម៉ារ៉ូហាន់ ជាសកល។



**លោក ហាន់ ខេន** ចូលរួមជាមួយ សាជីវកម្ម ម៉ារ៉ូហាន់ក្នុងឆ្នាំ២០០០និងត្រូវបានតែងតាំងជា នាយក ក្នុងឆ្នាំ២០០៧។ គាត់ទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុរបស់សម្ព័ន្ធ មានតួនាទីជានាយក នៃ ម៉ារ៉ូហាន់ ធនាគារជប៉ុន ក្នុងប្រទេសកម្ពុជា ឡាវ និងភូមា ហើយនិងជានាយកប្រតិបត្តិនៃ ម៉ារ៉ូហាន់ វិនិយោគអាស៊ី ដែលមានស្នាក់ការកណ្តាលនៅក្នុង សម្ព័ន្ធហិរញ្ញវត្ថុ ម៉ារ៉ូហាន់ អាស៊ាន ក្នុងប្រទេសសិង្ហបុរី។



**យ៉ាបេ យ៉ូស៊ីកាហ៊ីរ៉ូ** ចូលរួមជាមួយ ម៉ារ៉ូហាន់ ធនាគារជប៉ុន ជានាយកនិងអ្នកគ្រប់គ្រងទូទៅ ក្នុងខែមករាឆ្នាំ២០១៤។ គាត់មានប្រវត្តិផ្នែកពាណិជ្ជកម្មវិនិយោគ និងធនាគារឯកជន និងផ្តល់ទុន ហានិភ័យខ្ពស់នៅជប៉ុន ញូយ៉ក ហ្សូរីក និងហុងកុង។ មុនពេលចូលបម្រើការនៅ ធនាគារជប៉ុន គាត់ធ្លាប់ធ្វើការនៅ ធនាគារ សាន់វ៉ា និងធនាគារ តូក្យូ-មីតស៊ុយប៊ីស៊ី UFJ ពីឆ្នាំ១៩៨៧ ដល់ ឆ្នាំ២០១៣។



**លោកឧកញ៉ា បណ្ឌិត ប៊ុន មុនី** ចូលជាសមាជិកក្រុមប្រឹក្សាភិបាល ម៉ារ៉ូហាន់ ធនាគារ ជប៉ុន នៅក្នុងឆ្នាំ២០១៣ ហើយក៏ជានាយកប្រតិបត្តិនៃស្ថាបនាលីមីតធីត។ គាត់ទទួលបរិញ្ញាប័ត្រជាន់ខ្ពស់ ផ្នែករដ្ឋបាលអាជីវកម្ម ពីសកលវិទ្យាល័យ យូតារា ប្រទេសម៉ាឡេស៊ី និង វិញ្ញាប័ត្របណ្ឌិតផ្នែក រដ្ឋបាលអាជីវកម្ម ពីសកលវិទ្យាល័យ ប្រេសតុន សហរដ្ឋអាមេរិក ហើយមានបទពិសោធន៍ ជាង២០ឆ្នាំ ផ្នែកឧស្សាហកម្ម មីក្រូហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។



**ឯកឧត្តម ស៊ីណូហារ៉ា កាត្សុហ៊ីរ៉ូ** ជាអភិបាលឯករាជ្យនៃ ម៉ារ៉ូហាន់ ធនាគារជប៉ុន។ គាត់បាន ចាប់ផ្តើមមុខងារការទូតរបស់គាត់នៅកម្ពុជា ជាមន្ត្រីលេខាធិការ នៅស្ថានទូតជប៉ុន បន្ទាប់មកក៏ក្លាយ ជាមន្ត្រីប្រឹក្សាជាន់ខ្ពស់។ ចុងក្រោយមកគាត់ក៏ក្លាយជាឯកអគ្គរាជទូត ជប៉ុន ប្រចាំ នៅកម្ពុជាពីឆ្នាំ ២០០៧ ដល់ ២០០៩។



**លោក អ៊ីស៊ីម៉ូរ៉ា មីស្សូ** ជាអភិបាលឯករាជ្យ នៃម៉ារ៉ូហាន់ ធនាគារជប៉ុន។ គាត់មានភាពស្ទាត់ ជំនាញខាងផ្នែក អាជីវកម្មហិរញ្ញវត្ថុ ជាមួយនឹងបទពិសោធន៍រយៈពេលជាង ៣០ឆ្នាំ ក្នុងកិច្ចការ គ្រប់គ្រងនិងចាត់ចែងក្នុងវិស័យ ធនាគារ ទូរគមនាគមន៍ ហិរញ្ញប្បទានប្រើប្រាស់ អគ្គិសនី ម្ហូបអាហារ ការបង្កើនទុន ហិរញ្ញប្បទានទ្រព្យម្ចាស់ និងហិរញ្ញប្បទាន សំរាប់បណ្តារប្រទេស ក្នុងតំបន់អាស៊ី ក្នុងតួនាទីជានាយកគ្រប់គ្រងក្រុមហ៊ុន HSBC។

# លទ្ធផលរបស់យើងខ្ញុំ

| នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥ | ដុល្លារអាមេរិក | |
|---|---|---|
| | សម្ព័ន | ធនាគារ |
| ចំណូលដុល | ៥៧, ៦៣០, ៥០១ | ៨,៣២៥,៦២៣ |
| ចំណេញសុទ្ធមុនបង់ពន្ធ | ១២,២៧៥,៤៧៣ | ៨១០,៦១៤ |
| **ចំណុចសំខាន់នៃតារាងតុល្យការ** | | |
| ទ្រព្យសកម្មសរុប | ៥៣០,៦៩៦,១៥៧ | ២០៨,៧៨០,៨៥៩ |
| មូលនិធិម្ចាស់ភាគហ៊ុន | ៨៣,៥៩១,៣៨១ | ៧២,១៩១,៨៣៦ |
| ឥណទាននិងបុរេប្រទាន | ៣៧០,៧២២,៧៨៨ | ៦៩,០២២,១៥៦ |
| ប្រាក់បញ្ញើពីអតិថិជន | ២៦៩,២៥៨,៥២៧ | ១០៤,៦៣៤,៣៦១ |
| **អនុបាតហិរញ្ញវត្ថុ** | | |
| ចំណូលធៀបនឹងទ្រព្យសកម្ម | ១.៨១% | ០.៣៨% |
| អនុបាតចំណាយធៀបនឹងចំណូល | ៦៤.៩០% | ៧៦.០៤% |
| អនុបាតសោធនភាព | ២៣.៧៥% | ៤៩.៩៨% |
| អនុបាតសាច់ប្រាក់ងាយស្រួល | ៦៣.៤៣% | ១២៧.៥៤% |

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលនៃ ម៉ាឡូហាន់ ធនាគារជប៉ុន ភីអិលស៊ី (“ធនាគារ”) បង្ហាញនូវរបាយការណ៍របស់ក្រុមប្រឹក្សា ភិបាល រួមជាមួយរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (រួមគ្នាហៅថា ”ក្រុមហ៊ុនរួម”) និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារ (រួមគ្នាហៅថា “របាយការណ៍ហិរញ្ញវត្ថុ”) នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់។

## ព័ត៌មានអំពីក្រុមហ៊ុនរួម

### ធនាគារ

ធនាគារមានទ្រង់ទ្រាយជាធនាគារពាណិជ្ជ ដែលធ្វើប្រតិបត្តិការអាជីវកម្ម ក្រោមច្បាប់ស្តីពីសហគ្រាស ពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា និងស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជាដោយ គោរពតាមច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា ហើយនិងអនុលោមតាម អាជ្ញាប័ណ្ណធនាគារលេខ ២០ ដែលចេញដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ធនាគារ ជាបុត្រសម្ព័ន្ធគ្រប់គ្រងទាំងស្រុងដោយក្រុមហ៊ុន Mahuran Investment Asia Pte. ដែលជាក្រុមហ៊ុនចុះបញ្ជីនៅប្រទេសសិង្ហបុរី។

ធនាគារ ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការអាជីវកម្មលើរាល់សកម្មភាពធនាគាររួមមាន៖ ចល័តកម្ម និងការទទួលនូវមូលនិធិបញ្ញើសម្រាប់រយៈពេលខ្លី មធ្យម និងវែងពីអង្គភាព និងរូបវន្តបុគ្គលទូទៅ ផ្តល់ប្រាក់កម្ចីរយៈពេលខ្លី មធ្យម និងវែងដល់អង្គភាព និងរូបវន្តបុគ្គលទៅតាមប្រភេទអាជីវកម្ម និងលទ្ធភាពនៃប្រភពធនធានរបស់ធនាគារ ធ្វើប្រតិបត្តិការអាជីវកម្មរូបិយប័ណ្ណបរទេស ផ្តល់សេវាកម្មហិរញ្ញប្បទាន ពាណិជ្ជកម្មអន្តរជាតិ ផ្ទេរប្បហារកម្មលើមូលបត្រពាណិជ្ជកម្ម ផ្តល់សេវាប្រតិបត្តិការរវាងអតិថិជន និង សេវាកម្មធនាគារផ្សេងៗទៀត ដែលបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា តាមរយៈទីស្នាក់ការកណ្តាលរបស់ធនាគារនៅរាជធានីភ្នំពេញ។ ពុំមានការផ្លាស់ប្តូរដែលគួរអោយ កត់សម្គាល់ទៅលើសកម្មភាព ប្រតិបត្តិការសំខាន់ៗ ដែលបានរៀបរាប់ខាង លើឡើយក្នុងអំឡុងឆ្នាំហិរញ្ញវត្ថុនេះ។ ទីស្នាក់ការចុះបញ្ជីរបស់ធនាគារ មានទីតាំងនៅអគារលេខ ៨៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មីទី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

### ក្រុមហ៊ុនបុត្រសម្ព័ន្ធ

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ធនាគារបានចុះកិច្ចសន្យាការទិញលក់ ជាមួយ Stichting Triodos-Doen (“ST”), Nederlandse Financierings-Maatschapij Voor Ontwikkellingslanden N.V. (“NFVO”), DWM Funds S.C.A.-SICAV SIF (“DWM”), Cambodia Community Building (“CCB”) និង SATHAPANA Employee Investment Limited (“SEI”) ដើម្បីទិញភាគហ៊ុនចំនួន៩៥,១% នៃភាគហ៊ុនសរុបរបស់ស្ថាបនា លីមីតធីត (“ក្រុមហ៊ុនបុត្រសម្ព័ន្ធ”)។ ការទិញលក់នេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២។ បន្ថែមពីនេះ ភាគហ៊ុនទិញលក់ខាងលើត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មក្នុងការ ផ្លាស់ប្តូរកម្មសិទ្ធិភាគហ៊ុននៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។
សកម្មភាពចម្បងសំខាន់ៗរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទៅសហគ្រិនក្រីក្រ ជាពិសេសស្ត្រីនៅតាមតំបន់ជនបទនិងទីប្រជុំជនក្នុងប្រទេសកម្ពុជាតាមរយៈការិយាល័យកណ្តាលរបស់ខ្លួននៅទីក្រុងភ្នំពេញ និងការិយាល័យនៅតាមបណ្តាខេត្ត និងស្រុកនានាក្នុងព្រះរាជាណាចក្រកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុអចិន្ត្រៃយ៍ដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលមានសុពលភាព ចាប់ពីថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ក្រុមហ៊ុនបុត្រសម្ព័ន្ធទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ក្នុងការ ផ្តល់សេវាទទួលប្រាក់បញ្ញើ។
នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ក្រុមហ៊ុនបុត្រសម្ព័ន្ធទទួលបានអាជ្ញាប័ណ្ណ ៣ឆ្នាំ ផ្សេងទៀតក្នុងការផ្តល់សេវាប្តូរប្រាក់។

លទ្ធផលអាជីវកម្ម និងភាគលាភ
លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | ធនាគារ | |
|---|---|---|---|---|
| | ២០១៥ | ២០១៤ | ២០១៥ | ២០១៤ |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ចំណេញមុនបង់ពន្ធ | ២៣.២៦៨.៨៨៩ | ១២.២៧៥.៤៧៣ | ២.១៦១.៧៥៨ | ៨១០.៦១៤ |
| ពន្ធលើប្រាក់ចំណេញ | (៤.៩០៦.៤៣៦) | (២.៦៧៨.២៤៨) | (១៨៣.៣០២) | (២៥.៤៧៨) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | ១៨.៣៦២.៤៥៣ | ៩.៥៩៧.២២៥ | ១.៩៧៨.៤៥៦ | ៧៨៥.១៣៦ |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ - ពាន់រៀល** | ៧៤.៣៦៧.៩៣៦ | ៣៩.១០៨.៦៩៣ | ៨.០១២.៧៤៨ | ៣.១៩៩.៤២៩ |
| ត្រូវបែងចែកដូចខាងក្រោម៖ | | | | |
| មូលធនម្ចាស់ភាគហ៊ុនធនាគារ | ១៧.៤៣៤.៣៦១ | ៩.០៧៩.៣០៥ | ១.៩៧៨.៤៥៦ | ៧៨៥.១៣៦ |
| ម្ចាស់ភាគហ៊ុនអប្បភាគ | ៩២៨.០៩២ | ៥១៧.៩២០ | - | - |
| | ១៨.៣៦២.៤៥៣ | ៩.៥៩៧.២២៥ | ១.៩៧៨.៤៥៦ | ៧៨៥.១៣៦ |

ពុំមានការប្រកាស ឬបែងចែកភាគលាភដោយធនាគារក្នុងការិយបរិច្ឆេទនេះទេ។

## ដើមទុន
ដើមទុនរបស់ធនាគារនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានចំនួន ១០៤ លានដុល្លារអាមេរិក (ឆ្នាំ២០១៤ ៖ ៧៤ លានដុល្លារអាមេរិក)។

## ទុនបម្រុងនិង សំវិធានធន
គណនីទុនបម្រុង និងសំវិធានធនសម្រាប់ការិយបរិច្ឆេទនេះពុំមានការផ្លាស់ប្តូរជាសារវន្តទេក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## ឥណទាន និងបុរេប្រទានជាប់សង្ស័យ និងពិបាកទារ
នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា ក្រុមប្រឹក្សាភិបាលបានចាត់វិធានការទាក់ទង ទៅនឹងការលុបចោលឥណទាន និងបុរេប្រទានដែលទារមិនបាន និងការធ្វើសំវិធានធនសម្រាប់ការខាតបង់ចំពោះឥណទាននិងបុរេប្រទាន និងមានការជឿជាក់ថារាល់បំណុលនិងបុរេប្រទានដែលបានដឹងថាមិនអាចទារបានត្រូវបានលុបចោល ហើយសំវិធានធនគ្រប់គ្រាន់ត្រូវបានកំណត់សម្រាប់ឥណទាន និងបុរេ ប្រទានដែលជាប់សង្ស័យ និងពិបាកទារ។

មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹង បណ្តាលអោយចំនួនទឹកប្រាក់ដែលលុបចោលចំពោះឥណទាន និងបុរេប្រទានទារមិនបាន ឬចំនួនទឹកប្រាក់ សំវិធានធនចំពោះឥណទាន និងបុរេប្រទានជាប់សង្ស័យ និងពិបាកទារនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនរួម និងធនាគារមិនគ្រប់គ្រាន់រហូតដល់កម្រិតសារវន្តណាមួយនោះទេ។

## ទ្រព្យសកម្មចរន្ត
នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារត្រូវបានរៀបចំឡើងក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យ ដើម្បីបញ្ជាក់ថា ទ្រព្យសកម្មចរន្ត ដែលមិនអាចលក់បាននៅក្នុង ប្រតិបត្តិការអាជីវកម្មធម្មតា អោយបានស្មើនឹងតម្លៃកត់ត្រានៅក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុនរួមនិង ធនាគារ ត្រូវបានកាត់បន្ថយអោយនៅស្មើនឹងតម្លៃដែលគិតថានឹងអាចលក់បានលើទីផ្សារ។

មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែល នឹងធ្វើអោយប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មចរន្ត នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ ថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របណាមួយនោះទេ។

## វិធីសាស្ត្រនៃការវាយតម្លៃ
មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែល បានកើតឡើងដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តវិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃ ទ្រព្យ សកម្ម និងទ្រព្យអកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានភាពមិនត្រឹមត្រូវ ឬ មិនសមស្របណាមួយនោះទេ។

## ទ្រព្យអកម្មយថាភាព និងទ្រព្យអកម្មផ្សេងៗ
មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ

- ពុំមានការដាក់បញ្ចាំទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុនរួម និងធនាគារ ដែលកើតមានឡើងនៅជំណាច់ការិយបរិច្ឆេទសម្រាប់ធានាចំពោះបំណុលរបស់បុគ្គលណាមួយ និង
- ពុំមានទ្រព្យអកម្មយថាភាពណាមួយកើតមានឡើងចំពោះក្រុមហ៊ុនរួម និងធនាគារចាប់តាំងពីជំណាច់ ការិយបរិច្ឆេទក្រៅពីប្រតិបត្តិការធម្មតារបស់អាជីវកម្ម។

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល គឺពុំមានទ្រព្យអកម្មយថាភាព ឬទ្រព្យអកម្មផ្សេងៗទៀតរបស់ ក្រុមហ៊ុនរួម និងធនាគារដែលត្រូវមានកាតព្វកិច្ចអនុវត្ត ឬអាចនឹងត្រូវមានកាតព្វកិច្ចអនុវត្តក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទនៃការិយបរិច្ឆេទបញ្ចប់នេះដែលនឹងមានផលប៉ះពាល់ ឬអាចនឹងមានផល ប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ក្រុមហ៊ុនរួម និងធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃ ដល់កំណត់នោះទេ។

## ព្រឹត្តិការណ៍ក្រោយកាលបរិច្ឆេទនៃតារាងតុល្យការ
ពុំមានព្រឹត្តិការណ៍សំខាន់ណាបានកើតឡើងក្រោយពីកាលបរិច្ឆេទតារាងតុល្យការ ដែលតម្រូវអោយមាន ការបង្ហាញ ឬការធ្វើនិយ័តកម្មចំពោះរបាយការណ៍ហិរញ្ញវត្ថុ ក្រៅពីព្រឹត្តិការណ៍ដូចមានបង្ហាញក្នុងកំណត់ សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុនេះទេ។

## ក្រុមប្រឹក្សាភិបាល
សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងការិយបរិច្ឆេទ និងមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះមាននាម ដូចខាងក្រោម៖

| | |
|---|---|
| **លោកបណ្ឌិត ហាន់ ចាងវូ** | ប្រធានក្រុមប្រឹក្សាភិបាល |
| **លោក ហាន់ យូ** | អភិបាល |
| **លោក ហាន់ ខេន** | អភិបាល |
| **យ៉ាបេ យ៉ូស៊ីកាហ៊ីរូ** | អភិបាល |
| **លោកឧកញ៉ា បណ្ឌិត ប៊ុន មុនី** | អភិបាល |
| **ឯកឧត្តម ស៊ុណូហារ៉ា កាត្សុហ៊ីរ៉ូ** | អភិបាលឯករាជ្យ |
| **លោក អ៊ីស៊ីម៉ូរ៉ា មីស៊ូរ៉ូ** | អភិបាលឯករាជ្យ (តែងតាំងថ្ងៃទី១ ខែ តុលា ឆ្នាំ២០១៥ និងអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥) |
| **ឯកឧត្តម អឺរ៉ាំបិ កាស៊្សីយុស៊ី** | អភិបាលឯករាជ្យ(លាលែងពីតំណែង ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥) |

## សវនករឯករាជ្យ

**ក្រុមហ៊ុនសវនកម្មឯករាជ្យ** Ernst & Young ( Cambodia ) Ltd. **ជាសវនកររបស់ក្រុមហ៊ុនរួម។**

## ភាគហ៊ុនកាន់កាប់ដោយអភិបាល
ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាម្នាក់ ដែលមានតួនាទីក្នុងធនាគារមានភាគហ៊ុនផ្ទាល់ នៅក្នុងធនាគារ នាចុងការិយបរិច្ឆេទនេះទេ។

## អត្ថប្រយោជន៍របស់ក្រុមប្រឹក្សាភិបាល
ក្នុងអំឡុងនិងនាចុងការិយបរិច្ឆេទនេះពុំមានការព្រមព្រៀងណាមួយដែលមានធនាគារចូលរួមជាភាគីម្ខាងទៀត ក្នុងគោលបំណងជួយដល់ក្រុមប្រឹក្សាភិបាលរបស់ធនាគារ ដើម្បីទទួលបាននូវអត្ថប្រយោជន៍ដោយ ការទិញយកភាគហ៊ុន ឬលិខិតបំណុលពីសាមីធនាគារ ឬពីក្រុមហ៊ុនដទៃទៀតទេ។

ពុំមានសមាជិកក្រុមប្រឹក្សាភិបាលណាមួយរបស់ធនាគារដែលបានទទួលឬមានសិទ្ធិនឹងទទួលបាននូវអត្ថប្រយោជន៍ណាមួយតាមរយៈការចុះកិច្ចសន្យាដែលបានធ្វើឡើងរវាងធនាគារ និងក្រុមប្រឹក្សាភិបាល ឬ រវាងធនាគារ និងក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងក្រុមប្រឹក្សាភិបាលនោះ ឬជាមួយនឹងក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះជាសមាជិក ឬក៏ជាមួយក្រុមហ៊ុនដែលក្រុមប្រឹក្សាភិបាលនោះមានផលប្រយោជន៍ ផ្នែកហិរញ្ញវត្ថុសំខាន់ៗជាមួយគ្នាក្រៅពីប្រតិបត្តិការដូចមានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

## របាយការណ៍ស្តីពីការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ
ក្រុមប្រឹក្សាភិបាល ជាអ្នកទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាង ត្រឹមត្រូវ ដើម្បីបង្ហាញនូវទិដ្ឋភាពពិតនិងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលហិរញ្ញវត្ថុ ហើយនិងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្រុមប្រឹក្សាភិបាលត្រួតពិនិត្យលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់គណៈគ្រប់គ្រងដែលត្រូវបានតម្រូវអោយៈ

- អនុម័តនូវគោលនយោបាយគណនេយ្យសមស្របដែលផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណយ៉ាងសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្នហើយបន្ទាប់នោះធ្វើការអនុវត្តគោលនយោបាយទាំង នេះជាអចិន្ត្រៃយ៍។
- អនុលោមតាមស្តង់ដារគណនេយ្យកម្ពុជាហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំដែលតម្រូវដោយធនាគារជាតិនៃកម្ពុជាហើយប្រសិនបើការស្វែងរកទិដ្ឋភាពពិតប្រាកដតម្រូវអោយប្រើវិធានដទៃទៀតដែលខុសពីវិធានមុនវិធានថ្មីនេះត្រូវបានបង្ហាញនិងពន្យល់អោយបានច្បាស់លាស់ និងកំណត់ បរិមាណនៃការប្រែប្រួលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។
- រក្សាទុកនូវបញ្ជីគណនេយ្យអោយបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងអោយមានប្រសិទ្ធភាព។
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីមិនសមរម្យក្នុងការសន្មតថាក្រុមហ៊ុនរួមនឹងមិនបន្តធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នាពេល អនាគត។
- គ្រប់គ្រង និងដឹកនាំក្រុមហ៊ុនរួម និងធនាគារប្រកបដោយប្រសិទ្ធភាព លើការសំរេចចិត្តដែលអាចប៉ះពាល់ជាសារវន្តដល់ប្រតិបត្តិការនិងដំណើរការអាជីវកម្មរបស់ធនាគារ ហើយត្រូវប្រាកដថាកិច្ចការ ទាំងនេះ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវ ដើម្បីធានាថាបញ្ជីគណនេយ្យត្រឹមត្រូវ ហើយត្រូវបានរក្សាទុក និង លាតត្រដាងបង្ហាញអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមនិងធនាគារឲ្យបានត្រឹមត្រូវសមហេតុផលគ្រប់ពេល ហើយនិងធានាថាបញ្ជីគណនេយ្យស្របតាមប្រព័ន្ធគណនេយ្យដែលបានចុះបញ្ជី។ គណៈគ្រប់គ្រង ក៏ជាអ្នកទទួលខុសត្រូវក្នុងការថែរក្សាទ្រព្យសកម្មរបស់ក្រុមហ៊ុនរួម ហើយម្យ៉ាងទៀតក៏ត្រូវចាត់ វិធានការសមស្រប ដើម្បីទប់ស្កាត់និងស្វែងរកកំហុសចេតនា ហើយនិងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលបញ្ជាក់ថា ក្រុមហ៊ុនរួមបានអនុវត្តតាមលក្ខខណ្ឌតម្រូវចាំបាច់នានា ដូចដែលបានបញ្ជាក់ខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ
យើងខ្ញុំ ជាក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុដែលមានភ្ជាប់នេះថាបានបង្ហាញនូវ ទិដ្ឋភាពពិតនិងត្រឹមត្រូវ ទៅលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុហើយនិងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជានិងបទបញ្ញត្តិហើយនិងគោលការណ៍ណែនាំពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា។

តំណាងក្រុមប្រឹក្សាភិបាលៈ



HAN, Chang-Woo
ប្រធានក្រុមប្រឹក្សាភិបាល
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

## ម៉ារ៉ូហាន់ ធនាគារជប៉ុន
# របាយការណ៍របស់សវនករឯករាជ្យ

យើងខ្ញុំបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន (រួមគ្នាហៅថា“ក្រុមហ៊ុនរួម”) និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែករបស់ធនាគារដែលរួមមានតារាងតុល្យការរួម និងដាច់ដោយឡែក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងរបាយការណ៍ លទ្ធផលរួម និងដាច់ដោយឡែក របាយការណ៍បម្រែបម្រួលមូលធនរួម និងដាច់ដោយឡែក ព្រមទាំងរបាយការណ៍លំហូរសាច់ប្រាក់រួម និងដាច់ដោយឡែកសម្រាប់ការិយបរិច្ឆេទបញ្ចប់ ហើយនិងគោលនយោបាយគណនេយ្យសំខាន់ៗ និងកំណត់សម្គាល់ផ្សេងៗទៀត (រួមគ្នាហៅថា “របាយការណ៍ហិរញ្ញវត្ថុ“)។

### ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រងចំពោះរបាយការណ៍ហិរញ្ញវត្ថុ
គណៈគ្រប់គ្រងជាអ្នកទទួលខុសត្រូវចំពោះការរៀបចំនិងការបង្ហាញទិដ្ឋភាពពិតនិងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំ ដែលចេញដោយធនាគារជាតិនៃកម្ពុជា ហើយនិងទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលគណៈគ្រប់គ្រងគិតថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។

### ការទទួលខុសត្រូវរបស់សវនករ
ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺបញ្ចេញមតិយោបល់លើរបាយការណ៍ហិរញ្ញវត្ថុនេះដោយផ្អែកលើមូលដ្ឋាននៃការងារសវនកម្ម។ យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា។ ស្តង់ដារទាំងនេះតម្រូវឲ្យយើងខ្ញុំអនុវត្តតាមតម្រូវការនៃក្រមសីលធម៌ និងរៀបចំផែនការនិងបំពេញការងារសវនកម្មដើម្បីទទួលបាននូវការធានាសមហេតុផល ដើម្បីអះអាងថារបាយការណ៍ហិរញ្ញវត្ថុពុំមានកំហុសឆ្គងជា សារវន្តឡើយ។

ការងារសវនកម្មយើងខ្ញុំ រួមមានការអនុវត្តនីតិវិធីទាំងឡាយដើម្បីទទួលបាននូវភស្តុតាងសវនកម្មដែលទាក់ទងទៅនឹងបរិមាណទឹកប្រាក់និងកំណត់សម្គាល់ទាំងឡាយនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ រាល់នីតិវិធីដែលបានជ្រើសរើសខាងលើ គឺពឹងផ្អែកទៅលើការវិនិច្ឆ័យរបស់សវនករ ដោយរាប់បញ្ចូលនូវការវាយតម្លៃទៅលើហានិភ័យលើភាពខុសឆ្គងជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុដែលបណ្តាលមកពីការក្លែងបន្លំ ឬការភាន់ច្រឡំ។ ក្នុងការវាយតម្លៃលើហានិភ័យទាំងនោះសវនករបានពិនិត្យលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងការរៀបចំនិងការបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម ដើម្បីរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈក៏ប៉ុន្តែការវាយតម្លៃទាំងនោះមិនមែនសម្រាប់គោលបំណងក្នុងការបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ក្រុមហ៊ុនរួមនោះទេ។ ការងារសវនកម្មរបស់យើងខ្ញុំ ក៏រួមបញ្ចូលផងដែរនូវការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗដែលធ្វើឡើងដោយគណៈគ្រប់គ្រង ព្រមទាំងការវាយតម្លៃលើការបង្ហាញនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួលមានលក្ខណៈគ្រប់គ្រាន់និងសមស្របដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### មតិយោបល់របស់សវនករ
តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរួម និងដាច់ដោយឡែកនេះបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមនិងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុរួម និងដាច់ដោយឡែក ហើយនិងលំហូរសាច់ប្រាក់រួម និងដាច់ដោយឡែកសម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំដែលចេញដោយធនាគារជាតិនៃកម្ពុជា។

### ការគូសបញ្ជាក់បញ្ហា
ដោយគ្មានការកែប្រែលើមតិយោបល់ យើងសូមទាញចំណាប់អារម្មណ៍ទៅលើកំណត់សម្គាល់លេខ១ទៅនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបង្ហាញពីការបញ្ចូលគ្នានៃប្រតិបត្តិការណ៍រវាងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺស្ថាបនា លីមីតធីត។ នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ធនាគារបានទទួលការយល់ព្រមជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជាលើការរួមបញ្ចូលគ្នាស្ថិតក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួនដែលគួរត្រូវបានអនុវត្តតាមដោយធនាគារ និងស្ថាបនា លីមីតធីត ក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការយល់ព្រម។ នៅថ្ងៃទី១៣ ខែ វិច្ឆិកា ឆ្នាំ២០១៥គណៈគ្រប់គ្រងរបស់ធនាគារនិងស្ថាបនា លីមីតធីត បានដាក់ជូនឯកសារចាំបាច់ផ្សេងៗ ដែលតំរូវដោយធនាគារជាតិនៃកម្ពុជា ដែលឯកសារទាំងនោះមិនទាន់ទទួលបានការអនុម័តពីស្ថាប័នពាក់ព័ន្ធផ្សេងៗនៅឡើយទេ។ យោងតាមផែនការបញ្ចូលគ្នាទ្រព្យសកម្មនិង ទ្រព្យអកម្មរបស់ធនាគារនឹងត្រូវផ្ទេរមកស្ថាបនា លីមីតធីត នាកាលបរិច្ឆេទបញ្ចូលគ្នា ហើយនឹងបន្តបំពេញរាល់សិទ្ធិនិងកាតព្វកិច្ចរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុទាំងនេះត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋាននិរន្តរភាព។



Dai Xuan Nguyen

Partner

Ernst & Young ( Cambodia ) Ltd.

ក្រុមហ៊ុនគណនេយ្យករជំនាញ និងសវនករប្រតិស្រុត

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦

## ម៉ារ៉ូហាន់ ធនាគារជប៉ុន

# តារាងតុល្យការរួម

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ ពាន់រៀល កំណត់សម្គាល់ ២.១ | ២០១៤ ដុល្លារអាមេរិក | ២០១៤ ពាន់រៀល កំណត់សម្គាល់ ២.១ |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ | ៣ | ១៧.៦១៣.៣០៩ | ៧១.៣៣៣.៩០១ | ១០.២១០.៣៨៤ | ៤១.៦០៧.៣១៥ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | ៤ | ៦៥.៨៥២.៨៥១ | ២៦៦.៧០៤.០៤៧ | ៨២.៩៤៨.៧២៨ | ៣៣៨.០១៦.០៦៧ |
| សមតុល្យជាមួយធនាគារផ្សេងៗ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | ៥ | ១៦.០៨៣.៩៥០ | ៦៥.១៣៩.៩៩៨ | ១៥.៨៦៦.០៧៣ | ៦៤.៦៥៤.២៤៧ |
| ប្រាក់បញ្ញើនៅធនាគារ និង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | ៦ | ៩.៥៨៩.៧៧៨ | ៣៨.៨៣៨.៦០១ | ១៧.៥៨៨.២១០ | ៧១.៦៧១.៩៥៦ |
| ឥណទាន និងបុរេប្រទានចំពោះអតិថិជន | ៧ | ៥៤៦.៧១០.៥៤៣ | ២.២១៤.១៧៧.៦៩៩ | ៣៧០.៧២២.៧៨៨ | ១.៥១០.៦៩៥.៣៦១ |
| ទ្រព្យ និងបរិក្ខារ | ៨ | ៥.៩៩៧.៦៨៨ | ២៤.២៩០.៦៣៦ | ៤.៦៣៤.៥៦១ | ១៨.៨៨៥.៨៣៦ |
| កម្មវិធីកុំព្យូទ័រ | ៩ | ២៩៤.៩៩៧ | ១.១៩៤.៧៣៨ | ៥៥៧.២៥៣ | ២.២៧០.៨០៦ |
| មូលនិធិពាណិជ្ជកម្ម | ២៥ | ១៧.៣៨០.០៣០ | ៧០.៣៨៩.១២២ | ១៧.៣៨០.០៣០ | ៧០.៨២៣.៦២២ |
| ពន្ធពន្យារទ្រព្យសកម្ម | ១៣.២ | ១.៤១៣.៥៨១ | ៥.៧២៥.០០៣ | ១.០៥៧.៩៥៨ | ៤.៣១១.១៧៩ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ១៣.៥១៨.៤៨៥ | ៥៤.៧៤៩.៨៦៦ | ៩.៧៣០.១៧២ | ៣៩.៦៥០.៤៥១ |
| **ទ្រព្យសកម្មសរុប** | | **៦៩៤.៤៥៥.២១២** | **២.៨១២.៥៤៣.៦១១** | **៥៣០.៦៩៦.១៥៧** | **២.១៦២.៥៨៦.៨៤០** |
| **ទ្រព្យអកម្ម និងមូលធន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១១ | ២២.៣៩៩.៤៧៥ | ៩០.៧១៧.៨៧៤ | ១៥.៤២២.៨២២ | ៦២.៨៤៨.០០០ |
| ប្រាក់បញ្ញើពីអតិថិជន | ១២ | ៣២៥.៩៩៧.៤៩៩ | ១.៣២០.២៨៩.៨៧១ | ២៥៣.៨៣៥.៧០៥ | ១.០៣៤.៣៨០.៤៩៨ |
| ពន្ធត្រូវបង់ | ១៣.១ | ៤.៤១៥.៩៤១ | ១៧.៨៨៤.៥៦១ | ២.៤៨២.៧៤៦ | ១០.១១៧.១៩០ |
| ប្រាក់កម្ចី | ១៤ | ១៦០.៤២៥.៣៩៦ | ៦៤៩.៧២២.៨៥៤ | ១១៥.៥៣០.២២០ | ៤៧០.៧៨៥.៦៤៧ |
| បំណុលបន្ទាប់បន្សំ | ១៥ | ៣២.៣១៣.២១៧ | ១៣០.៨៦៨.៥២៩ | ៤៧.៣១៣.២១៧ | ១៩២.៨០១.៣៥៩ |
| កាតព្វកិច្ចមូលនិធិសោធននិវត្តន៍ | ១៦ | ៥.៨១៦.៧៣៣ | ២៣.៥៥៧.៧៦៩ | ៤.០៨២.៦៦៦ | ១៦.៦៣៦.៨៦៤ |
| ទ្រព្យអកម្មផ្សេងៗ | ១៧ | ៨.៧០៤.៧១៣ | ៣៥.២៥៤.០៨៨ | ៥.៨៧៩.៥១៥ | ២៣.៩៥៩.០២៣ |
| **ព្យអកម្មសរុប** | | **៥៦០.០៧២.៩៧៤** | **២.២៦៨.២៩៥.៥៤៦** | **៤៤៤.៥៤៦.៨៩១** | **១.៨១១.៥២៨.៥៨១** |
| **មូលធន** | | | | | |
| ដើមទុន | ១៨ | ១០៤.០០០.០០០ | ៤២១.២០០.០០០ | ៧៤.០០០.០០០ | ៣០១.៥៥០.០០០ |
| ចំណេញបង្គរ | | ២៦.៩៧៥.៧៤២ | ១០៩.២៥១.៧៥៦ | ៩.៥៤១.៣៨១ | ៣៨.៨៨១.១២៨ |
| **មូលធនម្ចាស់ភាគហ៊ុនធនាគារ** | | **១៣០.៩៧៥.៧៤២** | **៥៣០.៤៥១.៧៥៦** | **៨៣.៥៤១.៣៨១** | **៣៤០.៤៣១.១២៨** |
| ម្ចាស់ភាគហ៊ុនអប្បភាគ | | ៣.៤០៦.៤៩៦ | ១៣.៧៩៦.៣០៩ | ២.៦០៧.៨៨៥ | ១០.៦២៧.១៣១ |
| **មូលធនសរុប** | | **១៣៤.៣៨២.២៣៨** | **៥៤៤.២៤៨.០៦៥** | **៨៦.១៤៩.២៦៦** | **៣៥១.០៥៨.២៥៩** |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | **៦៩៤.៤៥៥.២១២** | **២.៨១២.៥៤៣.៦១១** | **៥៣០.៦៩៦.១៥៧** | **២.១៦២.៥៨៦.៨៤០** |

# ម៉ារ៉ូហាន់ ធនាគារជប៉ុន

# របាយការណ៍លទ្ធផលរួម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់សម្គាល់ ២.១ |
| ចំណូលការប្រាក់ និងចំណូលប្រហាក់ប្រហែល | ១៩ | ៨៩.០១១.៦៣០ | ៣៦០.៤៩៧.១០២ | ៥៥.៩៣៣.៦០៣ | ២២៧.៩២៩.៤៣២ |
| ចំណាយការប្រាក់ និងចំណាយប្រហាក់ប្រហែល | ២០ | (៣២.៨៨៨.៦៤៦) | (១៣៣.១៩៩.០១៦) | (១៩.៤១១.៧៧៧) | (៧៩.១០២.៩៩១) |
| **ចំណូលការប្រាក់ និងចំណូលប្រហាក់ប្រហែលសុទ្ធ** | | **៥៦.១២២.៩៨៤** | **២២៧.២៩៨.០៨៦** | **៣៦.៥២១.៨២៦** | **១៤៨.៨២៦.៤៤១** |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ | | ២.៤៦១.៩៩២ | ៩.៩៧១.០៦៨ | ១.៦០៩.៤៧៧ | ៦.៥៥៨.៦១៩ |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសារ | | (៦៥៩.៩២៧) | (២.៦៧២.៧០៤) | (៣៤៧.៤៦៧) | (១.៤១៥.៩២៨) |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ** | **២១** | **១.៨០២.០៦៥** | **៧.២៩៨.៣៦៤** | **១.២៦២.០១០** | **៥.១៤២.៦៩១** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ២២ | ២៩៥.៩៨៤ | ១.១៩៨.៧៣៥ | ៨៧.៤២១ | ៣៥៦.២៤១ |
| **ចំណូលពីប្រតិបត្តិការសរុប** | | **៥៨.២២១.០៣៣** | **២៣៥.៧៩៥.១៨៥** | **៣៧.៨៧១.២៥៧** | **១៥៤.៣២៥.៣៧៣** |
| ចំណាយរដ្ឋបាលនិងចំណាយទូទៅ | ២៣ | (៣២.៥៦៦.៦៧២) | (១៣១.៨៩៥.០២២) | (២៤.៥៧៧.៧១១) | (១០០.១៥៤.១៧២) |
| សំវិធានធនលើឥណទាន និងបុរេប្រទាន | ៧ | (១.១៣០.៦៨៧) | (៤.៥៧៩.២៨២) | (១.០១៨.០៧៣) | (៤.១៤៨.៦៤៧) |
| សំវិធានធនសម្រាប់ការខាតបង់ | ១០ | (១.២៥៤.៧៨៥) | (៥.០៨១.៨៧៩) | - | - |
| **ចំណេញមុនបង់ពន្ធ** | | **២៣.២៦៨.៨៨៩** | **៩៤.២៣៩.០០២** | **១២.២៧៥.៤៧៣** | **៥០.០២២.៥៥៤** |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៣ | (៤.៩០៦.៤៣៦) | (១៩.៨៧១.០៦៦) | (២.៦៧៨.២៤៨) | (១០.៩១៣.៨៦១) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **១៨.៣៦២.៤៥៣** | **៧៤.៣៦៧.៩៣៦** | **៩.៥៩៧.២២៥** | **៣៩.១០៨.៦៩៣** |
| **ដែលត្រូវបែងចែកដូចខាងក្រោម៖** | | | | | |
| ម្ចាស់ភាគហ៊ុនធនាគារ | | ១៧.៤៣៤.៣៦១ | ៧០.៦០៩.១៦៣ | ៩.០៧៩.៣០៥ | ៣៦.៩៩៨.១៦៨ |
| ម្ចាស់ភាគហ៊ុនអប្បភាគ | | ៩២៨.០៩២ | ៣.៧៥៨.៧៧៣ | ៥១៧.៩២០ | ២.១១០.៥២៥ |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **១៨.៣៦២.៤៥៣** | **៧៤.៣៦៧.៩៣៦** | **៩.៥៩៧.២២៥** | **៣៩.១០៨.៦៩៣** |

## ម៉ារ៉ូហាន់ ធនាគារជប៉ុន

# របាយការណ៍បម្រែបម្រួលមូលធនរួម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | ម្ចាស់ភាគហ៊ុនធនាគារ | | | | |
|---|---|---|---|---|---|
| | ដើមទុន<br>ដុល្លារអាមេរិក | ចំណេញ(ខាត)បង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក | ម្ចាស់ភាគហ៊ុនអប្បភាគ | សរុប<br>ដុល្លារអាមេរិក |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៧៤.០០០.០០០ | ៩.៥៤១.៣៨១ | ៨៣.៥៤១.៣៨១ | ២.៦០៧.៨៨៥ | ៨៦.១៤៩.២៦៦ |
| ការបំលែងបំណុលបន្ទាប់បន្សំជាមូលធន | ៣០.០០០.០០០ | - | ៣០.០០០.០០០ | - | ៣០.០០០.០០០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ១៧.៤៣៤.៣៦១ | ១៧.៤៣៤.៣៦១ | ៩២៨.០៩២ | ១៨.៣៦២.៤៥៣ |
| ភាគលាភដែលបានប្រកាស | - | - | - | (១២៩.៤៨១) | (១២៩.៤៨១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **១០៤.០០០.០០០** | **២៦.៩៧៥.៧៤២** | **១៣០.៩៧៥.៧៤២** | **៣.៤០៦.៤៩៦** | **១៣៤.៣៨២.២៣៨** |
| **ពាន់រៀល** (**កំណត់សម្គាល់ ២.១**) | **៤២១.២០០.០០០** | **១០៩.២៥១.៧៥៦** | **៥៣០.៤៥១.៧៥៦** | **១៣.៧៩៦.៣០៩** | **៥៤៤.២៤៨.០៦៥** |
| | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៧៤.០០០.០០០ | ៤៦២.០៧៦ | ៧៤.៤៦២.០៧៦ | ១.៧១៨.៦៦៥ | ៧៦.១៨០.៧៤១ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ៩.០៧៩.៣០៥ | ៩.០៧៩.៣០៥ | ៥១៧.៩២០ | ៩.៥៩៧.២២៥ |
| ដើមទុនបានផ្តល់ | - | - | - | ៤៤៥.៩២៨ | ៤៤៥.៩២៨ |
| ភាគលាភដែលបានប្រកាស | - | - | - | (៧៤.៦២៨) | (៧៤.៦២៨) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៧៤.០០០.០០០** | **៩.៥៤១.៣៨១** | **៨៣.៥៤១.៣៨១** | **២.៦០៧.៨៨៥** | **៨៦.១៤៩.២៦៦** |
| **ពាន់រៀល** (**កំណត់សម្គាល់ ២.១**) | **៣០១.៥៥០.០០០** | **៣៨.៨៨១.១២៨** | **៣៤០.៤៣១.១២៨** | **១០.៦២៧.១៣១** | **៣៥១.០៥៨.២៥៩** |

# ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី

# របាយការណ៍លំហូរសាច់ប្រាក់រួម

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ ពាន់រៀល កំណត់សម្គាល់ ២.១ | ២០១៤ ដុល្លារអាមេរិក | ២០១៤ ពាន់រៀល កំណត់សម្គាល់ ២.១ |
|---|---|---|---|---|---|
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពប្រតិបត្តិការ** | ២៤ | (៨១.២០៦.៤៩១) | (៣២៨.៨៨៦.២៨៨) | (៣.៤៤២.០៥៨) | (១៤.០២៦.៣៨៥) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ថយ(កើន) ប្រាក់បញ្ញើនៅធនាគារ | | | | | |
| ផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | | ៥.៥៧៥.១៩៧ | ២២.៥៧៩.៣៨៥ | (១៣.០២៥.១៩៧) | (៥៣.០៧៧.៤៧៨) |
| ការទិញទ្រព្យ និងបរិក្ខារ និងកម្មវិធីកុំព្យូទ័រ | ៨,៩ | (៤.០២១.៥៥២) | (១៦.២៨៧.២៨៦) | (២.៧៣១.៥៨៥) | (១១.១៣១.២០៩) |
| ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ | | ២០.៤៨៩ | ៨២.៩៤០ | ៣៦.៣៦៥ | ១៤៨.១៨៧ |
| **សាច់ប្រាក់សុទ្ធបានពី (ប្រើក្នុង) សកម្មភាព វិនិយោគ** | | **១.៥៧៤.០៨៤** | **៦.៣៧៥.០៣៩** | **(១៥.៧២០.៣៦៧)** | **(៦៤.០៦០.៤៩៦)** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| ចំណូលពីប្រាក់កម្ចី | | ៨៧.២៤៩.៥០៦ | ៣៥៣.៣៦០.៤៩៩ | ៦៥.៧០០.០០០ | ២៦៧.៧២៧.៥០០ |
| ការទូទាត់សងប្រាក់កម្ចី | | (៤២.៣៥៤.៣៣០) | (១៧១.៥៣៥.០៣៧) | (៣៣.៥៧៧.១៦៥) | (១៣៦.៨២៦.៩៤៧) |
| ចំណូលពីបំណុលបន្ទាប់បន្សំ | ១៥ | ១៥.០០០.០០០ | ៦០.៧៥០.០០០ | ១០.០០០.០០០ | ៤០.៧៥០.០០០ |
| ការទូទាត់ភាគលាភ | | (១២៩.៤៨១) | (៥២៤.៣៩៨) | (៧៤.៦២៨) | (៣០៤.១០៩) |
| ដើមទុនផ្តល់ដោយម្ចាស់ភាគហ៊ុន | | | | | |
| អប្បភាគ | | - | - | ៤៤៥.៩២៨ | ១.៨១៧.១៥៧ |
| **សាច់ប្រាក់សុទ្ធបានពីសកម្មភាពហិរញ្ញប្បទាន** | | **៥៩.៧៦៥.៦៩៥** | **២៤២.០៥១.០៦៤** | **៤២.៤៩៤.១៣៥** | **១៧៣.១៦៣.៦០១** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ថយ) កើនសុទ្ធក្នុងការិយបរិច្ឆេទ** | | (១៩.៨៦៦.៧១២) | (៨០.៤៦០.១៨៥) | ២៣.៣៣១.៧១០ | ៩៥.០៧៦.៧២០ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ | | ៧៧.៦៣៥.៨៩៥ | ៣១៦.៣៦៦.២៧២ | ៥៤.៣០៤.១៨៥ | ២១៦.៩៤៥.២១៩ |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | (១.៩៤០.៨៩៥) | - | ៤.៣៤៤.៣៣៣ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ | ៣ | **៥៧.៧៦៩.១៨៣** | **២៣៣.៩៦៥.១៩២** | **៧៧.៦៣៥.៨៩៥** | **៣១៦.៣៦៦.២៧២** |
| **ប្រតិបត្តិការពុំមែនសាច់ប្រាក់ដែលសំខាន់ៈ** | | | | | |
| ការបំលែងបំណុលបន្ទាប់បន្សំជាមូលធន | | ៣០.០០០.០០០ | ១២១.៥០០.០០០ | - | - |

## តារាងតុល្យការដាច់ដោយឡែក

# តារាងតុល្យការដាច់ដោយឡែក

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | | កំណត់សម្គាល់ ២.១ | | កំណត់សម្គាល់ ២.១ |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៣ | ៣.៥៦៣.១៧៥ | ១៤.៤៣០.៨៥៩ | ៣.២៤០.៦៥៣ | ១៣.២០៥.៦៦១ |
| សមតុល្យជាមួយធនាគារជាតិនៃកម្ពុជា | ៤ | ៣៧.០៧១.១៥៨ | ១៥០.១៣៨.១៥៩ | ៥៦.៦៣៦.៤៥៣ | ២៣០.៧៩៣.៥៤៦ |
| សមតុល្យជាមួយធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | ៥ | ៩.១៧០.៤៩៦ | ៣៧.១៤០.៥០៩ | ៩.៧០៧.១៧៦ | ៣៩.៥៥៦.៧៤២ |
| ប្រាក់បញ្ញើនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | ៦ | ១១.៤៧១.៨៣៤ | ៤៦.៤៦០.៩២៨ | ១៨.៩០៩.២៤២ | ៧៧.០៥៥.១៦១ |
| ឥណទាន និងបុរេប្រទានចំពោះអតិថិជន | ៧ | ៨៤.៨១៥.៤៤១ | ៣៤៣.៥០២.៥៣៦ | ៦៩.០២២.១៥៦ | ២៨១.២៦៥.២៨៦ |
| វិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ២៥ | ៤៧.៩៣៩.៦៨៣ | ១៩៤.១៥៥.៧១៦ | ៤៧.៩៣៩.៦៨៣ | ១៩៥.៣៥៤.២០៨ |
| ទ្រព្យ និងបរិក្ខារ | ៨ | ៦៣៨.៩៤០ | ២.៥៨៧.៧០៧ | ៧៩០.៧១៥ | ៣.២២២.១៦៤ |
| កម្មវិធីកុំព្យូទ័រ | ៩ | ៩៦.០៩៣ | ៣៨៩.១៧៧ | ១៥៩.៤៤៤ | ៦៤៩.៧៣៤ |
| ពន្ធពន្យារទ្រព្យសកម្ម | ១៣.២ | - | - | ៩១.៨៧៣ | ៣៧៤.៣៨២ |
| ទ្រព្យសកម្មផ្សេងៗ | ១០ | ២.៣៣៦.១៥០ | ៩.៤៦១.៤០៨ | ២.២៨៣.៤៦៤ | ៩.៣០៥.១១៦ |
| **ទ្រព្យសកម្មសរុប** | | **១៩៧.១០២.៩៦០** | **៧៩៨.២៦៦.៩៨៩** | **២០៨.៧៨០.៨៥៩** | **៨៥០.៧៨២.០០០** |
| **ទ្រព្យអកម្ម និងមូលធន** | | | | | |
| **ទ្រព្យអកម្ម** | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ១១ | ៨.៦៩១.៣៥៤ | ៣៥.១៩៩.៩៨៤ | ៧.៦២៥.៩៤៥ | ៣១.០៧៥.៧២៦ |
| ប្រាក់បញ្ញើពីអតិថិជន | ១២ | ៨២.៥៧០.៦៩៨ | ៣៣៤.៤១១.៣២៧ | ៩៧.០០៨.៤១៦ | ៣៩៥.៣០៩.២៩៥ |
| ពន្ធត្រូវបង់ | ១៣.១ | ៤.៨៩៦ | ១៩.៨២៩ | - | - |
| បំណុលបន្ទាប់បន្សំ | ១៥ | - | - | ៣០.០០០.០០០ | ១២២.២៥០.០០០ |
| កាតព្វកិច្ចមូលនិធិសោធននិវត្តន៍ | ១៦ | ៤៤៥.៥៥៣ | ១.៨០៤.៤៩០ | ៣៣៣.៤០៨ | ១.៣៥៨.៦៣៨ |
| ទ្រព្យអកម្មផ្សេងៗ | ១៧ | ១.២៧០.១៦៧ | ៥.១៤៤.១៧៦ | ១.៦៧១.២៥៤ | ៦.៨១០.៣៥៩ |
| **ទ្រព្យអកម្មសរុប** | | **៩២.៩៨២.៦៦៨** | **៣៧៦.៥៧៩.៨០៦** | **១៣៦.៦៣៩.០២៣** | **៥៥៦.៨០៤.០១៨** |
| **មូលធន** | | | | | |
| ដើមទុន | ១៨ | ១០៤.០០០.០០០ | ៤២១.២០០.០០០ | ៧៤.០០០.០០០ | ៣០១.៥៥០.០០០ |
| ចំណេញបង្គរ (ខាតបង្គរ) | | ១២០.២៩២ | ៤៨៧.១៨៣ | (១.៨៥៨.១៦៤) | (៧.៥៧២.០១៨) |
| **មូលធនសរុប** | | **១០៤.១២០.២៩២** | **៤២១.៦៨៧.១៨៣** | **៧២.១៤១.៨៣៦** | **២៩៣.៩៧៧.៩៨២** |
| **ទ្រព្យអកម្ម និងមូលធនសរុប** | | **១៩៧.១០២.៩៦០** | **៧៩៨.២៦៦.៩៨៩** | **២០៨.៧៨០.៨៥៩** | **៨៥០.៧៨២.០០០** |

# របាយការណ៍លទ្ធផលដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ ដុល្លារអាមេរិក | ២០១៥ ពាន់រៀល កំណត់សម្គាល់ ២.១ | ២០១៤ ដុល្លារអាមេរិក | ២០១៤ ពាន់រៀល កំណត់សម្គាល់ ២.១ |
|---|---|---|---|---|---|
| ចំណូលការប្រាក់ និង ចំណូលប្រហាក់ប្រហែល | ១៩ | ៧.៧១៩.៦៤៥ | ៣១.២៦៤.៥៦២ | ៦.៣៥២.១៣៤ | ២៥.៨៨៤.៩៤៦ |
| ចំណាយការប្រាក់ និង ចំណាយប្រហាក់ប្រហែល | ២០ | (៣.៥០៩.៤៦៩) | (១៤.២១៣.៣៤៩) | (៣.២៥៦.៨៦៣) | (១៣.២៧១.៧១៧) |
| **ចំណូលការប្រាក់ និង ចំណូលប្រហាក់ប្រហែលសុទ្ធ** | | **៤.២១០.១៧៦** | **១៧.០៥១.២១៣** | **៣.០៩៥.២៧១** | **១២.៦១៣.២២៩** |
| ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារ | | ៧៨៨.៤៣៩ | ៣.១៩៣.១៧៨ | ៥៤០.៩២២ | ២.២០៤.២៥៧ |
| ចំណាយថ្លៃឈ្នួល និងកម្រៃជើងសារ | | (៣០.១៨០) | (១២២.២២៩) | (៦.២០៨) | (២៥.២៩៨) |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ** | ២១ | **៧៥៨.២៥៩** | **៣.០៧០.៩៤៩** | **៥៣៤.៧១៤** | **២.១៧៨.៩៥៩** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | ២២ | ២.៦៣០.៩២០ | ១០.៦៥៥.២២៦ | ១.៤៣២.៥៦៧ | ៥.៨៣៧.៧១១ |
| **ចំណូលពីប្រតិបត្តិការសរុប** | | **៧.៥៩៩.៣៥៥** | **៣០.៧៧៧.៣៨៨** | **៥.០៦២.៥៥២** | **២០.៦២៩.៨៩៩** |
| ចំណាយរដ្ឋបាលនិងចំណាយទូទៅ | ២៣ | (៣.៧៩៥.៤២៤) | (១៥.៣៧១.៤៦៧) | (៣.៨៤៩.៧៨៨) | (១៥.៦៨៧.៨៨៦) |
| សំវិធានធនលើឥណទាន និងបុរេប្រទាន | ៧ | (៣៨៧.៣៨៨) | (១.៥៦៨.៩២១) | (៤០២.១៥០) | (១.៦៣៨.៧៦១) |
| សំវិធានធនសម្រាប់ការខាតបង់ | ១០ | (១.២៥៤.៧៨៥) | (៥.០៨១.៨៧៩) | - | - |
| **ចំណេញមុនបង់ពន្ធ** | | **២.១៦១.៧៥៨** | **៨.៧៥៥.១២១** | **៨១០.៦១៤** | **៣.៣០៣.២៥២** |
| ចំណាយពន្ធលើប្រាក់ចំណេញ | ១៣ | (១៨៣.៣០២) | (៧៤២.៣៧៣) | (២៥.៤៧៨) | (១០៣.៨២៣) |
| **ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | | **១.៩៧៨.៤៥៦** | **៨.០១២.៧៤៨** | **៧៨៥.១៣៦** | **៣.១៩៩.៤២៩** |

## ម៉ារ៉ូហាន់ ធនាគារជប៉ុន ភីអិលស៊ី

# របាយការណ៍បម្រែបម្រួលមូលធនដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | ដើមទុន<br>ដុល្លារអាមេរិក | ចំណេញបង្គរ (ខាតបង្គរ)<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៧៤.០០០.០០០ | (១.៨៥៨.១៦៤) | ៧២.១៤១.៨៣៦ |
| ការបំលែងបំណុលបន្ទាប់បន្សំជាមូលធន | ៣០.០០០.០០០ | - | ៣០.០០០.០០០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ១.៩៧៨.៤៥៦ | ១.៩៧៨.៤៥៦ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥** | **១០៤.០០០.០០០** | **១២០.២៩២** | **១០៤.១២០.២៩២** |
| **ពាន់រៀល** (កំណត់សម្គាល់ ២.១) | **៤២១.២០០.០០០** | **៤៨៧.១៨៣** | **៤២១.៦៨៧.១៨៣** |
| សមតុល្យនៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៧៤.០០០.០០០ | (២.៦៤៣.៣០០) | ៧១.៣៥៦.៧០០ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | ៧៨៥.១៣៦ | ៧៨៥.១៣៦ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៤** | **៧៤.០០០.០០០** | **(១.៨៥៨.១៦៤)** | **៧២.១៤១.៨៣៦** |
| **ពាន់រៀល** (កំណត់សម្គាល់ ២.១) | **៣០១.៥៥០.០០០** | **(៧.៥៧២.០១៨)** | **២៩៣.៩៧៧.៩៨២** |

## ម៉ារូហាន់ ធនាគារជប៉ុន ភីអិលស៊ី

# របាយការណ៍លំហូរសាច់ប្រាក់ដាច់ដោយឡែក

សម្រាប់ការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

| | កំណត់សម្គាល់ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់សម្គាល់ ២.១ |
| **សាច់ប្រាក់សុទ្ធ (ប្រើក្នុង) បានពីសកម្មភាពប្រតិបត្តិការ** | ២៤ | **(២៧.១៣៩.០៤៧)** | **(១០៩.៩១៣.១៤០)** | **៣២.៤៩៥.៧៣៨** | **១៣២.៤២០.១៣៤** |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ថយ (កើន) ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | | ៥.០១៤.១២៣ | ២០.៣០៧.១៩៨ | (១៣.៥៧៣.៦១៧) | (៥៥.៣១២.៤៩០) |
| ទិញទ្រព្យ និងបរិក្ខារ និងកម្មវិធីកុំព្យូទ័រ | ៨,៩ | (៧៩.០៦៩) | (៣២០.២២៩) | (៥៨៨.១១៦) | (២.៣៩៦.៥៧៣) |
| ចំណូលពីការលក់ទ្រព្យ និងបរិក្ខារ | | ១.០៩៣ | ៤.៤២៧ | ២០.១៨៦ | ៨២.២៥៨ |
| វិនិយោគបន្ថែមក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ | ២៤ | - | - | (៨.៦៥៤.៦០០) | (៣៥.២៦៧.៤៩៥) |
| **សាច់ប្រាក់សុទ្ធបានពី (ប្រើក្នុង) សកម្មភាពវិនិយោគ** | | **៤.៩៣៦.១៤៧** | **១៩.៩៩១.៣៩៦** | **(២២.៧៩៦.១៤៧)** | **(៩២.៨៩៤.៣០០)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល (ថយ) កើនសុទ្ធ ក្នុងការិយបរិច្ឆេទ** | | **(២២.២០២.៩០០)** | **(៨៩.៩២១.៧៤៤)** | **៩.៦៩៩.៥៩១** | **៣៩.៥២៥.៨៣៤** |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅដើមការិយបរិច្ឆេទ | | ៥៣.២២២.៨០៥ | ២១៦.៨៨២.៩៣០ | ៤៣.៥២៣.២១៤ | ១៧៣.៨៧៥.២៤០ |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | (១.៣៣០.៥៧០) | - | ៣.៤៨១.៨៥៦ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នៅចុងការិយបរិច្ឆេទ** | ៣ | **៣១.០១៩.៩០៥** | **១២៥.៦៣០.៦១៦** | **៥៣.២២២.៨០៥** | **២១៦.៨៨២.៩៣០** |
| **ប្រតិបត្តិការពុំមែនសាច់ប្រាក់ដែលសំខាន់ៈ ការបំលែងបំណុលបន្ទាប់បន្សំជាមូលធន** | | **៣០.០០០.០០០** | **១២១.៥០០.០០០** | - | - |

# ម៉ារូហាន់ ធនាគារជប៉ុន ភីអិលស៊ី

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥

## ១. ព័ត៌មានអំពីធនាគារ

### ការបង្កើត និងប្រតិបត្តិការ

ម៉ារូហាន់ ធនាគារជប៉ុន ភីអិលស៊ី(“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធ (រួមគ្នាហៅថា“ក្រុមហ៊ុនរួម”)ត្រូវបានបង្កើតឡើងនិងចុះបញ្ជីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០០៨ ធនាគារត្រូវបានបង្កើតឡើង ដោយចុះបញ្ជីជាមួយនឹងក្រសួង ពាណិជ្ជកម្ម ហើយនិងត្រូវបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០០៨។ ត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ធនាគារ ជាបុត្រសម្ព័ន្ធគ្រប់គ្រងទាំងស្រុងដោយ ក្រុមហ៊ុន Mahuran Investment Asia Pte. ដែលជាក្រុមហ៊ុនចុះបញ្ជីនៅប្រទេសសិង្ហបុរី។

ធនាគារ ត្រូវបានបង្កើតឡើងដើម្បីធ្វើប្រតិបត្តិការអាជីវកម្មលើរាល់សកម្មភាពធនាគាររួមមាន៖ ចល័តកម្ម និងការទទួលនូវមូលនិធិបញ្ញើសម្រាប់រយៈពេលខ្លី មធ្យម និងវែងពីអង្គភាព និង រូបវន្តបុគ្គលទូទៅ ផ្តល់ប្រាក់កម្ចីរយៈពេលខ្លី មធ្យម និងវែងដល់អង្គភាព និងរូបវន្តបុគ្គលទៅតាមប្រភេទអាជីវកម្ម និងលទ្ធភាពនៃប្រភពធនធានរបស់ធនាគារ ធ្វើប្រតិបត្តិការអាជីវកម្ម រូបិយប័ណ្ណបរទេស ផ្តល់សេវាកម្មហិរញ្ញប្បទាន ពាណិជ្ជកម្មអន្តរជាតិធ្វើអប្បហារកម្មលើមូលបត្រពាណិជ្ជកម្ម ផ្តល់សេវាប្រតិបត្តិការរវាងអតិថិជន និងសេវាកម្មធនាគារផ្សេងៗទៀត ដែលបានអនុញ្ញាតដោយធនាគារជាតិនៃកម្ពុជា។

នៅថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១២ ធនាគារបានចុះកិច្ចសន្យាការទិញលក់ រវាង Stichting Triodos-Doen (“ST”), Nederlandse Financierings-Maatschapij Voor Ontwikellingslanden N.V. (“NFVO”), DWM Funds S.C.A.-SICAV SIF (“DWM”), Cambodia Community Building (“CCB”) និង Sathapana Employee Investment Limited (“SEI”) ដើម្បីទិញ៩៥,១% នៃភាគហ៊ុនរបស់ស្ថាបនា លីមីតធីត (“ក្រុមហ៊ុនបុត្រសម្ព័ន្ធ”)។ ការទិញលក់នេះត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០១២។ បន្ថែមពីនេះ ការផ្លាស់ប្តូរភាគហ៊ុននេះ ត្រូវបានអនុម័តដោយក្រសួង ពាណិជ្ជកម្ម នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២។

សកម្មភាពចម្បងរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺការផ្តល់សេវាមីក្រូហិរញ្ញវត្ថុទៅសហគ្រិនក្រីក្រជាពិសេសស្ត្រីនៅតាមតំបន់ជនបទ និងទីក្រុងនៅប្រទេសកម្ពុជា តាមរយៈការិយាល័យកណ្តាលនៅទីក្រុងភ្នំពេញរបស់ខ្លួន និងការិយាល័យនៅតាមបណ្តាខេត្ត និងស្រុកនានានៃព្រះរាជាណាចក្រកម្ពុជា។ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណមីក្រូហិរញ្ញវត្ថុឥតមានរយៈពេលកំណត់ដល់ ក្រុមហ៊ុនបុត្រសម្ព័ន្ធនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៦។

នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០០៩ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណឲ្យក្រុមហ៊ុនបុត្រសម្ព័ន្ធ ក្នុងការផ្តល់សេវាប្រាក់បញ្ញើ។
នៅថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១៤ ក្រុមហ៊ុនបុត្រសម្ព័ន្ធទទួលបានអាជ្ញាប័ណ្ណ៣ឆ្នាំផ្សេងទៀតក្នុងការផ្តល់សេវាប្តូរប្រាក់។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានអនុម័តអោយចេញផ្សាយដោយក្រុម ប្រឹក្សាភិបាល នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦។

### ដើមទុន

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដើមទុនរបស់ធនាគារ ដែលបានបង់មានចំនួន ១០៤ លានដុល្លារ អាមេរិក (ឆ្នាំ២០១៤៖ ៧៤ លានដុល្លារអាមេរិក)។

### ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលនៅក្នុងការិយបរិច្ឆេទ មកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មាននាមដូចខាងក្រោម៖

| | |
|---|---|
| **លោកបណ្ឌិត ហាន់ ចាងូ** | ប្រធានក្រុមប្រឹក្សាភិបាល |
| **លោក ហាន់ យូ** | អភិបាល |
| **លោក ហាន់ ខេន** | អភិបាល |
| **យ៉ាបេ យ៉ូស៊ីកាហ៊្សូ** | អភិបាល |
| **លោកឧកញ៉ា បណ្ឌិត ប៊ុន មុនី** | អភិបាល |
| **ឯកឧត្តម ស៊ីណូហារ៉ា កាត្សុហ៊ីរ៉ូ** | អភិបាលឯករាជ្យ |
| **លោក អ៊ីស៊ីម៉ូរ៉ា ម៉ីសូរ៉ូ** | អភិបាលឯករាជ្យ (តែងតាំងថ្ងៃទី១ ខែតុលា ឆ្នាំ២០១៥<br>និង អនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ២០១៥) |
| **ឯកឧត្តម អីរ៉ាំបិ កាស្សឺយុស៊ី** | អភិបាលឯករាជ្យ(លាលែងពីតំណែងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥) |

**ទីតាំង**

ទីស្នាក់ការកណ្តាលរបស់ធនាគារមានទីតាំងនៅអគារលេខ៨៣ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ទី៣ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញព្រះរាជាណាចក្រកម្ពុជា។

**និយោជិត**

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ធនាគារមាននិយោជិតសរុបចំនួន ៨៩នាក់ (ឆ្នាំ២០១៤៖ ៨១នាក់)។

**ការរួមបញ្ចូលគ្នាជាមួយស្ថាបនាលីមីតធីត**

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនរួមបានព្រមព្រៀងគ្នាក្នុងការរួមបញ្ចូលប្រតិបត្តិការនៃធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាល និងគណៈគ្រប់គ្រងនៃក្រុមហ៊ុនរួមបានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់សម្រាប់ការរួមបញ្ចូលខាងលើ។

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៥ ធនាគារបានទទួលការយល់ព្រមជាគោលការណ៍ពីធនាគារជាតិនៃកម្ពុជាលើការរួមបញ្ចូលគ្នា ស្ថិតក្រោមលក្ខខណ្ឌជាក់លាក់មួយចំនួនដែលគួរត្រូវបានអនុវត្តតាមដោយក្រុមហ៊ុនរួមក្នុងរយៈពេលប្រាំមួយខែបន្ទាប់ពីការយល់ព្រម។ នៅថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ គណៈគ្រប់គ្រងរបស់ក្រុមហ៊ុនរួមបានដាក់ជូនឯកសារចាំបាច់ផ្សេងៗ ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ មកដល់ពេលនេះ ធនាគារមិនទាន់ទទួលបានការអនុម័តពីស្ថាប័នពាក់ព័ន្ធផ្សេងៗនៅឡើយទេ។

**២. គោលនយោបាយគណនេយ្យ**

គោលនយោបាយគណនេយ្យសំខាន់ៗដែលប្រើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ និងដាច់ដោយឡែកមានកំណត់ដូចខាងក្រោម។ គោលនយោបាយទាំងនេះ ត្រូវបានអនុវត្តយ៉ាងជាប់លាប់ នៅគ្រប់ការិយបរិច្ឆេទដែលបានបង្ហាញ លើកលែងតែមានការលើកឡើងផ្សេងពីនេះ។

**២.១ មូលដ្ឋាននៃការរៀបចំ**

របាយការណ៍ហិរញ្ញវត្ថុ និងដាច់ដោយឡែក (ហៅថា "របាយការណ៍ហិរញ្ញវត្ថុ") ត្រូវបានរៀបចំ តាមសម្មតិកម្មថ្លៃដើមប្រវត្តិសាស្ត្រ។ ក្រុមហ៊ុនរួមបានកត់ត្រា និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុជា ទឹកប្រាក់ដុល្លារអាមេរិក ស្របតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខធ៧-០៧-១៦៤ ចុះ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ស្តីពីការប្រើប្រាស់ភាសា ឯកតារូបិយប័ណ្ណ និងអត្រាប្តូរប្រាក់សម្រាប់កិច្ច បញ្ជីកាគណនេយ្យ និងរបាយការណ៍។

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងរបស់ធនាគារត្រូវបានរៀបចំឡើងតាមអនុលោមតាមស្តង់ដារគណនេយ្យកម្ពុជា ហើយនិងបទបញ្ញត្តិ និងគោលការណ៍ណែនាំចេញដោយធនាគារជាតិនៃកម្ពុជា។

ការប្រែសម្រួលទឹកប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមប្រកាសលេខ ធ៧-០៧-១៦៤ ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ការប្រើប្រាស់ អត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា នៅចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដែល ១ ដុល្លារអាមេរិក ស្មើនឹង ៤.០៥០ រៀល (ឆ្នាំ២០១៤៖១ដុល្លារអាមេរិកស្មើនឹង ៤.០៧៥ រៀល)។ ដូច្នេះតួលេខប្រែសម្រួលជាប្រាក់រៀលដែលបានបង្ហាញនេះ និងមិនគួរត្រូវយកមកបកស្រាយថាជាតួលេខដែលអាចត្រូវបាន ឬនឹងត្រូវបានឬនាពេលអនាគតនឹងត្រូវបានប្តូរទៅជាប្រាក់ដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់នេះ ឬអត្រាផ្សេងៗទៀតបានឡើយ។

**ឆ្នាំសារពើពន្ធ**

ឆ្នាំសារពើពន្ធរបស់ក្រុមហ៊ុនរួម គឺចាប់ផ្តើមពីថ្ងៃទី១ ខែមករា និងបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។

**២.២ ការវិនិច្ឆ័យ និង ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ**

ក្នុងការអនុវត្តគោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនរួមគណៈគ្រប់គ្រងបានធ្វើការវិនិច្ឆ័យ និងការប៉ាន់ស្មានរបស់ខ្លួនក្នុងការកំណត់ចំនួនទឹកប្រាក់ដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍ ហិរញ្ញវត្ថុ ដូចខាងក្រោម៖

**២.២.១ ការសន្មតអំពីនិរន្តរភាព**

ដូចដែលបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ១ ក្រុមហ៊ុនរួមបានដាក់បែបបទស្នើសុំនៃការរួមបញ្ចូល នៃប្រតិបត្តិការទៅកាន់ធនាគារជាតិនៃកម្ពុជារួចរាល់ហើយ។ យោងតាមផែនការបញ្ចូលគ្នាទ្រព្យសកម្មនិង ទ្រព្យអកម្មរបស់ធនាគារនឹងត្រូវផ្ទេរមកក្រុមហ៊ុនបុត្រសម្ព័ន្ធនាកាលបរិច្ឆេទបញ្ចូលគ្នាដែលនឹងបន្តបំពេញរាល់សិទ្ធិ និងកាតព្វកិច្ចរបស់ធនាគារ។ ជាមួយគ្នាផងដែររបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ត្រូវបានរៀបចំឡើងផ្អែកលើមូលដ្ឋាននិរន្តរភាព។

**២.២.២ ភតិសន្យា**

ក្រុមហ៊ុនរួមបានចុះកិច្ចសន្យាជួលអចលនទ្រព្យក្នុងនាមជាអ្នកជួលសម្រាប់អគារការិយាល័យរបស់ខ្លួន។ ក្រុមហ៊ុនរួមបានកំណត់ថាម្ចាស់អគារ ជាអ្នករ៉ាប់រងលើរាល់ហានិភ័យធំៗ និងជាម្ចាស់កម្មសិទ្ធិលើអចលនទ្រព្យនេះដោយផ្អែកទៅតាមសូចនាករនៃភតិសន្យាប្រតិបត្តិ។ នៅក្នុងការ កំណត់ថាមាន ឬមិនមានសូចនាករនៃការអនុវត្តន៍ភតិសន្យាប្រតិបត្តិក្រុមហ៊ុនរួមពិចារណាលើកត្តាដូចជា៖ ការរក្សាទុកប្លង់កម្មសិទ្ធិរបស់អចលនទ្រព្យដែលបានជួល និងរយៈពេលនៃកិច្ចសន្យាជួលទាក់ទងជាមួយនឹងការប៉ាន់ស្មានរយៈពេលប្រើប្រាស់សេដ្ឋកិច្ចរបស់អចលនទ្រព្យ ដែលបាន ជួលថ្លៃត់ការ និងថ្លៃផ្សេងៗ។

**២.២.៣ ការខាតបង់ដោយការថយចុះតម្លៃលើឥណទាន និងបុរេប្រទានចំពោះអតិថិជន**

នៅពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ គុណភាពនៃឥណទាន និងបុរេប្រទានត្រូវបានត្រួតពិនិត្យ និងវាយតម្លៃដើម្បីកំណត់ចំណាត់ថ្នាក់និងកម្រិតនៃសំវិធានធននៃការខាតបង់ដោយការ ថយចុះតម្លៃ ដូចបានបង្ហាញទាំងស្រុងនៅក្នុងកំណត់សម្គាល់លេខ ២.៣.៨។

### ២.២.៤ ការថយចុះតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មដែលមានអាយុកាលមិនកំណត់មិនត្រូវបានធ្វើរំលស់នោះទេ និងត្រូវបានវិនិច្ឆ័យលើការថយចុះតម្លៃរៀងរាល់ឆ្នាំ។ ទ្រព្យសកម្មដែលត្រូវធ្វើរំលស់ត្រូវបានពិនិត្យឡើងវិញលើការថយចុះតម្លៃនៅពេលដែលព្រឹត្តិការណ៍ ឬបម្រែបម្រួលក្នុងកាលៈទេសៈបង្ហាញថា តម្លៃចុះបញ្ជីមិនអាចស្តារមកវិញបាននោះ។ ការខាតបង់ដោយការថយចុះតម្លៃត្រូវបានទទួលស្គាល់នូវទឹកប្រាក់ដែលជាចំនួនលើសនៃតម្លៃចុះបញ្ជីរបស់ទ្រព្យសកម្មនិងតម្លៃអាចស្តារមកវិញបានរបស់វា។ តម្លៃដែលអាចស្តារមកវិញបានជាចំនួនដែលខ្ពស់ជាងគេរវាងតម្លៃទីផ្សាររបស់ទ្រព្យសកម្មដកចេញនូវចំណាយក្នុងការលក់និងតម្លៃប្រើប្រាស់។ ក្នុងការវាយតម្លៃលើការថយចុះតម្លៃទ្រព្យសកម្មត្រូវបានចាត់ជាក្រុមដែលមានកម្រិតទាបបំផុតដែលមានលំហូរសាច់ប្រាក់ដាច់ដោយឡែក (អង្គភាពបង្កើនសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ ក្រៅពីមូលនិធិពាណិជ្ជកម្មដែលមានការថយចុះតម្លៃត្រូវបានពិនិត្យឡើងវិញសម្រាប់ការ កត់បញ្ច្រាសត្រលប់វិញដែលអាចមាននៃការថយចុះតម្លៃ នាការិយបរិច្ឆេទរបាយការណ៍នីមួយៗ។

### ២.២.៥ ការថយចុះតម្លៃមូលនិធិពាណិជ្ជកម្ម

មូលនិធិពាណិជ្ជកម្មត្រូវបានត្រួតពិនិត្យលើការថយចុះតម្លៃរៀងរាល់ឆ្នាំឬញឹកញាប់ប្រសិនបើមានព្រឹត្តិការណ៍ឬបម្រែបម្រួលក្នុងកាលៈទេសៈបង្ហាញថាតម្លៃចុះបញ្ជីអាចត្រូវបានថយចុះតម្លៃ។ ការថយចុះតម្លៃត្រូវបានកំណត់សម្រាប់មូលនិធិពាណិជ្ជកម្មដោយការវាយតម្លៃដែលអាចស្តារមកវិញបាននៃអង្គភាពបង្កើនសាច់ប្រាក់ ឬក្រុមនៃអង្គភាពបង្កើនសាច់ប្រាក់ដែលទាក់ទងនឹងមូលនិធិពាណិជ្ជកម្មនោះ។ នៅពេលដែលតម្លៃអាចស្តារមកវិញបាននៃអង្គភាពបង្កើនសាច់ប្រាក់ ឬក្រុមនៃអង្គភាពបង្កើនសាច់ប្រាក់តិចជាងតម្លៃចុះបញ្ជីនៃអង្គភាពបង្កើនសាច់ប្រាក់ ឬក្រុមនៃអង្គភាពបង្កើនសាច់ប្រាក់ដែលមូលនិធិពាណិជ្ជកម្មត្រូវបានបែងចែក នោះការខាតបង់ដោយការថយចុះតម្លៃត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។ ការខាតបង់ដោយការថយចុះតម្លៃទាក់ទង នឹងមូលនិធិពាណិជ្ជកម្ម មិនអាចកត់ត្រាបញ្ច្រាសត្រលប់វិញបានទេសម្រាប់ការកើនឡើងនៅពេលក្រោយនៅក្នុងតម្លៃដែលអាចស្តារមកវិញបានរបស់វានាពេលអនាគត។ ក្រុមហ៊ុនរួម ធ្វើការវិនិច្ឆ័យលើការថយចុះតម្លៃនៃមូលនិធិពាណិជ្ជកម្មជារៀងរាល់ឆ្នាំ។

## ២.៣ សេចក្តីសង្ខេបគោលនយោបាយគណនេយ្យសំខាន់ៗ

### ២.៣.១ ការផ្លាស់ប្តូរគោលនយោបាយគណនេយ្យ

គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រនៃការគណនាត្រូវបានអនុវត្តជានិច្ចកាល ដោយ ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធដូចដែលបានអនុវត្តក្នុងការិយបរិច្ឆេទមុន។

### ២.៣.២ ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុនបុត្រសម្ព័ន្ធគឺជាអង្គភាពដែលធនាគារមានលទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងគោលនយោបាយប្រតិបត្តិការ ដើម្បីទទួលផលប្រយោជន៍ពីសកម្មភាពរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនោះ។ វត្តមាន និងឥទ្ធិពលនៃសិទ្ធិបោះឆ្នោតដែលមានសក្តានុពលដែលអាចប្រើប្រាស់ ឬប្តូរបានបច្ចុប្បន្នត្រូវបានពិចារណានៅពេលវាយតម្លៃថាធនាគារមានអំណាចបែបនឹងទៅលើអង្គភាពផ្សេងទៀត។

នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានបង្ហាញតាមថ្លៃដើមដក ការខាតបង់នៃការថយចុះតម្លៃ។ បើមានការលក់ការវិនិយោគនេះ ទឹកប្រាក់ខុសគ្នារវាងចំណូលសុទ្ធពីការលក់ និងតម្លៃចុះបញ្ជីត្រូវបានបង្ហាញនៅក្នុងរបាយការណ៍លទ្ធផល។

### ២.៣.៣ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួម

របាយការណ៍ហិរញ្ញវត្ថុរួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនាការិយបរិច្ឆេទនៃតារាងតុល្យការ។ របាយការណ៍ហិរញ្ញវត្ថុរបស់ ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានរៀបចំឡើងដូចការិយបរិច្ឆេទរបាយការណ៍របស់ធនាគារផងដែរ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានរួមបញ្ចូលចាប់ពីថ្ងៃទិញដែលជាថ្ងៃដែលធនាគារទទួលបានការគ្រប់គ្រង និងបន្តរួមបញ្ចូលរហូតដល់ថ្ងៃបញ្ចប់ការគ្រប់គ្រង។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរួមសមតុល្យផ្ទៃក្នុងប្រតិបត្តិការ និងចំណេញ ឬខាតដែលមិនច្បាស់លាស់ត្រូវបានលុបចោលទាំងអស់។ គោលនយោបាយគណនេយ្យមានលក្ខណៈតែមួយត្រូវបានអនុវត្តនៅក្នុងរបាយការណ៍ ហិរញ្ញវត្ថុរួម ចំពោះប្រតិបត្តិការ និងព្រឹត្តិការណ៍ទាំងឡាយណាស្ថិតក្នុងកាលៈទេសៈស្រដៀងគ្នា។ ការទិញក្រុមហ៊ុនបុត្រសម្ព័ន្ធត្រូវបានកត់ត្រាដោយប្រើប្រាស់វិធីសាស្ត្រទិញ។ វិធីសាស្ត្រគណនេយ្យ ទិញទាក់ទងទៅនឹងការបែងចែកថ្លៃដើមនៃការទិញទៅនឹងតម្លៃទីផ្សារនៃទ្រព្យសកម្មដែលបានទិញបំណុល និងបំណុលយថាហេតុដែលបានសន្មតនៅថ្ងៃទិញ។ ថ្លៃដើមទិញត្រូវបានវាស់វែងជាតម្លៃសរុបនៃតម្លៃទីផ្សារនាថ្ងៃដោះដូរនៃទ្រព្យសកម្មដែលបានទទួលបំណុលដែលបានកើតឡើងឬដែលបានសន្មតនិងឧបករណ៍មូលធនដែលបានចេញផ្សាយបូកថែមថ្លៃដើមផ្ទាល់ផ្សេងៗដែលពាក់ព័ន្ធនឹងការទិញ។

### ២.៣.៤ ការរួមបញ្ចូលអាជីវកម្ម

ការរួមបញ្ចូលអាជីវកម្មត្រូវបានកត់ត្រាដោយប្រើវិធីសាស្ត្រលទ្ធកម្ម។ ថ្លៃដើមនៃការទិញត្រូវបានកំណត់ស្មើនឹងតម្លៃសរុបនៃទឹកប្រាក់បង់ថ្លៃទិញ ដែលបានផ្ទេរវាស់វែងតាមតម្លៃទីផ្សារនៅថ្ងៃទិញ និងតម្លៃម្ចាស់ភាគហ៊ុនអប្បភាគ។ សម្រាប់ការរួមបញ្ចូលអាជីវកម្មនីមួយៗ ក្រុមហ៊ុនរួមជ្រើសរើសការវាស់វែងម្ចាស់ភាគហ៊ុនអប្បភាគតាមតម្លៃទីផ្សារ ឬតាមសមាមាត្រភាគហ៊ុននៃទ្រព្យសកម្មសុទ្ធដែលអាចកំណត់បានរបស់ក្រុមហ៊ុនដែលត្រូវបានទិញ។ សោហ៊ុយពាក់ព័ន្ធនឹងការទិញត្រូវបាន កត់ត្រាជាចំណាយនៅក្នុងចំណាយរដ្ឋបាល។ នៅពេលដែលក្រុមហ៊ុនរួមទិញអាជីវកម្មមួយ ក្រុមហ៊ុនរួមបានវាយតម្លៃទ្រព្យសកម្ម និងទ្រព្យអកម្មហិរញ្ញវត្ថុដែលបានសន្មត សម្រាប់ចំណាត់ថ្នាក់សមស្របនិងការចាត់តាំងដោយផ្អែកលើលក្ខខណ្ឌកិច្ចសន្យាកាលៈទេសៈសេដ្ឋកិច្ច និងលក្ខខណ្ឌពាក់ព័ន្ធនានានៅថ្ងៃទិញ។ ការវាស់វែងនេះ ក៏រួមបញ្ចូលនូវឧបករណ៍និទស្សន្ទដោយ ឡែកពីគ្នា នៅក្នុងកិច្ចសន្យាជាមួយក្រុមហ៊ុនដែលត្រូវបានទិញ។

### ២.៣.៥ មូលនិធិពាណិជ្ជកម្ម

មូលនិធិពាណិជ្ជកម្មត្រូវបានវាស់វែងដំបូងតាមថ្លៃដើមដែលជាតម្លៃលើសនៃថ្លៃទិញសរុប ធៀបនឹង ចំនួនដែលទទួលស្គាល់ចំពោះម្ចាស់ភាគហ៊ុនដែលមានសិទ្ធិគ្រប់គ្រងលើទ្រព្យសកម្មសុទ្ធដែលបានទទួលនិងទ្រព្យអកម្មដែលបានសន្មត។ ប្រសិនបើថ្លៃទិញនេះទាបជាងតម្លៃទីផ្សារនៃទ្រព្យសកម្មសុទ្ធ របស់ក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួនខុសគ្នាត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផល។ ក្រោយពីការទទួលស្គាល់ដំបូងមូលនិធិពាណិជ្ជកម្មត្រូវបានវាស់វែងតាមថ្លៃដើមដោយដកចេញនូវ ការខាតបង់ដោយការថយចុះតម្លៃបង្គរ។

### ២.៣.៦ សាច់ប្រាក់ និង សាច់ប្រាក់សមមូល

សម្រាប់គោលបំណងរៀបចំរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ សមតុល្យនៅធនាគារជាតិនៃកម្ពុជា និងធនាគារផ្សេងៗ និងការវិនិយោគរយៈពេលខ្លីផ្សេងៗទៀតដែលមានកម្រិតសន្ទនីយភាពខ្ពស់ ហើយដែលមានកាលបរិច្ឆេទដល់កាលកំណត់តិចជាង ឬស្មើនឹង៣ខែ គិតចាប់ពីថ្ងៃដាក់បញ្ញើ និងដែលអាចប្តូរមកជាសាច់ប្រាក់បាន ឆាប់រហ័ស និងមានហានិភ័យតិចតួចក្នុងការប្រែប្រួលតម្លៃ។

### ២.៣.៧ ឥណទាន និងបុរេប្រទានចំពោះអតិថិជន

ឥណទាននិងបុរេប្រទានចំពោះអតិថិជនត្រូវបានបង្ហាញក្នុងតារាងតុល្យការជាទឹកប្រាក់ដើមដោយដកចេញនូវឥណទានដែលត្រូវបានលុបចោលនិងសំវិធានធនដែលមានលើឥណទាន និង បុរេប្រទានទាំងនោះ។ ឥណទានរយៈពេលខ្លីគឺជាឥណទានដែលនឹងត្រូវទូទាត់សងមកវិញនៅក្នុងរយៈពេលមួយឆ្នាំដោយគិតចាប់ពីកាលបរិច្ឆេទដែលឥណទាននោះត្រូវបានផ្តល់អោយអតិថិជន។ ឥណទានរយៈពេលវែងគឺជាឥណទានដែលនឹងត្រូវទូទាត់សងមកវិញនៅក្នុងរយៈពេលច្រើនជាងមួយឆ្នាំដោយគិតចាប់ពីកាលបរិច្ឆេទដែលឥណទានត្រូវបានផ្តល់អោយអតិថិជន។ ការប្រាក់បង្គរដែលមិនទាន់បានទទួលប្រាក់ក្រៅពីបុរេប្រទានត្រូវបានកត់ត្រាជាទ្រព្យសកម្មផ្សេងៗ នៅក្នុងតារាងតុល្យការ។

ឥណទានត្រូវបានលុបចោល នៅពេលដែលធនាគារសង្ឃឹមយ៉ាងច្បាស់លាស់ថា ឥណទានមិន អាចប្រមូលមកវិញបាន។ ការប្រមូលបានមកវិញនៃឥណទាន និងបុរេប្រទានដែលត្រូវបានលុបចោល ឬបានធ្វើសំវិធានធននៅក្នុងការិយបរិច្ឆេទមុនៗ នឹងបន្ថយទឹកប្រាក់នៃសំវិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទាននៅក្នុងរបាយការណ៍លទ្ធផល។

ឥណទាន និងបុរេប្រទានដែលត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ សង្ស័យ ឬបាត់បង់ គឺត្រូវចាត់ទុកជា ឥណទានមិនដំណើរការ។

### ២.៣.៨ សំវិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទាន

សំវិធានធនសម្រាប់ការបាត់បង់លើឥណទាន និងបុរេប្រទានត្រូវបានធ្វើឡើងដោយអាស្រ័យទៅលើហានិភ័យជាក់លាក់នានា ដែលទាក់ទងទៅនឹងឥណទាន និងបុរេប្រទានទាំងនោះដែលត្រូវបានពិនិត្យមើលឡើងវិញ និងកំណត់យ៉ាងជាក់លាក់ថាជាឥណទានឃ្លាំមើល ក្រោមស្តង់ដារ សង្ស័យ ឬ បាត់បង់។ លើសពីនេះ សំវិធានធនទូទៅ ក៏ត្រូវបានធ្វើឡើងផងដែរសម្រាប់ឥណទាន ដែលបានចាត់ថ្នាក់ជាឥណទានធម្មតា។

សំវិធានធនត្រូវបានគណនាដោយផ្អែកទៅតាមភាគរយនៃសមតុល្យឥណទាន និងបុរេប្រទាននៅ សល់សរុបដកចេញនូវការប្រាក់ព្យួរ។

ធនាគារបានអនុវត្តតាមការធ្វើចំណាត់ថ្នាក់ និងសំវិធានធនឥណទាន ដូចដែលបានតម្រូវដោយ ធនាគារជាតិនៃកម្ពុជា តាមប្រកាសលេខ ធ៧-០៩-០៧៤ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៩។ ប្រកាសនេះតម្រូវអោយធនាគារពាណិជ្ជទាំងអស់ចាត់ថ្នាក់សំពៀតឥណទានរបស់ខ្លួនជា ៥ថ្នាក់។ កម្រិតស្របច្បាប់ចាំបាច់នៃការធ្វើសំវិធានធនទូទៅនិងជាក់លាក់ ត្រូវបានធ្វើឡើង ដោយផ្អែកលើចំណាត់ ថ្នាក់ឥណទានដូចមានបង្ហាញជូនខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | អត្រាសំវិធានធន |
|---|---|---|
| **សំវិធានធនទូទៅ** | | |
| ឥណទានធម្មតា | គ្មាន រហូតដល់តិចជាង៣០ថ្ងៃ | ១% |
| **សំវិធានធនជាក់លាក់** | | |
| ឥណទានឃ្លាំមើល | ពី ៣០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ៩០ ថ្ងៃ | ៣% |
| ឥណទានក្រោមស្តង់ដារ | ពី ៩០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង ១៨០ ថ្ងៃ | ២០% |
| ឥណទានជាប់សង្ស័យ | ពី១៨០ ថ្ងៃ ឬ ច្រើនជាង ប៉ុន្តែ តិចជាង៣៦០ ថ្ងៃ | ៥០% |
| ឥណទានបាត់បង់ | ៣៦០ថ្ងៃ ឬ ច្រើនជាង | ១០០% |

ឥណទានមិនអាចប្រមូលបានឬចំណែកឥណទានដែលចាត់ចំណាត់ថ្នាក់ជាឥណទានអាក្រក់ត្រូវបានលុបចោលបន្ទាប់ពីការពិចារណាលើតម្លៃទីផ្សារជាក់ស្តែងរបស់អចលនទ្រព្យដាក់បញ្ចាំនិងបន្ទាប់ពីការវិនិច្ឆ័យរបស់គណៈគ្រប់គ្រងធនាគារ ថាមិនមានសង្ឃឹមក្នុងការប្រមូលមកវិញបាន។

ដោយអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ក្រុមហ៊ុនបុត្រសម្ព័ន្ធ ក៏បាន ធ្វើសំវិធានធនជាក់លាក់លើឥណទានអាក្រក់ ឬសង្ស័យចំពោះឥណទានទាំងឡាយណាដែល បានបញ្ជាក់ថាជាឥណទានមិនដំណើរការដូចខាងក្រោម៖

| ចំណាត់ថ្នាក់ | ចំនួនថ្ងៃហួសកាលកំណត់ | អត្រាសំវិធានធន |
|---|---|---|
| **ឥណទានរយៈពេលខ្លី** (តិចជាង១ឆ្នាំ) | | |
| ឥណទានក្រោមស្តង់ដារ | ពី ៣០ ថ្ងៃ ឬ ច្រើនជាង | ១០% |
| ឥណទានជាប់សង្ស័យ | ពី ៦០ ថ្ងៃ ឬ ច្រើនជាង | ៣០% |
| ឥណទានបាត់បង់ | ពី៩០ ថ្ងៃ ឬ ច្រើនជាង | ១០០% |
| **ឥណទានរយៈពេលវែង** (ច្រើនជាង១ឆ្នាំ) | | |
| ឥណទានក្រោមស្តង់ដារ | ពី ៣០ ថ្ងៃ ឬ ច្រើនជាង | ១០% |
| ឥណទានជាប់សង្ស័យ | ពី ១៨០ ថ្ងៃ ឬ ច្រើនជាង | ៣០% |
| ឥណទានបាត់បង់ | ពី៣៦០ ថ្ងៃ ឬ ច្រើនជាង | ១០០% |

បន្ថែមលើសំវិធានធនជាក់លាក់កំណត់ដោយធនាគារជាតិនៃកម្ពុជាក្រុមហ៊ុនបុគ្គលក៏បានធ្វើសំវិធានធនទូទៅលើឥណទានអាក្រក់និងសង្ស័យដូចខាងក្រោម៖

- ០,២% លើឥណទានធម្មតា
- ៩០% លើឥណទានក្រោមស្តង់ដារ និង
- ៧០% លើឥណទានជាប់សង្ស័យ

សំវិធានធនត្រូវបានគណនាតាមភាគរយនៃចំនួនឥណទាននៅសល់ នៅពេលដែលឥណទានត្រូវ បានចាត់ចំណាត់ថ្នាក់ ដោយមិនរាប់បញ្ចូលការប្រាក់បង្គរ។ សំវិធានធនត្រូវបានកត់ត្រានៅក្នុងគណនីរបស់ក្រុមហ៊ុនបុគ្គលម្ចាស់ហើយនិងត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផលនៅក្នុងខែដែលឥណទាននោះត្រូវបានចាត់ចំណាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ។ ការប្រមូលមកវិញនូវឥណទានដែលបានលុបចោល និងការកត់បញ្ច្រាសគ្រលប់វិញនៃសំវិធានធន ដែលបានកត់ត្រាពីមុន ត្រូវបានបង្ហាញជាការដកចេញពីគណនីឥណទានខាតបង់នៅក្នុងរបាយការណ៍លទ្ធផល។

### ២.៣.៩ កិច្ចសន្យាឥណទានផ្សេងៗ

ក្នុងដំណើរការអាជីវកម្មធម្មតាក្រុមហ៊ុនរួមបានធ្វើកិច្ចសន្យាឥណទានផ្សេងៗរួមមានកិច្ចសន្យាផ្តល់ឥណទាន លិខិតឥណទាននិងលិខិតធានា។ គោលនយោបាយគណនេយ្យ និងវិធីសាស្ត្រសំវិធានធនគឺប្រហាក់ប្រហែលគ្នាទៅនឹងការផ្តល់ឥណទានដូចមានក្នុងកំណត់សម្គាល់ខាងលើ។ សំវិធានធនជាក់លាក់ត្រូវបានធ្វើឡើងចំពោះកិច្ចសន្យាឥណទានផ្សេងៗនៅពេលការបាត់បង់ត្រូវបានគិតថាអាចនឹងកើតមានឡើង។

### ២.៣.១០ ប្រាក់បញ្ញើ និង ប្រាក់តម្កល់នៅធនាគារផ្សេងៗ

ប្រាក់បញ្ញើ និង ប្រាក់តម្កល់នៅធនាគារផ្សេងៗកត់ត្រាជាថ្លៃដើម។

### ២.៣.១១ ប្រាក់បញ្ញើកាតព្វកិច្ច

ប្រាក់បញ្ញើកាតព្វកិច្ចសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពធនាគារត្រូវបានតម្កល់នៅធនាគារជាតិនៃកម្ពុជាអនុលោមតាមច្បាប់ស្តីពីធនាគារនិងស្ថាប័នហិរញ្ញវត្ថុ និងត្រូវបានកំណត់តាមអត្រាភាគរយ អប្បបរមានៃដើមទុន និងប្រាក់បញ្ញើរបស់អតិថិជនដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។

### ២.៣.១២ ទ្រព្យសកម្មផ្សេងៗ

ឥណទេយ្យផ្សេងៗត្រូវបានកត់ត្រាតាមតម្លៃលក់រំពឹងទុក។ ការប៉ាន់ស្មានត្រូវបានធ្វើឡើងសម្រាប់ការខាតបង់ដែលអាចកើតឡើងដោយផ្អែកលើការត្រួតពិនិត្យឡើងវិញនូវទឹកប្រាក់នៅ សល់នាកាលបរិច្ឆេទនៃតារាងតុល្យការ។

### ២.៣.១៣ ទ្រព្យ និងបរិក្ខារ

ទ្រព្យនិងបរិក្ខារត្រូវបានកត់ត្រានូវតម្លៃដើមដោយដកចេញនូវរំលស់បង្គរនិងសំវិធានធនលើការថយចុះតម្លៃ(ប្រសិនបើមាន)។ ការផ្លាស់ប្តូរអាយុកាលប្រើប្រាស់រំពឹងទុកត្រូវបានធ្វើឡើងដោយ ការផ្លាស់ប្តូររយៈពេល ឬវិធីសាស្ត្ររំលស់អោយបានសមស្រប ហើយចាត់ទុកថាជាការផ្លាស់ប្តូរ ការប៉ាន់ស្មានគណនេយ្យ។ រំលស់នៃទ្រព្យនិងបរិក្ខារត្រូវបានចាត់ទុកជាចំណាយក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្ត្ររំលស់ថយចុះលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យនីមួយៗ តាមអត្រាដូចខាងក្រោម៖

| | |
|---|---|
| សង្ហារឹម និងបរិក្ខារការិយាល័យ | ២៥% |
| យានយន្ត | ២៥% |
| ព័ត៌មានវិទ្យានិងកុំព្យូទ័រ | ៥០% |

ការកែលំអអគារ ត្រូវបានធ្វើរំលស់តាមវិធីសាស្ត្ររំលស់ថេរ ពី ៥ ទៅ ១២ឆ្នាំ។

សំណង់កំពុងសាងសង់មិនត្រូវបានធ្វើរំលស់ទេរហូតដល់ពេលដែលទ្រព្យដែលពាក់ព័ន្ធនោះត្រូវបានបញ្ចប់និងដាក់អោយប្រើប្រាស់ក្នុងប្រតិបត្តិការ។ ចំណាយបន្តបន្ទាប់ពាក់ពន្ធ័នឹងទ្រព្យនិងបរិក្ខារដែលត្រូវបានទទួលស្គាល់រួចទៅហើយគឺត្រូវបូកបន្ថែមទៅលើតម្លៃចុះបញ្ជីរបស់ទ្រព្យនោះនៅពេលដែលគេរំពឹងថាធនាគារនឹងអាចទទួលបានអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតលើសពីស្តង់ដារដែលបានវាយតម្លៃដំបូងលើទ្រព្យនិងបរិក្ខារនោះ។ ចំណាយបន្តបន្ទាប់ផ្សេងៗក្រៅពីនេះ ត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុង ការិយបរិច្ឆេទដែលកើតឡើង។

ចំណេញ ឬខាតលើការផុតអាយុប្រើប្រាស់ ឬលក់ចេញនៃទ្រព្យនិងបរិក្ខារមួយ គឺត្រូវបានកំណត់ជាចំនួនខុសគ្នារវាងតម្លៃដែលទទួលបានពីការលក់សុទ្ធ និងតម្លៃចុះបញ្ជីរបស់ទ្រព្យនោះ ហើយត្រូវ បានទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលនៅថ្ងៃដែលទ្រព្យនោះផុតអាយុប្រើប្រាស់ ឬលក់ ចេញ។

ទ្រព្យ និងបរិក្ខារដែលត្រូវបានរំលស់អស់ ត្រូវបានរក្សាទុកក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់ ពេលលក់ចេញ ឬលុបចោល។

### ២.៣.១៤ កម្មវិធីកុំព្យូទ័រ

កម្មវិធីកុំព្យូទ័រ ត្រូវបានកត់ត្រានូវតម្លៃដើមដកចេញនូវរំលស់បង្គរ និងត្រូវបានធ្វើរំលស់ដោយប្រើវិធីសាស្ត្រថយចុះតាមអត្រា៥០%ក្នុងមួយឆ្នាំ។

### ២.៣.១៥ ទ្រព្យអកម្ម

ប្រាក់បញ្ញើពីអតិថិជនប្រាក់បញ្ញើនិងការដាក់ប្រាក់របស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗត្រូវបានបង្ហាញតាមតម្លៃជាក់ស្តែងនៅពេលដាក់ផ្ញើ។ ទ្រព្យអកម្មផ្សេងៗត្រូវបានបង្ហាញតាមថ្លៃដើមដែលជាតម្លៃទីផ្សារនៃថ្លៃទិញត្រូវបង់រំពឹងទុកដែលនឹងត្រូវទូទាត់ពេលអនាគតសម្រាប់ទំនិញ និងសេវាដែលបានទទួល។

### ២.៣.១៦ ប្រាក់កម្ចី

ប្រាក់កម្ចី ត្រូវបានបង្ហាញជាចំនួនទឹកប្រាក់ដើមនៅសល់។កម្រៃដែលបានបង់សម្រាប់ការទទួលបានប្រាក់កម្ចីត្រូវបានធ្វើមូលធនកម្មនិងត្រូវបានធ្វើរំលស់លើរយៈពេលឆ្នាំនៃកម្ចី ដោយប្រើវិធីសាស្ត្ររំលស់ថេរ។

### ២.៣.១៧ បំណុលបន្ទាប់បន្សំ

បំណុលបន្ទាប់បន្សំត្រូវបានទទួលស្គាល់ដំបូងតាមថ្លៃដើម និងត្រូវបានបង្ហាញតាមចំនួនប្រាក់ដើមនៅសល់នៅពេលក្រោយ។ បំណុលបន្ទាប់បន្សំត្រូវបានកត់ត្រាជាទ្រព្យអកម្មរបស់ក្រុមហ៊ុនរួមហើយត្រូវបានរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធរបស់ក្រុមហ៊ុនរួមដោយអនុលោមតាមគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។

### ២.៣.១៨ សំវិធានធនលើទ្រព្យអកម្ម

សំវិធានធនលើទ្រព្យអកម្មត្រូវបានកត់ត្រាល្គឹកណាក្រុមហ៊ុនរួមមានកាតព្វកិច្ចនាពេលបច្ចុប្បន្នដែលជាលទ្ធផលនៃព្រឹត្តិការណ៍អតីតកាលនិងដែលវាប្រហែលជានឹងអាចត្រូវមានលំហូរចេញនៃធនធានដែលមានអត្ថប្រយោជន៍សេដ្ឋកិច្ចដើម្បីទូទាត់កាតព្វកិច្ចនោះហើយទឹកប្រាក់នៃកាតព្វកិច្ចនោះអាចធ្វើការប៉ាន់ប្រមាណដោយគួរអោយជឿជាក់បាន។

សំវិធានធនត្រូវបានត្រួតពិនិត្យឡើងវិញរៀងរាល់កាលបរិច្ឆេទតុល្យការនីមួយៗនិង ធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងតម្លៃប៉ាន់ស្មានសមស្របបំផុតនាពេលបច្ចុប្បន្ន។ ប្រសិនបើការប៉ះពាល់នៃតម្លៃសាច់ប្រាក់តាមពេលវេលាមានភាពជាសារវន្តទឹកប្រាក់សំវិធានធនគឺជាតម្លៃទឹកប្រាក់បច្ចុប្បន្ននៃការចំណាយដែលរំពឹងទុកដើម្បីទូទាត់កាតព្វកិច្ចនោះ។

### ២.៣.១៩ មូលនិធិសន្និធិ័យ និងសោធននិវត្តន៍

#### មូលនិធិសោធននិវត្តន៍

ធនាគារផ្តល់អត្ថប្រយោជន៍សោធននិវត្តន៍២ប្រភេទសម្រាប់និយោជិតរបស់ខ្លួន ដូចខាងក្រោម៖

i. វិភាគទានប្រចាំខែពីនិយោជិតនិងធនាគារតាមអត្រា ៥% នៃប្រាក់បៀវត្សរ៍ដុល៖
ធនាគារផ្តល់ការប្រាក់លើសមតុល្យបង្គរនៃគណនីមូលនិធិសោធននិវត្តន៍ តាមអត្រាការប្រាក់ ១.៥% ក្នុង ១ឆ្នាំ។

ក្នុងករណីនិយោជិតបានបំពេញការងារអោយធនាគារបានរយៈពេលជាប់គ្នា៣ឆ្នាំឬលើសពីនេះនិយោជិតនឹងទទួលបាននូវទឹកប្រាក់សោធនិវត្តន៍របស់ខ្លួនទាំងអស់នៅពេលដែលនិយោជិតបញ្ចប់កិច្ចសន្យាការងាររបស់ខ្លួនជាមួយធនាគារទោះក្នុងហេតុផលណាក៏ដោយ និង គ្រប់ពេលវេលាលើកលែងតែបានប្រព្រឹត្តខុសធ្ងន់ធ្ងរ។

ii. បន្ថែមលើមូលនិធិសោធននិវត្តន៍ ៥% ខាងលើ ធនាគារក៏ផ្តល់ជូននូវមូលនិធិសោធននិវត្តន៍ មួយទៀត ដែលនិយោជិតនឹងទទួលបានទឹកប្រាក់ពាក់កណ្តាលនៃប្រាក់បៀវត្សរ៍ប្រចាំខែចុងក្រោយ របស់ខ្លួនគុណនឹងចំនួនឆ្នាំដែលបានបំពេញការងារអោយធនាគារ៖ មូលនិធិសោធននិវត្តន៍នេះធ្វើឡើងដើម្បីបង្ហាញពីរង្វាន់លើកទឹកចិត្តចំពោះភាពយូរអង្វែងនៃរយៈពេលបំរើការងាររបស់និយោជិតហើយនិយោជិតនឹងទទួលបាននូវទឹកប្រាក់ក្នុងមូលនិធិនេះទាំងអស់នៅពេលបញ្ចប់កិច្ចសន្យាការងាររបស់ខ្លួនជាមួយធនាគារទោះក្នុងហេតុផលណាក៏ដោយ និងគ្រប់ពេលវេលាលើកលែងតែបានប្រព្រឹត្តខុសធ្ងន់ធ្ងរ ប្រសិនបើនិយោជិត នោះបានបំពេញការងារអោយធនាគារបានរយៈពេលជាប់គ្នា ៥ ឆ្នាំ ឬលើសពីនេះ។

#### មូលនិធិសន្និធិ័យ

ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្តល់ឲ្យនិយោជិតរបស់ខ្លួននូវអត្ថប្រយោជន៍ក្រោមគោលនយោបាយមូលនិធិសន្និធិ័យ។ និយោជិតដែលបញ្ចប់ឆ្នាំសាកល្បងមានជម្រើសក្នុងការចូលរួមក្នុងមូលនិធិសន្និធិ័យ។ មូលនិធិនេះមានប្រភពដូចខាងក្រោម៖

- និយោជិតអាចចូលវិភាគទានរហូតដល់ ៥% នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់ពួកគេ ហើយក្រុមហ៊ុនបុត្រសម្ព័ន្ធចូលវិភាគទានពីរដងលើចំនួននេះ។
- ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្តល់ការប្រាក់លើសមតុល្យបង្គរនៃមូលនិធិសន្និធិ័យនេះតាមអត្រាការប្រាក់៦,៥%ក្នុងមួយឆ្នាំ។ វិភាគទាននេះត្រូវបានទទួលស្គាល់ជាចំណាយនៅក្នុងរបាយការណ៍លទ្ធផល។

មូលនិធិសន្និធិ័យនឹងបើកអោយនិយោជិត (និយោជិតដែលបានចូលវិភាគទាន) នៅពេលដែលពួកគេចូលនិវត្តន៍លាឈប់ ឬបញ្ចប់កិច្ចសន្យាការងារ។

វិភាគទានរបស់និយោជិត និងការប្រាក់ ត្រូវបានបើកអោយទាំងអស់ ប៉ុន្តែវិភាគទានរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានបើកឲ្យតាម លក្ខខណ្ឌដូចខាងក្រោម៖

| ចំនួនឆ្នាំបំរើការងារ ( * )<br>ភាគរយនៃវិភាគទានរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ | |
|---|---|
| ស្មើ ឬ តិចជាងមួយឆ្នាំ | - |
| ច្រើនជាង១ឆ្នាំ | ២០% |
| ច្រើនជាង២ឆ្នាំ | ៤០% |
| ច្រើនជាង៣ឆ្នាំ | ៦០% |
| ច្រើនជាង៤ឆ្នាំ | ៨០% |
| ច្រើនជាង៥ឆ្នាំ | ១០០% |

( * )ចំនួនឆ្នាំបំរើការងារមិនរាប់បញ្ចូលឆ្នាំសាកល្បងទេ។

និយោជិតដែលត្រូវបានបញ្ឈប់ដោយសារការប្រព្រឹត្តខុសធ្ងន់ធ្ងរនោះ គឺមានសិទ្ធិទទួលបានត្រឹមតែវិភាគទានរបស់ខ្លួន និងការប្រាក់ប៉ុណ្ណោះដោយមិនគិតពីរយៈពេលដែលនិយោជិត បានធ្វើការអោយក្រុមហ៊ុនបុត្រសម្ព័ន្ធនោះទេ។

### ២.៣.២០ ពន្ធលើប្រាក់ចំណេញក្នុងគ្រា និងពន្ធពន្យារ

#### ពន្ធលើប្រាក់ចំណេញក្នុងគ្រា

ទ្រព្យសកម្ម និងបំណុលពន្ធក្នុងគ្រាសម្រាប់ការិយបច្ឆេទបច្ចុប្បន្ន និងការិយបច្ឆេទមុនត្រូវបានវាស់វែងជាទឹកប្រាក់ដែលត្រូវបានរំពឹងទុកថាត្រូវបានប្រមូលបានមកវិញពីឬត្រូវបង់អោយទៅអាជ្ញាធរពន្ធដារ។ អត្រាពន្ធ និងច្បាប់ពន្ធដែលបានប្រើដើម្បីគណនាទឹកប្រាក់ពន្ធទាំងនេះគឺជាអត្រានិងច្បាប់ពន្ធដែលមានសុពលភាពនៅកាលបរិច្ឆេទតារាងតុល្យការ។

#### ពន្ធលើប្រាក់ចំណេញពន្ធពន្យារ

ពន្ធលើប្រាក់ចំណេញពន្យារត្រូវបានគណនាដោយប្រើវិធីសាស្រ្តទ្រព្យអកម្មតារាងតុល្យការទៅលើចំនួនខុសគ្នាបណ្តោះអាសន្ននាការិយបរិច្ឆេទតារាងតុល្យការរវាងមូលដ្ឋានពន្ធ នៃទ្រព្យសកម្ម និងទ្រព្យអកម្ម និងតម្លៃចុះបញ្ជីរបស់ពន្ធពន្យារនោះសម្រាប់គោលបំណងរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារទ្រព្យអកម្មត្រូវបានទទួលស្គាល់សម្រាប់ចំនួនខុសគ្នាបណ្តោះអាសន្នជាប់ពន្ធទាំងអស់លើកលែងតែពន្ធពន្យារទ្រព្យអកម្មកើតឡើងពីការទទួលស្គាល់នៃទ្រព្យសកម្ម ឬទ្រព្យអកម្មដំបូងនៅក្នុងប្រតិបត្តិការមួយដែលនៅពេលនោះមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ និងប្រាក់ចំណេញ ឬខាតជាប់ពន្ធ។ ពន្ធពន្យារទ្រព្យសកម្មត្រូវបានទទួលស្គាល់សម្រាប់ចំនួនខុសគ្នាបណ្តោះអាសន្នដែលអាចកាត់កងទាំងអស់ត្រឹមកម្រិតដែលប្រាក់ចំណេញជាប់ពន្ធអនាគតប្រហែលជា នឹងអាចកើតមានដើម្បីអោយភាពខុសគ្នានេះអាចប្រើប្រាស់បាន លើកលែងតែពន្ធពន្យារទ្រព្យសកម្មកើតឡើងពីការទទួលស្គាល់នៃទ្រព្យសកម្ម ឬទ្រព្យអកម្មដំបូងនៅក្នុង ប្រតិបត្តិការមួយដែលនៅពេលនោះមិនប៉ះពាល់ដល់ប្រាក់ចំណេញគណនេយ្យ និងប្រាក់ចំណេញ ឬ ខាតជាប់ពន្ធ។ តម្លៃចុះបញ្ជីនៃពន្ធពន្យារទ្រព្យសកម្មត្រូវបានពិនិត្យឡើងវិញនៅការិយបរិច្ឆេទតារាងតុល្យការនីមួយៗ ហើយនិងត្រូវបានកាត់បន្ថយមកត្រឹមកម្រិតមួយដែលប្រាក់ចំណេញជាប់ពន្ធគ្រប់គ្រាន់ប្រហែលជាមិនកើតមានដើម្បីអាចអោយទ្រព្យសកម្មទាំងអស់ ឬមួយផ្នែកប្រមូលបានមកវិញ។ ពន្ធពន្យារទ្រព្យសកម្មដែលមិនត្រូវបានទទួលស្គាល់នោះគឺត្រូវបានវាយតម្លៃឡើងវិញនាការិយបរិច្ឆេទតារាងតុល្យការនីមួយៗ ហើយត្រូវបានទទួលស្គាល់ត្រឹមកម្រិតមួយដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធអនាគតនឹងធ្វើអោយពន្ធពន្យារទ្រព្យសកម្មនោះអាចប្រមូលបានមកវិញ។

### ២.៣.២១ ការទទួលស្គាល់ចំណូល ឬ ចំណាយ

ចំណូលត្រូវបានទទួលស្គាល់ត្រឹមកម្រិតដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ច នឹងហូរចូលមក ក្នុងក្រុមហ៊ុនរួម ហើយចំណូលនេះអាចវាស់វែងគួរអោយជឿជាក់បាន។

(១) ចំណូលការប្រាក់

ចំណូលការប្រាក់ត្រូវបានទទួលស្គាល់លើមូលដ្ឋានគណនេយ្យបង្គរ។

ចំណូលការប្រាក់លើឥណទានវិបារូបន៍ ឥណទានតាមកាលកំណត់ និងឥណទានផ្សេងៗ ត្រូវបានទទួលស្គាល់ប្រចាំថ្ងៃ ឬប្រចាំខែរហូតដល់ការិយបរិច្ឆេទដែលត្រូវបញ្ចប់។ នៅពេលដែលឥណទានមួយក្លាយជាឥណទានមិនដំណើរការការទទួលស្គាល់ការប្រាក់ត្រូវព្យួរទុករហូតដល់ឥណទាននោះត្រូវបានសងតាមមូលដ្ឋានសាច់ប្រាក់។ ឥណទានត្រូវបានចាត់ទុកជា ឥណទាន មិនដំណើរការនៅពេលដែលសំណងមានការយឺតយ៉ាវចាប់ពី ៩០ថ្ងៃ ឬលើសពីនេះ។

(២) ចំណូលពីសកម្មភាពផ្សេងៗរបស់ក្រុមហ៊ុនរួម៖

ចំណូលពីសកម្មភាពផ្សេងៗរបស់ក្រុមហ៊ុនរួម ត្រូវបង្គរដោយប្រើមូលដ្ឋានដូចខាងក្រោម៖

(ក) កម្រៃពីការរៀបចំឥណទាន និងកម្រៃជើងសារដែលបានពីសេវាកម្មផ្សេងៗ និងការផ្តល់មធ្យោបាយនានាដល់អតិថិជនត្រូវទទួលស្គាល់នៅពេលប្រតិបត្តិការទាំងនេះកើតឡើង

(ខ) កម្រៃពីកិច្ចសន្យា និងកម្រៃពីការធានាដែលបានពីសេវាកម្មផ្សេងៗ និងការផ្តល់មធ្យោបាយនានាដល់អតិថិជនត្រូវទទួលស្គាល់ជាចំណូលតាមពេលដែលសេវាកម្ម និង មធ្យោបាយនានានោះត្រូវបានផ្តល់អោយ

(គ) ឈ្នួលលើសេវា និងកម្រៃលើប្រតិបត្តិការត្រូវបានទទួលស្គាល់ នៅពេលសេវាកម្មត្រូវ បានបំពេញ។

(៣) ចំណាយការប្រាក់

ចំណាយការប្រាក់លើប្រាក់បញ្ញើរបស់អតិថិជន និងគណនីសម្រាប់ទូទាត់របស់ធនាគារផ្សេងៗ និងលើប្រាក់កម្ចីត្រូវបានទទួលស្គាល់តាមមូលដ្ឋានបង្គរ។

### ២.៣.២២ ភតិសន្យាប្រតិបត្តិការ

ការទូទាត់ភតិសន្យាប្រតិបត្តិការ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលតាមវិធីសាស្រ្ត ថេរទៅតាមអាយុកាលនៃការជួល។

### ២.៣.២៣ ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

ភាគីដែលចាត់ទុកថាជាសម្ព័ន្ធញាតិប្រសិនបើក្រុមហ៊ុនរួមមានលទ្ធភាពដោយផ្ទាល់ឬដោយប្រយោលដើម្បីគ្រប់គ្រងភាគីផ្សេងៗ ឬក៏មានឥទ្ធិពលខ្លាំងទៅលើភាគីទាំងនោះក្នុងការធ្វើសេចក្តីសំរេចលើប្រតិបត្តិការ និងហិរញ្ញវត្ថុឬផ្ទុយមកវិញ ឬនៅពេលដែលក្រុមហ៊ុនរួម និងភាគីនោះស្ថិតនៅក្រោមការគ្រប់គ្រងរួម ឬក៏មានឥទ្ធិពលខ្លាំង។ សម្ព័ន្ធញាតិអាចជារូបវន្តបុគ្គល ឬជានីតិបុគ្គល និងរួមបញ្ចូលទាំងសាច់ញាតិជិតស្និទ្ធិក្នុងសមាជិកគ្រួសារនៃរូបវន្តបុគ្គល ដែលចាត់ទុកថាជា សម្ព័ន្ធញាតិ។

សម្ព័ន្ធញាតិត្រូវបានកំណត់ក្នុងមាត្រា ៤៩ និង ៥០ នៃច្បាប់ស្តីពីធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុរួមមានដូចខាងក្រោមៈ

(ក) បុគ្គលទាំងឡាយណា ដែលកាន់កាប់ដោយផ្ទាល់ ឬដោយប្រយោលនូវដប់ភាគរយ (១០%) យ៉ាងតិចនៃដើមទុន ឬសិទ្ធិបោះឆ្នោត។

(ខ) ក្រុមហ៊ុនណា ដែលក្រុមហ៊ុនរួមកាន់កាប់នៅក្នុងដើមទុនដោយផ្ទាល់ ឬដោយប្រយោលនូវភាគកម្មយ៉ាងតិចស្មើនឹងដប់ភាគរយ (១០%)ឬតំណាងយ៉ាងតិចដប់ភាគរយ (១០%) នៃសិទ្ធិ បោះឆ្នោត។

(គ) បុគ្គលណាដែលចូលរួមក្នុងការអភិបាល ការដឹកនាំ ការកាន់កាប់ ឬការត្រួតពិនិត្យផ្ទៃក្នុង។ និង

(ឃ) សវនករឯករាជ្យ។ ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិនិងសមតុល្យគណនីដែលពាក់ព័ន្ធត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ២៦។

### ២.៣.២៤ ប្រតិបត្តិការជារូបិយប័ណ្ណបរទេស

ក្រុមហ៊ុនរួមរក្សាប្រព័ន្ធគណនេយ្យនិងកត់ត្រារាល់ប្រតិបត្តិការរបស់ខ្លួនជារូបិយប័ណ្ណដើម។ ទ្រព្យសកម្មនិងទ្រព្យអកម្មរូបិយវត្ថុដែលកត់ត្រាជារូបិយប័ណ្ណបរទេសក្រៅពីដុល្លារអាមេរិកនាចុងការិយបរិច្ឆេទត្រូវបានប្រែសម្រួលទៅជាដុល្លារអាមេរិកតាមអត្រាប្តូរប្រាក់ដែលបានកំណត់នៅការិយបរិច្ឆេទតារាងតុល្យការ។ ចំណូល និងចំណាយដែលកើតឡើងជារូបិយប័ណ្ណបរទេស និង ប្រាក់រៀលត្រូវបានប្តូរមកជាដុល្លារអាមេរិកនៅចុងខែដោយប្រើអត្រាប្តូរប្រាក់មធ្យមជាជាងអត្រាប្តូរប្រាក់ដែលបានកំណត់នាកាលបរិច្ឆេទនៃប្រតិបត្តិការ។

លំអៀងពីការប្តូររូបិយប័ណ្ណបរទេសដែលកើតឡើងពីការប្រែសម្រួលទ្រព្យសកម្មនិងទ្រព្យអកម្មរូបិយវត្ថុនៅការិយបរិច្ឆេទតារាងតុល្យការត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

សម្រាប់អត្រាប្តូរប្រាក់នៃរូបិយប័ណ្ណបរទេស និងដុល្លារអាមេរិកធៀបនឹងប្រាក់រៀល នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ សូមមើលកំណត់សម្គាល់លេខ ៣១ ។

### ២.៣.២៥ ទ្រព្យសកម្មដែលស្ថិតក្រោមកិច្ចសន្យាធានា

ទ្រព្យសកម្មដែលបានរក្សាទុកនៅក្នុងបន្ទុកឬក្នុងសមាសភាពជាទ្រព្យស្ថិតក្រោមកិច្ចសន្យាធានាគឺមិនត្រូវបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុទេពីព្រោះទ្រព្យទាំងអស់នេះមិនមែនជាទ្រព្យសកម្មរបស់ក្រុមហ៊ុនរួមឡើយ។

### ២.៣.២៦ ការកាត់ខ្ទង់ចំនួនទឹកប្រាក់

ចំនួនទឹកប្រាក់ដុល្លារអាមេរិកក្នុងរបាយការណ៍ហិរញ្ញវត្ថុត្រូវបានកាត់ខ្ទង់ដើម្បីអោយជៀកបំផុតទៅនឹងចំនួនទឹកប្រាក់ជាដុល្លារអាមេរិកនិងចំនួនទឹកប្រាក់រៀលជាខ្ទង់ពាន់រៀលលុះត្រាតែមានការបញ្ជាក់ផ្សេងក្រៅពីនេះ។

## ៣. សាច់ប្រាក់

សាច់ប្រាក់របស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ដុល្លារអាមេរិក | ១៣.៣០២.៩៦១ | ៥៣.៨៧៦.៩៩២ | ៧.៨៥៥.៤២១ | ៣២.០០៦.៧៦៦ | ៣.៣៩៧.០៥៨ | ១៣.៧៥៨.០៨៥ | ២.៩៨២.៧២២ | ១២.១៥៤.៥៩២ |
| រូបិយប័ណ្ណបរទេស | ៤.៣១០.៣៤៨ | ១៧.៤៥៦.៩០៩ | ២.៣៥៥.៩៦៣ | ៩.៦០០.៥៤៩ | ១៦៦.១១៧ | ៦៧២.៧៧៤ | ២៥៧.៩៣១ | ១.០៥១.០៦៩ |
| | **១៧.៦១៣.៣០៩** | **៧១.៣៣៣.៩០១** | **១០.២១០.៣៨៤** | **៤១.៦០៧.៣១៥** | **៣.៥៦៣.១៧៥** | **១៤.៤៣០.៨៥៩** | **៣.២៤០.៦៥៣** | **១៣.២០៥.៦៦១** |

សម្រាប់គោលបំណងរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរបស់ក្រុមហ៊ុនរួម និងធនាគាររួមមាន៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| សាច់ប្រាក់ក្នុងដៃ | ១៧.៦១៣.៣០៩ | ៧១.៣៣៣.៩០១ | ១០.២១០.៣៨៤ | ៤១.៦០៧.៣១៥ | ៣.៥៦៣.១៧៥ | ១៤.៤៣០.៨៥៩ | ៣.២៤០.៦៥៣ | ១៣.២០៥.៦៦១ |
| សមតុល្យនៅធនាគារជាតិនៃកម្ពុជា | | | | | | | | |
| គណនីចរន្ត | ២០.១៣២.១៤៦ | ៨១.៥៣៥.១៩២ | ៣៤.៤៩៦.៣៧៥ | ១៤០.៥៧២.៧២៨ | ១៤.៣៤៦.៤៥៦ | ៥៨.១០៣.១៤៧ | ២៣.២១១.៩១៣ | ៩៤.៥៨៨.៥៤៥ |
| គណនីបញ្ញើមានកាលកំណត់* | ១.៨០០.០០០ | ៧.២៩០.០០០ | ១២.៥០០.០០០ | ៥០.៩៣៧.៥០០ | ១.៨០០.០០០ | ៧.២៩០.០០០ | ១២.៥០០.០០០ | ៥០.៩៣៧.៥០០ |
| សមតុល្យជាមួយធនាគារផ្សេងៗ | | | | | | | | |
| គណនីចរន្ត | ១៦.០៨៣.៩៥០ | ៦៥.១៣៩.៩៩៨ | ១៥.៨៦៦.០៧៣ | ៦៤.៦៥៤.២៤៧ | ៩.១៧០.៤៨៦ | ៣៧.១៤០.៥០៩ | ៩.៧០៧.១៧៦ | ៣៩.៥៥៦.៧៤២ |
| សមតុល្យនៅធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | | | | | | | | |
| គណនីបញ្ញើមានកាលកំណត់* | ២.១៣៩.៧៧៨ | ៨.៦៦៦.១០១ | ៤.៥៦៣.០៦៣ | ១៨.៥៩៤.៨៨២ | ២.១៣៩.៧៧៨ | ៨.៦៦៦.១០១ | ៤.៥៦៣.០៦៣ | ១៨.៥៩៤.៨៨២ |
| | **៥៧.៧៦៩.១៨៣** | **២៣៣.៩៦៥.១៩២** | **៧៧.៦៣៥.៨៩៥** | **៣១៦.៣៦៦.២៧២** | **៣១.០១៩.៩០៥** | **១២៥.៦៣០.៦១៦** | **៥៣.២២២.៨០៥** | **២១៦.៨៨២.៩៣០** |

(*) គណនីបញ្ញើមានកាលកំណត់ដែលមានកាលវសានបីខែឬតិចជាង។

## ៤. សមតុល្យនៅធនាគារជាតិនៃកម្ពុជា

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| គណនីចរន្ត | ២០.១៣២.១៤៦ | ៨១.៥៣៥.១៩២ | ៣៤.៤៩៦.៣៧៥ | ១៤០.៥៧២.៧២៨ | ១៤.៣៤៦.៤៥៦ | ៥៨.១០៣.១៤៧ | ២៣.២១១.៩១៣ | ៩៤.៥៨៨.៥៤៥ |
| គណនីបញ្ញើមានកាលកំណត់ | ១.៨០០.០០០ | ៧.២៩០.០០០ | ១២.៥០០.០០០ | ៥០.៩៣៧.៥០០ | ១.៨០០.០០០ | ៧.២៩០.០០០ | ១២.៥០០.០០០ | ៥០.៩៣៧.៥០០ |
| ប្រាក់តម្កល់ធានាលើដើមទុន | ៩.២២០.១០៦ | ៣៧.៣៤១.៤២៩ | ៩.២២០.១០៦ | ៣៧.៥៧១.៩៣២ | ៧.៤០០.០០០ | ២៩.៩៧០.០០០ | ៧.៤០០.០០០ | ៣០.១៥៥.០០០ |
| ប្រាក់បម្រុងកាតព្វកិច្ច | ៣៤.៧០០.៥៩៩ | ១៤០.៥៣៧.៤២៦ | ២៦.៧៣២.២៤៧ | ១០៨.៩៣៣.៩០៧ | ១៣.៥២៤.៦៩២ | ៥៤.៧៧៥.០០២ | ១៣.៥២៤.៥៤០ | ៥៥.១១២.៥០១ |
| | **៦៥.៨៥២.៨៥១** | **២៦៦.៧០៤.០៤៧** | **៨២.៩៤៨.៧២៨** | **៣៣៨.០១៦.០៦៧** | **៣៧.០៧១.១៤៨** | **១៥០.១៣៨.១៤៩** | **៥៦.៦៣៦.៤៥៣** | **២៣០.៧៩៣.៥៤៦** |

**ប្រាក់តម្កល់ធានាលើដើមទុន**

យោងតាមប្រកាសដែលពាក់ព័ន្ធរបស់ធនាគារជាតិនៃកម្ពុជា ធនាគារ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុត្រូវបានតម្រូវអោយតម្កល់ប្រាក់បញ្ញើដើមទុនកាតព្វកិច្ចចំនួន ១០% ភាគរយនៃដើមទុនចុះបញ្ជី នៅធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់នេះ គឺមិនអាចប្រើប្រាស់ក្នុងប្រតិបត្តិការប្រចាំថ្ងៃបានឡើយ ប៉ុន្តែធនាគារ ឬ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអាចដកយកវិញបាននៅពេលដែលធនាគារ ឬគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ម័គ្រចិត្តឈប់ធ្វើប្រតិបត្តិការអាជីវកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ធនាគារបានដាក់ប្រាក់តម្កល់ធានាលើដើមទុនបន្ថែមទៀត ដែលទាក់ទងក្នុងការកើនឡើងនៃដើមទុនរបស់ខ្លួន នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៦។

**ប្រាក់បម្រុងកាតព្វកិច្ច**

អនុលោមតាមប្រកាសរបស់ធនាគារជាតិនៃកម្ពុជា លេខ ធ៧-០១២-១៤០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១២ ធនាគារត្រូវបានតម្រូវអោយរក្សាសាច់ប្រាក់បម្រុងដាក់លាក់នៅធនាគារជាតិនៃកម្ពុជាក្នុងទំរង់ជាប្រាក់បញ្ញើកាតព្វកិច្ច ដោយគណនាតាមអត្រា ៨% នៃប្រាក់បញ្ញើរបស់អតិថិជន និងកម្ចីជាប្រាក់រៀល និង ១២,៥% នៃប្រាក់បញ្ញើរបស់អតិថិជន និងកម្ចីជារូបិយប័ណ្ណបរទេស។

ប្រាក់បម្រុងកាតព្វកិច្ចរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាប្រាក់បម្រុងកាតព្វកិច្ចអប្បបរមាដែលត្រូវបាន គណនាតាមអត្រា ៨% នៃប្រាក់បញ្ញើពីអតិថិជន ដែលត្រូវបានតម្រូវដោយប្រកាសលេខ ធ៧-០៧-១៦៣ សម្រាប់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ។ ប្រាក់បម្រុងកាតព្វកិច្ចចំពោះ ប្រាក់បញ្ញើពីអតិថិជនមានការប្រែប្រួល អាស្រ័យទៅលើកម្រិតនៃប្រាក់បញ្ញើរបស់អតិថិជន។

អត្រាការប្រាក់

អត្រាការប្រាក់ប្រចាំឆ្នាំ លើសមតុល្យនៅធនាគារជាតិនៃកម្ពុជាមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | ធនាគារ | |
|---|---|---|---|---|
| | ២០១៥ | ២០១៤ | ២០១៥ | ២០១៤ |
| គណនីចរន្ត | 0% | 0% | 0% | 0% |
| ប្រាក់តម្កល់ធានាលើដើមទុន | 0,១១% | 0,0៨% | 0,១១% | 0,0៨% |
| ប្រាក់បម្រុងកាតព្វកិច្ច | 0,0៨% | 0,0៨% | 0,0៨% | 0,0៨% |

### ៥. សមតុល្យនៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក

សមតុល្យនៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| គណនីចរន្ត | | | | | | | | |
| ជាមួយធនាគារក្នុងស្រុក | ៦.០៣៩.៧៨២ | ២៤.៤៦១.១១៧ | ៧.៩៧៤.៩៦៨ | ៣២.៤៩៧.៩៩៥ | ៣.៧១៣.៧៥០ | ១៥.០៤០.៦៨៧ | ៤.២១៣.០២៣ | ១៧.១៦៨.០៦៩ |
| ជាមួយធនាគារនៅបរទេស | ៤.៥៦២.២៧១ | ១៨.៤៧៧.១៩៨ | ៤.៤៦១.០៤០ | ១៨.១៧៨.៧៣៨ | ៤.៥៦២.២៧១ | ១៨.៤៧៧.១៩៨ | ៤.៤៦១.០៤០ | ១៨.១៧៨.៧៣៨ |
| គណនីសន្សំ | | | | | | | | |
| ជាមួយធនាគារក្នុងស្រុក | ៤.៥៨៧.៤២២ | ១៨.៥៧៩.០៥៩ | ២.៣៩៦.៩៥២ | ៩.៧៦៧.៥៧៩ | - | - | - | - |
| ជាមួយគ្រឹះស្ថានមីក្រូ ហិរញ្ញវត្ថុក្នុងស្រុក | ៨៩៤.៤៧៥ | ៣.៦២២.៦២៤ | ១.០៣៣.១១៣ | ៤.២០៩.៩៣៥ | ៨៩៤.៤៧៥ | ៣.៦២២.៦២៤ | ១.០៣៣.១១៣ | ៤.២០៩.៩៣៥ |
| | **១៦.០៨៣.៩៥០** | **៦៥.១៣៩.៩៩៨** | **១៥.៨៦៦.០៧៣** | **៦៤.៦៥៤.២៤៧** | **៩.១៧០.៤៩៦** | **៣៧.១៤០.៥០៩** | **៩.៧០៧.១៧៦** | **៣៩.៥៥៦.៧៤២** |

គណនីចរន្តជាមួយធនាគារនៅបរទេសពុំមានការប្រាក់នោះទេ ឯគណនីចរន្តជាមួយធនាគារនៅក្នុងស្រុកទទួលបានការប្រាក់ ០,០៥% ក្នុងមួយឆ្នាំ (ឆ្នាំ២០១៤៖ ០,០៥% ក្នុងមួយឆ្នាំ)។

គណនីសន្សំទទួលបានការប្រាក់ ០,៥០% ដល់ ១,២០% ក្នុងមួយឆ្នាំ (ឆ្នាំ ២០១៤ ៣,៧៥%)។

### ៦. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក

ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| បញ្ញើមានកាលកំណត់នៅធនាគារផ្សេងៗ | ៤.១០០.០០០ | ១៦.៦០៥.០០០ | ១៤.០០០.០០០ | ៥៧.០៥០.០០០ | ៤.១០០.០០០ | ១៦.៦០៥.០០០ | ១៤.០០០.០០០ | ៥៧.០៥០.០០០ |
| បញ្ញើមានកាលកំណត់នៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក | ៥.៤៨៩.៧៧៨ | ២២.២៣៣.៦០១ | ៣.៥៨៨.២១០ | ១៤.៦២១.៩៥៦ | ៧.៣៧១.៨៣៤ | ២៩.៨៥៥.៩២៨ | ៤.៩០៩.២៤២ | ២០.០០៥.១៦១ |
| | **៩.៥៨៩.៧៧៨** | **៣៨.៨៣៨.៦០១** | **១៧.៥៨៨.២១០** | **៧១.៦៧១.៩៥៦** | **១១.៤៧១.៨៣៤** | **៤៦.៤៦០.៩២៨** | **១៨.៩០៩.២៤២** | **៧៧.០៥៥.១៦១** |

ប្រាក់បញ្ញើមានកាលកំណត់នៅធនាគារផ្សេងៗ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុកទទួលបានការប្រាក់ពី ២,៧០% ទៅ ៥,០០% ក្នុងមួយឆ្នាំ (ឆ្នាំ២០១៤ ទទួលបានការប្រាក់ពី ២,៣០% ទៅ ៥,៥០%)។

## ៧. ឥណទាន និងបុរេប្រទានចំពោះអតិថិជន

ខាងក្រោមនេះជាឥណទាន និងបុរេប្រទានចំពោះអតិថិជនរបស់ក្រុមហ៊ុនរួម និងធនាគារះ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ឥណទានពាណិជ្ជកម្មះ | | | | | | | | |
| ឥណទានរយៈពេលខ្លី | ១៩.៦៤៦.៤៨៥ | ៧៩.៥៦៨.២៦៤ | ២៤.៤៩៥.៣៣៦ | ៩៩.៨១៨.៤៩៤ | ៣.០០០.០០០ | ១២.១៥០.០០០ | ៣.០០០.០០០ | ១២.២២៥.០០០ |
| ឥណទានវិបារូបន៍ | ៨.០០៦.១៤១ | ៣២.៤២៤.៨៧១ | ៧.៤៣៤.៤២៥ | ៣០.២៩៥.២៨២ | ៨.០០៦.១៤១ | ៣២.៤២៤.៨៧១ | ៧.៤៣៤.៤២៥ | ៣០.២៩៥.២៨២ |
| ឥណទានរយៈពេលវែង | ៥០៨.៥៦០.៤៣៦ | ២.០៥៩.៦៦៩.៧៦៦ | ៣៣៤.៤០៤.០៦៣ | ១.៣៦២.៦៩៦.៥៥៧ | ៧២.៩៣៦.០៧០ | ២៩៥.៣៩១.០៨៣ | ៥៨.៣៣០.៣៧៤ | ២៣៧.៦៩៦.២៧៤ |
| ឥណទានអ្នកប្រើប្រាស់ះ | | | | | | | | |
| ឥណទានផ្តល់អោយបុគ្គលិក | ១៣.៨៨៩.១៧១ | ៥៦.២៥១.១៤៣ | ៦.៨១៤.០៨២ | ២៧.៧៦៧.៣៨៤ | ២.៥៨១.៧៣១ | ១០.៤៥៦.០១១ | ១.៥៧៨.៤៧០ | ៦.៤៣២.២៦៥ |
| ឥណទានដុលសរុប | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៤៣.២៦៩** | **២៨៦.៦៤៨.៨២១** |
| សំវិធានធនសម្រាប់ | | | | | | | | |
| ឥណទាន និងបុរេប្រទាន | (៣.៣៩១.៦៩០) | (១៣.៧៣៦.៣៩៥) | (២.៤២៥.១១៨) | (៩.៨៨២.៣៥៦) | (១.៧០៨.៥០១) | (៦.៩១៩.៤២៩) | (១.៣២១.១១៣) | (៥.៣៨៣.៥៣៥) |
| | **៥៤៦.៧១០.៥៤៣** | **២.២១៤.១៧៧.៦៤៩** | **៣៧០.៧២២.៧៨៨** | **១.៥១០.៦៩៥.៣៦១** | **៨៤.៨១៥.៤៤១** | **៣៤៣.៥០២.៥៣៦** | **៦៩.០២២.១៥៦** | **២៨១.២៦៥.២៨៦** |

ការវិភាគបន្ថែមលើឥណទាន និងបុរេប្រទានចំពោះអតិថិជនមានដូចខាងក្រោម៖

(ក) បម្រែបម្រួលនៃសំវិធានធនសម្រាប់ការខាតបង់លើឥណទាន និងបុរេប្រទាន៖

| | ក្រុមហ៊ុនរួម | | | ធនាគារ | | |
|---|---|---|---|---|---|---|
| | សំវិធានធន ជាក់លាក់ | សំវិធានធន ធនទូទៅ | សរុប | សំវិធានធន ជាក់លាក់ | សំវិធានធនទូទៅ ធនទូទៅ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ១.០៥៦.១៩៥ | ១.៣៦៨.៩៧៣ | ២.៤២៥.១១៨ | ៦២៣.៩២១ | ៦៩៧.១៩២ | ១.៣២១.១១៣ |
| ចំណាយសម្រាប់ការិយបរិច្ឆេទ | ៨១០.៨៩៤ | ៣១៩.៧៩៣ | ១.១៣០.៦៨៧ | ៣៣៨.៣៧០ | ៤៩.០១៨ | ៣៨៧.៣៨៨ |
| ការលុបចោល | (១៦៥.៨២៧) | - | (១៦៥.៨២៧) | - | - | - |
| លំអៀងពីអត្រាប្តូរប្រាក់ | ១.៧១២ | - | ១.៧១២ | - | - | - |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **១.៧០២.៩២៤** | **១.៦៨៨.៧៦៦** | **៣.៣៩១.៦៩០** | **៩៦២.២៩១** | **៧៤៦.២១០** | **១.៧០៨.៥០១** |
| **ពាន់រៀល (កំណត់សម្គាល់ ២.១)** | **៦.៨៩៦.៨៤៣** | **៦.៨៣៩.៥០២** | **១៣.៧៣៦.៣៤៥** | **៣.៨៩៧.២៧៩** | **៣.០២២.១៥០** | **៦.៩១៩.៤២៩** |
| សមតុល្យថ្ងៃទី១ ខែមករា ឆ្នាំ២០១៤ | ៣២១.៤១៦ | ១.៣៤៦.៨៧៣ | ១.៦៦៨.២៨៩ | ១០១.១១៧ | ៨២២.៧៥៥ | ៩២៣.៨៧២ |
| ចំណាយ (កត់ត្រាបញ្ច្រាស) សម្រាប់ ការិយបរិច្ឆេទ | ៩៩៥.៩៧៣ | ២២.១០០ | ១.០១៨.០៧៣ | ៥២៧.៧១៣ | (១២៥.៥៦៣) | ៤០២.១៥០ |
| ការលុបចោល | (២៥៩.៨៦២) | - | (២៥៩.៨៦២) | (៤.៩០៩) | - | (៤.៩០៩) |
| លំអៀងពីអត្រាប្តូរប្រាក់ | (១.៣៨២) | - | (១.៣៨២) | - | - | - |
| **សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **១.០៥៦.១៩៥** | **១.៣៦៨.៩៧៣** | **២.៤២៥.១១៨** | **៦២៣.៩២១** | **៦៩៧.១៩២** | **១.៣២១.១១៣** |
| **ពាន់រៀល (កំណត់សម្គាល់ ២.១)** | **៤.៣០៣.៧៩១** | **៥.៥៧៨.៥៦៥** | **៩.៨៨២.៣៥៦** | **២.៥៤២.៤៧៨** | **២.៨៤១.០៥៧** | **៥.៣៨៣.៥៣៥** |

## (ខ) ការកំណត់កម្រិតសំពាធឥណទានដុល និងសំវិធានធនដែលពាក់ព័ន្ធ សម្រាប់ឥណទានមិនមានដំណើរការមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ឥណទានដុល | សំវិធានធន | ឥណទានដុល | សំវិធានធន | ឥណទានដុល | សំវិធានធន | ឥណទានដុល | សំវិធានធន |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ឥណទានធម្មតា៖ | | | | | | | | |
| មានវត្ថុធានា | ៥៣០.៦៣៨.០៨២ | ១.៥៣៦.១៥៦ | ៣៦៥.១៩២.៨៦៧ | ១.១៦៤.៦៣៧ | ៥៩.៣៥៩.៩៨៤ | ៥៩៣.៦០០ | ៥៤.២៨១.៥០៨ | ៥៤២.៨១៤ |
| ពុំមានវត្ថុធានា | ៦.៨២០.៥៤០ | ១៥២.៦១០ | ៦.៨៤៤.៩៣៦ | ១៥៤.៣៧៨ | ១៥.២៦០.៩៤០ | ១៥២.៦១០ | ១៥.៤៣៧.៨៤០ | ១៥៤.៣៧៨ |
| ឥណទានឃ្លាំមើល៖ | | | | | | | | |
| មានវត្ថុធានា | ១១.៧៧៩.០៥៧ | ៣៣៨.៣៧០ | - | - | ១១.៧៧៩.០៥៧ | ៣៣៨.៣៧០ | - | - |
| ឥណទានក្រោមស្តង់ដារ៖ | | | | | | | | |
| មានវត្ថុធានា | ៤២៣.០៤៩ | ៤២៣.០៤៩ | ៣២៨.៨៧៦ | ៣២៨.៨៧៦ | - | - | - | - |
| ឥណទានជាប់សង្ស័យ៖ | | | | | | | | |
| មានវត្ថុធានា | ២២៩.២៨៦ | ២២៩.២៨៦ | ១០៤.៦៥២ | ១០៤.៦៥២ | - | - | - | - |
| ឥណទានបាត់បង់៖ | | | | | | | | |
| មានវត្ថុធានា | ៧១២.២១៩ | ៧១២.២១៩ | ៦៧២.៥៧៥ | ៦៧២.៥៧៥ | ៦២៣.៩២១ | ៦២៣.៩២១ | ៦២៣.៩២១ | ៦២៣.៩២១ |
| **សរុបឥណទានដុល** | **៥៥០.១០២.២៣៣** | **៣.៣៩១.៦៩០** | **៣៧៣.១៤៣.៩០៦** | **២.៤២៥.១១៨** | **៨៦.៥២៣.៩៤២** | **១.៧០៨.៥០១** | **៧០.៣៤៣.២៦៩** | **១.៣២១.១១៣** |
| **ពាន់រៀល** | | | | | | | | |
| (កំណត់សម្គាល់ ២.១) | **២.២២៧.៩១៤.០៤៤** | **១៣.៧៣៦.៣៤៥** | **១.៥២០.៥៧៧.៧១៧** | **៩.៨៨២.៣៥៦** | **៣៥០.៤២១.៩៦៥** | **៦.៩១៩.៤២៩** | **២៨៦.៦៤៨.៨២១** | **៥.៣៨៣.៩៣៥** |

(គ) **ការវិភាគឥណទាន និងបុរេប្រទាន តាមកាលកំណត់សងសូមមើលកំណត់សម្គាល់លេខ ២៩ ស្តីពី "ហានិភ័យសាច់ប្រាក់ងាយស្រួល"។**

(ឃ) **ការវិភាគឥណទាន និងបុរេប្រទានសំរាប់អតិថិជនតាមប្រភេទអាជីវកម្មៈ**

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ |
| លក់ដុំ និងលក់រាយ | ១៨៨.៣០៥.៥៣៦ | ៧៦២.៦៣៧.៤២១ | ១១៣.៣០៤.៦៥០ | ៤៦១.៧១៦.៤៤៩ | ១៦.៤២៤.៦៣៥ | ៦៦.៥១៩.៧៧២ | ៣០.០៣៣.៦៦៥ | ១២២.៣៨៧.១៨៥ |
| កសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ១៤៣.៩២២.២០៧ | ៥៨២.៨៨៤.៩៣៨ | ១០៤.៦៧១.០៧៣ | ៤២៦.៥៣៤.៦២២ | ៤.០៩៤.៥០៣ | ១៦.៥៨២.៧៣៧ | ៧.២៣៣.៧៥៤ | ២៩.៤៧៧.៥៤៨ |
| សេវាកម្ម | ៨៣.៣៨០.១១៩ | ៣៣៧.៦៨៩.៤៨២ | ៥២.៣៣៣.៣៧៣ | ២១៣.២៥៨.៤៩៥ | ២.៥៨១.៧៣១ | ១០.៤៥៦.០១១ | ១.៥៧៨.៤៧០ | ៦.៤៣២.២៦៥ |
| សេវាហិរញ្ញវត្ថុ | ១៥.២៦០.៩៨២ | ៦១.៨០៦.៩៧៧ | ១៥.៤៣៧.៨៤៣ | ៦២.៩០៩.២១០ | ១៥.២៦០.៩៨២ | ៦១.៨០៦.៩៧៧ | ១៥.៤៣៧.៨៤៣ | ៦២.៩០៩.២១០ |
| សំណង់ | ១៣.៤២៥.៥៥២ | ៥៤.៣៧៣.៤៨៦ | ៣៧.៥១១.៥៤៥ | ១៥២.៨៥៩.៥៤៦ | ១២.៩៣៤.១២៩ | ៥២.៣៨៣.២២២ | ៦.០៣១.៧០៤ | ២៤.៥៧៩.១៩៤ |
| ទឹក ភ្លើង | ៩.២២៧.៧៤៤ | ៣៧.៣៧២.៣៦៣ | - | - | ៩.២២៧.៧៤៤ | ៣៧.៣៧២.៣៦៣ | - | - |
| ការបញ្ចាំទ្រព្យ និងលំនៅដ្ឋាន | ៨.៩៥៩.៦៧៤ | ៣៦.២៨៦.៦៨០ | ៣៨៦.៦៥៧ | ១.៥៧២.៦២៧ | ៨.៩៥៩.៦៧៤ | ៣៦.២៨៦.៦៨០ | ៣៨៦.៦៥៧ | ១.៥៧២.៦២៧ |
| រុករករ៉ែ និងថ្ម | ៧.២១៥.២១៧ | ២៩.២២១.៦២៩ | - | - | ៧.២១៥.២១៧ | ២៩.២២១.៦២៩ | - | - |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៤.៥៥២.២៧០ | ១៨.៤៣៦.៦៩៤ | ៥.៨៨៨.៧៤២ | ២៣.៩៩៦.៦២៤ | ៤.៥៥២.២៧០ | ១៨.៤៣៦.៦៩៤ | ៥.៨៨៨.៧៤២ | ២៣.៩៩៦.៦២៤ |
| កម្មន្តសាលកម្ម | ១.១៥៦.៨៦៥ | ៤.៦៨៥.៣០៣ | ២៣១.០០៧ | ៩៤១.៣៥៤ | ១.១៥៦.៨៦៥ | ៤.៦៨៥.៣០៣ | ២៣១.០០៧ | ៩៤១.៣៥៤ |
| ផ្សេងៗ | ៧៤.៦៩៦.០៦៧ | ៣០២.៥១៩.០៧១ | ៤៣.៤២៣.០១៦ | ១៧៦.៩៤៨.៧៩០ | ៤.១១៦.១៩២ | ១៦.៦៧០.៥៧៧ | ៣.៥៦១.៤២៧ | ១៤.៥១២.៨១៤ |
| **សរុបឥណទានដុល** | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៤៣.២៦៩** | **២៨៦.៦៤៨.៩២១** |

## (ខ) វិភាគឥណទាន និងបុរេប្រទានចំពោះតាមនិវាសនភាព សម្ព័ន្ធញាតិ ហានិភ័យ អត្រាការប្រាក់ និងវត្ថុធានានៈ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| តាមនិវាសនភាពៈ | | | | | | | | |
| និវាសនជន | ៥៥០.១០២.២៣៣ | ២.២២៧.៩១៤.០៤៤ | ៣៧៣.១៤៧.៩០៦ | ១.៥២០.៥៧៧.៧១៧ | ៨៦.៥២៣.៩៤២ | ៣៥០.៤២១.៩៦៥ | ៧០.៣៨៣.២៦៩ | ២៨៦.៦៤៨.៨២១ |
| អនិវាសនជន | - | - | - | - | - | - | - | - |
| | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៨៣.២៦៩** | **២៨៦.៦៤៨.៨២១** |
| តាមទំនាក់ទំនងៈ | | | | | | | | |
| ភាគីសម្ព័ន្ធញាតិ | ១.២៦១.៩១៤ | ៥.១១០.៧៥២ | ៧៦៦.១១១ | ៣.១២១.៩០២ | ៨.៥១០.១៣៥ | ៣៤.៤៦៦.០៤៧ | ៨.៧១៦.២៣៨ | ៣៥.៥១៨.៦៧០ |
| ពុំមែនភាគីសម្ព័ន្ធញាតិ | ៥៤៨.៨៤០.៣១៩ | ២.២២២.៨០៣.២៩២ | ៣៧២.៣៨១.៧៩៥ | ១.៥១៧.៤៥៥.៨១៥ | ៧៨.០១៣.៨០៧ | ៣១៥.៩៥៥.៩១៨ | ៦១.៦៦៧.០៣១ | ២៥១.១៣០.១៥១ |
| | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៨៣.២៦៩** | **២៨៦.៦៤៨.៨២១** |
| តាមហានិភ័យៈ | | | | | | | | |
| ហានិភ័យធំ | ៥២.៥៤៩.៨១១ | ២១២.៨២៦.៧៣៥ | ៤០.៥០០.០០០ | ១៦៥.០៣៧.៥០០ | ៥២.៥៤៩.៨១១ | ២១២.៨២៦.៧៣៤ | ៤០.៥០០.០០០ | ១៦៥.០៣៧.៥០០ |
| ពុំមែនហានិភ័យធំ | ៤៩៧.៥៥២.៤២២ | ២.០១៥.០៨៧.៣០៩ | ៣៣២.៦៤៧.៩០៦ | ១.៣៥៥.៥៤០.២១៧ | ៣៣.៩៧៤.១៣១ | ១៣៧.៥៩៥.២៣១ | ២៩.៨៨៣.២៦៩ | ១២១.៦១១.៣២១ |
| | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៨៣.២៦៩** | **២៨៦.៦៤៨.៨២១** |

ហានិភ័យធំ កំណត់ដោយប្រកាសរបស់ធនាគារជាតិនៃកម្ពុជា គឺជាទឹកប្រាក់សរុបរបស់ឥណទានដុលទាំងឡាយដែលបានផ្តល់អោយរូបវន្តបុគ្គលណាម្នាក់ ហើយលើសពី ១០% នៃមូលនិធិផ្ទាល់សុទ្ធ។ ហានិភ័យធំ ត្រូវបានកំណត់យកនូវចំនួនទឹកប្រាក់ខ្ពស់បំផុតរវាងសមតុល្យនៃឥណទាន ឬនៃការសន្យាតាមហត្ថលេខា និងចំនួនទឹកប្រាក់ ឥណទាន ឬនៃការសន្យាតាមហត្ថលេខាដែលបានអនុម័ត។

## ( ខ ) វិភាគឥណទាន និងបុរេប្រទានតាមនិវាសនភាព សម្ព័ន្ធញាតិ ហានិភ័យ អត្រាការប្រាក់ និងវត្ថុធានា៖ ( តពីទំព័រមុន )

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ សម្គាល់ ២.១ |
| តាមអត្រាការប្រាក់ប្រចាំឆ្នាំ៖ | | | | | | | | |
| តិចជាង ១០% | ៨០.៣១៩.២៧១ | ៣២៥.២៩៣.០៤៨ | ៦៣.៦៦៤.៧៧៤ | ២៥៩.៤៣៣.៩៥៤ | ៧៧.៤៥៣.៩៨៥ | ៣១៣.៦៨៨.៦៣៩ | ៦៧.០៦៣.៤៧៧ | ២៧៣.២៨៣.៦៦៩ |
| ច្រើនជាង ១០% ប៉ុន្តែមិនលើស ១២% | ៨.៨៣៦.៣៤១ | ៣៥.៧៨៧.១៨១ | ៣.០៩៧.៩០៦ | ១២.៦២៣.៩៦៧ | ៨.៨៣៦.៣៤១ | ៣៥.៧៨៧.១៨១ | ៣.០៩៧.៩០៦ | ១២.៦២៣.៩៦៧ |
| ច្រើនជាង ១២% ប៉ុន្តែមិនលើស ១៥% | ៤.២៧១.៧១២ | ១៧.៣០០.៤៣៤ | ៣.១៦៦.៨៨៦ | ១២.៩០៥.០៦០ | ២៣៣.៦១៦ | ៩៤៦.១៩៥ | ១៨១.៨៨៦ | ៧៤១.១៨៥ |
| ច្រើនជាង ១៥% ប៉ុន្តែមិនលើស ១៨% | ២១៩.៩៥៦.៥២៣ | ៨៩០.៨២៣.៩១៨ | ១០១.៤៦៤.៤៤៩ | ៤១៣.៤៦៧.៦៣០ | - | - | - | - |
| ច្រើនជាង ១៨% | ២៣៦.៧១៨.៣៨៦ | ៩៥៨.៧០៩.៤៦៣ | ២០១.៧៥៣.៨៩១ | ៨២២.១៩៧.១០៦ | - | - | - | - |
| | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៤៣.២៦៩** | **២៨៦.៦៤៨.៨២១** |
| តាមវត្ថុធានា៖ | | | | | | | | |
| មានវត្ថុធានា | ៥៣៤.៨៤១.២៥៣ | ២.១៦៦.១០៧.០៧៥ | ៣៦៦.៣៤៤.៣៨១ | ១.៤៩២.៨៥៣.៣៥៣ | ៧១.២៦២.៩៦២ | ២៨៨.៦១៤.៩៨៦ | ៥៤.៩០៥.៤២៩ | ២២៣.៧៣៩.៦២៣ |
| ពុំមានវត្ថុធានា | ១៥.២៦០.៩៨០ | ៦១.៨០៦.៩៦៩ | ៦.៨០៣.៥២៥ | ២៧.៧២៤.៣៦៤ | ១៥.២៦០.៩៨០ | ៦១.៨០៦.៩៦៩ | ១៥.៤៣៧.៨៤០ | ៦២.៩០៩.១៩៨ |
| | **៥៥០.១០២.២៣៣** | **២.២២៧.៩១៤.០៤៤** | **៣៧៣.១៤៧.៩០៦** | **១.៥២០.៥៧៧.៧១៧** | **៨៦.៥២៣.៩៤២** | **៣៥០.៤២១.៩៦៥** | **៧០.៣៤៣.២៦៩** | **២៨៦.៦៤៨.៨២១** |

## ៨. ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខាររបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោមៈ

| | ក្រុមហ៊ុនរួម | | | | | |
|---|---|---|---|---|---|---|
| | កែលំអអាគារ | សង្ហារឹម និងបរិក្ខារការិយាល័យ | ព័ត៌មានវិទ្យា និងកុំព្យូទ័រ | យានយន្ត | សំណង់កំពុងសាងសង់ | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្លៃដើម | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ១.៦២០.៧១០ | ២.៤០៧.៨២២ | ៣.០៤៧.៦៤៤ | ២.៦៩៩.៤០៩ | ៤២៤.២៤២ | ១០.១៩៩.៨២៧ |
| ទិញបន្ថែម | ១៥៨.១៥៥ | ៦៤៧.៧៦៧ | ១.១៥៣.១៥៧ | ១.៧៣២.៨២៤ | ២៩៨.១៤៩ | ៣.៩៩០.០៥២ |
| ការលក់ចេញ | - | (៥៨.៨៧២) | (២០.២៨១) | (១៨៥.៧៦០) | - | (២៦៤.៩១៣) |
| ការលុបចោល | (៧៧៨.៩០៣) | (៩១៦.៣០៥) | (១៩៨.៨៨៥) | (១៧៧.១៩០) | - | (១.៥២១.២៨៣) |
| ការផ្ទេរ | - | - | ៤២៤.២៤១ | - | (៤២៤.២៤១) | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **៩៩៩.៩៦២** | **២.៥៨០.៤១២** | **៤.៤៥៥.៨៧៦** | **៤.០៦៩.២៨៣** | **២៩៨.១៥០** | **១២.៤០៣.៦៨៣** |
| ដកៈ រំលស់បង្គរ | | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ១.១០០.៩៤៧ | ១.១២៥.៦១៣ | ២.២២៣.៩៧១ | ១.១១៤.៧៣៥ | - | ៥.៥៦៥.២៦៦ |
| រំលស់ក្នុងការិយបរិច្ឆេទ | ១៦៨.២៨៧ | ៤៧៥.០៩៨ | ១.១៩៥.៧៤៨ | ៨២២.១៩៤ | - | ២.៦៦១.២៧៧ |
| ការលក់ចេញ | - | (៥០.៥១២) | (២០.១២០) | (១៩៨.០៧០) | - | (២១៨.៧០២) |
| ការលុបចោល | (៧៧៨.៩០១) | (៣៩០.៨៨១) | (១៩៥.៣៩៩) | (១៧៦.៩៣១) | - | (១.៩៩២.១១២) |
| ផ្សេងៗ | (១០៩.៧៣៤) | - | - | - | - | (១០៩.៧៣៤) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **៣៨០.៥៩៩** | **១.១៥៩.៣១៨** | **៣.២៥៤.២០០** | **១.៦១១.៨៧៨** | - | **៦.៤០៥.៩៩៥** |
| តម្លៃចុះបញ្ជីសុទ្ធ | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **៦១៩.៣៦៣** | **១.៤២១.០៩៤** | **១.២០១.៦៧៦** | **២.៤៥៧.៤០៥** | **២៩៨.១៥០** | **៥.៩៩៧.៦៨៨** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **៥១៩.៧៦៣** | **១.២៨២.២០៩** | **៨២៣.៦៧៣** | **១.៥៨៤.៦៧៤** | **៤២៤.២៤២** | **៤.៦៣៤.៥៦១** |
| ពាន់រៀល (កំណត់សម្គាល់ ២.១) | | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **២.៥០៨.៤១៩** | **៥.៧៥៥.៤៣១** | **៤.៨៦៦.៧៨៨** | **៩.៩៥២.៤៩០** | **១.២០៧.៥០៨** | **២៤.២៩០.៦៣៦** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **២.១១៨.០៣៤** | **៥.២២៥.០០២** | **៣.៣៥៦.៤៦៧** | **៦.៤៥៧.៥៤៧** | **១.៧២៨.៧៨៦** | **១៨.៨៨៥.៨៣៦** |

| | ធនាគារ | | | | |
|---|---|---|---|---|---|
| | កែលំអអាគារ | សង្ហារឹម និងបរិក្ខារ ការិយាល័យ | ព័ត៌មានវិទ្យា និងកុំព្យូទ័រ | យានយន្ត | សរុប |
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្លៃដើម | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ១.១៩៥.៣៨៦ | ៥០៤.៤៦៨ | ១.៣៨១.៨០៧ | ៥៧១.១៤០ | ៣.៦០២.៨០១ |
| ទិញបន្ថែម | ៣.៤៦៥ | ៨៥០ | ២៣.៨៥៤ | ១៩.៤០០ | ៤៧.៥៦៩ |
| ការលក់ចេញ | - | (៥៤.៤២១) | - | - | (៥៤.៤២១) |
| លុបចោល | (៧៧៨.៩០៣) | (៣៨០.៤២០) | (១២២.៨៣២) | (១៧៥.៦៧០) | (១.៤៥៧.៨២៥) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **៣៦៩.៩៤៨** | **៧០.៤៧៧** | **១.២៨២.៨២៩** | **៤១៤.៨៧០** | **២.១៣៨.១២៤** |
| ដក: រំលស់បង្គរ | | | | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ៩២៩.៨៤២ | ៤១៧.៦៥៦ | ១.១៤០.៤១៨ | ៣២៤.១៧០ | ២.៨១២.០៨៦ |
| រំលស់ក្នុងការិយបរិច្ឆេទ | ៧១.៩០០ | ១៥.៦៩៣ | ១២៨.០៧៨ | ៦៦.៥៩២ | ២៨២.២៦៣ |
| ការលក់ចេញ | - | (៤៧.១០១) | - | - | (៤៧.១០១) |
| ការលុបចោល | (៧៧៨.៩០១) | (៣៦៣.៨៣៤) | (១១៩.៩២៥) | (១៧៥.៦៧០) | (១.៤៣៨.៣៣០) |
| ផ្សេងៗ | (១០៩.៧៣៤) | - | - | - | (១០៩.៧៣៤) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥** | **១១៣.១០៧** | **២២.៤១៤** | **១.១៤៨.៥៧១** | **២១៥.០៩២** | **១.៤៩៩.១៨៤** |
| តម្លៃចុះបញ្ជីសុទ្ធ | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **២៥៦.៨៤១** | **៤៨.០៦៣** | **១៣៤.២៥៨** | **១៩៩.៧៧៨** | **៦៣៨.៩៤០** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **២១៥.៥៤៤** | **៨៦.៨១២** | **២៤១.៣៨៩** | **២៤៦.៩៧០** | **៧៩០.៧១៥** |
| ពាន់រៀល (កំណត់សម្គាល់ ២.១) | | | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **១.០៤០.២០៦** | **១៩៤.៦៥៥** | **៥៤៣.៧៤៥** | **៨០៩.១០១** | **២.៥៨៧.៧០៧** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **៨៧៨.៣៤២** | **៣៥៣.៧៥៩** | **៩៨៣.៦៦០** | **១.០០៦.៤០៣** | **៣.២២២.១៦៤** |

**៩. កម្មវិធីកុំព្យូទ័រ**

**បម្រែបម្រួលនៃកម្មវិធីកុំព្យូទ័ររបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖**

| | ក្រុមហ៊ុនរួម | ធនាគារ |
|---|---|---|
| | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| ថ្លៃដើម | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ២.៨០៧.២៧៤ | ១.៧៥០.៩៨១ |
| ទិញបន្ថែម | ៣១.៥០០ | ៣១.៥០០ |
| ការលុបចោល | (៣២៣.៧៩១) | (៣២៣.៧៩១) |
| **នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០១៥** | **២.៥១៤.៩៨៣** | **១.៤៥៨.៦៩០** |
| ដក: រំលស់បង្គរ | | |
| នាថ្ងៃទី១ ខែមករា ឆ្នាំ២០១៥ | ២.២៥០.០២១ | ១.៥៩១.៥៣៧ |
| រំលស់ក្នុងការិយបរិច្ឆេទ | ២៩៣.៧៥៦ | ៩៤.៨៥១ |
| ការលុបចោល | (៣២៣.៧៩១) | (៣២៣.៧៩១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៥** | **២.២១៩.៩៨៦** | **១.៣៦២.៥៩៧** |
| តម្លៃចុះបញ្ជីសុទ្ធ | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **២៩៤.៩៩៧** | **៩៦.០៩៣** |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤** | **៥៥៧.២៥៣** | **១៥៩.៤៤៤** |
| **ពាន់រៀល** (កំណត់សម្គាល់ ២.១) | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ | **១.១៩៤.៧៣៨** | **៣៨៩.១៧៧** |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ | **២.២៧០.៨០៦** | **៦៤៩.៧៣៤** |

## ១០. ទ្រព្យសកម្មផ្សេងៗ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ការប្រាក់បង្គរត្រូវទទួល | ៥.៨៣២.៥២១ | ២៣.៦២១.៧១០ | ៤.០៣០.០០២ | ១៦.៤២២.២៥៨ | ៣៧៩.៤៤០ | ១.៥៣៦.៧៣២ | ៣៣៦.៦០០ | ១.៣៧១.៦៤៥ |
| ប្រាក់បង់មុន | ៦.០០០.៨៥០ | ២៤.៣០៣.៤៤៣ | ៣.៩០០.១៤១ | ១៥.៨៩៣.០៧៥ | ២៩៦.៥៩៦ | ១.២០១.២១៤ | ១៧១.៨៣៥ | ៧០០.២២៨ |
| បុរេប្រទាន និងប្រាក់កក់ | ២.៦១៥.២៥០ | ១០.៥៩១.៧៦២ | ១.៦៤០.០២២ | ៦.៦៨៣.០៩០ | ២.៦១៥.២៥០ | ១០.៥៩១.៧៦២ | ១.៦៤០.០២២ | ៦.៦៨៣.០៩០ |
| ផ្សេងៗ | ៣២៤.៦៤៩ | ១.៣១៤.៨៣០ | ១៦០.០០៧ | ៦៥២.០២៨ | ២៩៩.៦៤៩ | ១.២១៣.៥៧៩ | ១៣៥.០០៧ | ៥៥០.១៥៣ |
| | **១៤.៧៧៣.២៧០** | **៥៩.៨៣១.៧៤៥** | **៩.៧៣០.១៧២** | **៣៩.៦៥០.៤៥១** | **៣.៥៩០.៩៣៥** | **១៤.៥៤៣.២៨៧** | **២.២៨៣.៤៦៤** | **៩.៣០៥.១១៦** |
| សំវិធានធននៃការខាតបង់ | (១.២៥៤.៧៨៥) | (៥.០៨១.៨៧៩) | - | - | (១.២៥៤.៧៨៥) | (៥.០៨១.៨៧៩) | - | - |
| | **១៣.៥១៨.៤៨៥** | **៥៤.៧៤៩.៨៦៦** | **៩.៧៣០.១៧២** | **៣៩.៦៥០.៤៥១** | **២.៣៣៦.១៥០** | **៩.៤៦១.៤០៨** | **២.២៨៣.៤៦៤** | **៩.៣០៥.១១៦** |

ទ្រព្យផ្សេងៗរួមមាន ទ្រព្យសកម្មតូចតាច និងការវិនិយោគនៅក្រេឌីតប្យ្ររ៉ូកម្ពុជាចំនួន ១០០.០០០ ដុល្លារអាមេរិកសម្រាប់ក្រុមហ៊ុនរួម និងចំនួន ៧៥.០០០ ដុល្លារអាមេរិកសម្រាប់ធនាគារ (ឆ្នាំ២០១៤ ចំនួន ១៥០.០០០ ដុល្លារអាមេរិកសម្រាប់ក្រុមហ៊ុនរួម និងចំនួន ១២៥.០០០ ដុល្លារអាមេរិកសម្រាប់ធនាគារ)។ តម្លៃទីផ្សាររបស់ការវិនិយោគនេះមិនអាចកំណត់បានអោយជាក់លាក់នោះទេដោយសារតែភាពមិនច្បាស់លាស់នៃលំហូរសាច់ប្រាក់នាពេលអនាគត និងកង្វះខាតនៃវិធីសាស្ត្រសមស្របសម្រាប់កំណត់តម្លៃទីផ្សារនេះ។ ការវិនិយោគនេះត្រូវបានកត់ត្រាតាមថ្លៃដើម។ នៅឆ្នាំ២០១៤ ទ្រព្យផ្សេងៗរួមមានប្រាក់ពន្ធបង់មុនរបស់ធនាគារមានចំនួន ១.២៤៩ ដុល្លារអាមេរិក (កំណត់សម្គាល់លេខ ១៣.១)។

សំវិធានធននៃការខាតបង់ជាប់ទាក់ទងនឹងបុរេប្រទានដែលផ្តល់អោយការិយាល័យម៉ារ៉ូហាន់ នៅប្រទេសមីយ៉ាន់ម៉ា និងប្រាក់កក់ដែលត្រូវបង្វិលសងវិញ។

## ១១. ប្រាក់បញ្ញើពីធនាគារផ្សេង

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| គណនីចរន្ត | ២.៦៩០.៨៤២ | ១០.៨៩៧.៩១០ | ៤៧៤.៣៦៥ | ១.៩៣៣.០៣៨ | ២.៦៩០.៨៤២ | ១០.៨៩៧.៩១០ | ៦២៥.១៨៧ | ២.៥៤៧.៦៣៧ |
| គណនីសន្សំ | ១០២.៦៣៣ | ៤១៥.៦៦៤ | ៤៦.៦៩៣ | ១៩០.២៧៤ | ៥១២ | ២.០៧៤ | ៧៥៨ | ៣.០៨៩ |
| គណនីបញ្ញើមានកាលកំណត់ | ១៩.៦០៦.០០០ | ៧៩.៤០៤.៣០០ | ១៤.៩០១.៧៦៤ | ៦០.៧២៤.៦៨៨ | ៦.០០០.០០០ | ២៤.៣០០.០០០ | ៧.០០០.០០០ | ២៨.៥២៥.០០០ |
| | **២២.៣៩៩.៤៧៥** | **៩០.៧១៧.៨៧៤** | **១៥.៤២២.៨២២** | **៦២.៨៤៨.០០០** | **៨.៦៩១.៣៥៤** | **៣៥.១៩៩.៩៨៤** | **៧.៦២៥.៩៤៥** | **៣១.០៧៥.៧២៦** |

គណនីចរន្តមិនមានការប្រាក់នោះទេ ប៉ុន្តែគណនីបញ្ញើមានកាលកំណត់ទទួលបានការប្រាក់ប្រចាំឆ្នាំពី ០,៣៨% - ៥,០០% ក្នុងឆ្នាំ២០១៥ (១,២៥% - ៤,៥០% ក្នុងឆ្នាំ២០១៤)។

## ១២. ប្រាក់បញ្ញើពីអតិថិជន

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ប្រាក់បញ្ញើចរន្ត | ៣.១៣៧.៣១៦ | ១២.៧០៦.១៣០ | ៣.១៧៩.៨៥៥ | ១២.៩៥៧.៩០៩ | ៣.១៣៧.៣១៦ | ១២.៧០៦.១៣០ | ៣.១៧៩.៨៥៥ | ១២.៩៥៧.៩០៩ |
| ប្រាក់បញ្ញើសន្សំ | ៨.០៨៦.៨៦៥ | ២៧៥.៧៥១.៨០៣ | ៦៦.០៨០.១៣២ | ២៦៩.២៧៦.៥៣៨ | ៣៥.៦០៣.៧៥២ | ១៤៤.១៩៥.១៩៥ | ៣៩.៩១០.៣០១ | ១៦២.៦៣៤.៤៧៧ |
| ប្រាក់បញ្ញើមានការកំណត់ | ២៥៤.៧៧១.៣០២ | ១.០៣១.៨២៣.៧៧៣ | ១៨៤.៥៧៥.៥០២ | ៧៥២.១៤៥.១៧១ | ៤៣.៨២៧.៦១៤ | ១៧៧.៥០១.៨៣៧ | ៥៣.៩១៨.០៤៤ | ២១៩.៧១៦.០២៩ |
| មូលប្បទានបត្រធនាគារិក | ២.០១៦ | ៨.១៦៥ | ២១៦ | ៨៨០ | ២.០១៦ | ៨.១៦៥ | ២១៦ | ៨៨០ |
| | **៣២៥.៩៩៧.៤៩៩** | **១.៣២០.២៨៩.៨៧១** | **២៥៣.៨៣៥.៧០៥** | **១.០៣៤.៣៨០.៤៩៨** | **៨២.៥៧០.៦៩៨** | **៣៣៤.៤១១.៣២៧** | **៩៧.០០៨.៤១៦** | **៣៩៥.៣០៩.២៩៥** |

ការវិភាគបន្ថែមលើប្រាក់បញ្ញើពីអតិថិជនមានដូចខាងក្រោម៖

(១) អត្រាការប្រាក់ប្រចាំឆ្នាំលើប្រាក់បញ្ញើពីអតិថិជនរបស់ក្រុមហ៊ុនរួម និងធនាគារត្រូវបានសង្ខេបដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | ធនាគារ | |
|---|---|---|---|---|
| | ២០១៥ | ២០១៤ | ២០១៥ | ២០១៤ |
| ប្រាក់បញ្ញើចរន្ត | ០,៥០% - ១,៥០% | គ្មាន | ០,៥០% - ១,៥០% | គ្មាន |
| ប្រាក់បញ្ញើសន្សំ | ០,២៥% - ៤,០០% | ០,៧៥% - ៤,០០% | ០,២៥% - ៣,០០% | ០,៥០% - ២,៥០% |
| ប្រាក់បញ្ញើមានកាលកំណត់ | ១,០០% - ៩,៥០% | ១,០០% - ៨,០០% | ១,០០% - ៧,០០% | ១,០០% - ៧,០០% |

(២) ប្រាក់បញ្ញើពីសម្ព័ន្ធញាតិ សូមមើលកំណត់សម្គាល់លេខ ២៧ ស្តីពី “ប្រតិបត្តិការ និងសមតុល្យរវាងសម្ព័ន្ធញាតិ”។

(៣) ការវិភាគអំពីកាលវសាន សូមមើលកំណត់សម្គាល់លេខ ២៩ ស្តីពី “ហានិភ័យសាច់ប្រាក់ងាយស្រួល”។

## ១៣. ពន្ធលើប្រាក់ចំណេញ

សមាសធាតុសំខាន់ៗនៃចំណាយពន្ធលើប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ មានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ចំណាយពន្ធលើប្រាក់ចំណេញ | | | | | | | | |
| ពន្ធក្នុងគ្រា | ៥.២៦២.០៥៩ | ២១.៣១១.៣៣៩ | ៣.០១៣.៥១២ | ១២.២៨០.០៦២ | ៩១.៤២៩ | ៣៧០.២៨៧ | ៧០.៣៩៧ | ២៨៦.៨៦៨ |
| ពន្ធពន្យារ | (៣៥៥.៦២៣) | (១.៤៤០.២៧៣) | (៣៣៥.២៦៤) | (១.៣៦៦.២០១) | ៩១.៨៧៣ | ៣៧២.០៨៦ | (៤៤.៩១៩) | (១៨៣.០៤៥) |
| | **៤.៩០៦.៤៣៦** | **១៩.៨៧១.០៦៦** | **២.៦៧៨.២៤៨** | **១០.៩១៣.៨៦១** | **១៨៣.៣០២** | **៧៤២.៣៧៣** | **២៥.៤៧៨** | **១០៣.៨២៣** |

### ១៣.១ ពន្ធលើប្រាក់ចំណេញក្នុងគ្រា

លិខិតប្រកាសពន្ធរបស់ធនាគារ គឺជាកម្មវត្ថុនៃការត្រួតពិនិត្យរបស់អាជ្ញាធរពន្ធដារ។ទឹកប្រាក់ដែលត្រូវរាយការណ៍ក្នុងរបាយការណ៍ហិរញ្ញវត្ថុអាចត្រូវបានផ្លាស់ប្តូរ នៅកាលបរិច្ឆេទក្រោយៗទៀតនៅពេលមានការកំណត់ចុងក្រោយរបស់អាជ្ញាធរពន្ធដារពីព្រោះការអនុវត្តច្បាប់និងបទបញ្ញត្តិពន្ធលើប្រភេទប្រតិបត្តិការជាច្រើនគឺងាយនឹងមានការភាន់ច្រឡំ ហើយមានការបកស្រាយខុសៗគ្នា។

យោងតាមបទបញ្ញត្តិច្បាប់សារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជាពន្ធលើប្រាក់ចំណេញបច្ចុប្បន្នត្រូវបានគណនាដោយយកចំនួនខ្ពស់ជាងគេនៃប្រាក់ចំណេញជាប់ពន្ធសម្រាប់ការិយបរិច្ឆេទគុណនឹងអត្រាពន្ធ ២០% និងពន្ធក្នុងអត្រា ១% នៃផលរបរសរុប។

ព័ត៌មានលម្អិតនៃចំណាយពន្ធលើប្រាក់ចំណេញ មានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ចំណេញមុនបង់ពន្ធតាមបញ្ជី គណនេយ្យ | ២៣.២៦៨.៨៨៩ | ៩៤.២៣៩.០០២ | ១២.២៧៥.៤៧៣ | ៥០.០២២.៥៥៤ | ២.១៦១.៧៥៨ | ៨.៧៥៥.១២១ | ៨១០.៦១៤ | ៣.៣០៣.២៥២ |
| ពន្ធលើប្រាក់ចំណេញបច្ចុប្បន្នតាម | | | | | | | | |
| អត្រាកំណត់ ២០% | ៤.៦៥៣.៧៧៨ | ១៨.៨៤៧.៨០០ | ២.៤៥៥.០៩៥ | ១០.០០៤.៥១២ | ៤៣២.៣៥២ | ១.៧៥១.០២៤ | ១៦២.១២៣ | ៦៦០.៦៥១ |
| ធាតុមិនអាចកាត់កងបាន | ១០៩.៥៥១ | ៤៤៣.៦៨២ | ១០៤.២៤១ | ៤២៤.៧៨២ | ១១៣.២៨៨ | ៤៥៨.៨១៦ | ៣៤.១២១ | ១៣៩.០៤៣ |
| ចំណូលមិនជាប់ពន្ធ | (១.២២៤) | (៤.៩៥៦) | - | - | (៥០៦.៦៦៩) | (២.០៥២.០០៩) | (២៤៩.៦៧៨) | (១.១៨០.៤៣៨) |
| ឥទ្ធិពលពន្ធអប្បបរមា | ៩១.៤២៩ | ៣៧០.២៨៧ | ៧០.៣៩៧ | ២៨៦.៨៦៨ | ៩១.៤២៩ | ៣៧០.២៨៧ | ៧០.៣៩៧ | ២៨៦.៨៦៨ |
| បម្រែបម្រួលពន្ធពន្យារជាទ្រព្យ | | | | | | | | |
| សកម្មដែលមិនទទួលស្គាល់ | ៥២.៩០២ | ២១៤.២៥៣ | ៤៨.៥១៥ | ១៩៧.៦៩៩ | ៥២.៩០២ | ២១៤.២៥៥ | ៤៨.៥១៥ | ១៩៧.៦៩៩ |
| **សរុបពន្ធលើប្រាក់ចំណេញក្នុងគ្រា** | **៤.៩០៦.៤៣៦** | **១៩.៨៧១.០៦៦** | **២.៦៧៨.២៤៨** | **១០.៩១៣.៨៦១** | **១៨៣.៣០២** | **៧៤២.៣៧៣** | **២៥.៤៧៨** | **១០៣.៨២៣** |

ព័ត៌មានលម្អិតពីបម្រែបម្រួលនៃពន្ធលើប្រាក់ចំណេញដែលត្រូវបង់ (ប្រាក់ពន្ធបង់មុន) មានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| សមតុល្យនាដើមការិយបរិច្ឆេទ | ២.៤៨១.៤៩៧ | ១០.១១២.០៩៩ | ១.៩៨៣.៦១០ | ៧.៩២៤.៥២២ | (១.២៤៩) | (៥.០៩០) | ៧២១.៦៦៦ | ២.៨៨៣.០៥៦ |
| ចំណាយពន្ធលើប្រាក់ចំណេញបច្ចុប្បន្ន សម្រាប់ការិយបរិច្ឆេទ | ៥.២៦២.០៥៩ | ២១.៣១១.៣៣៩ | ៣.០១៣.៥១២ | ១២.២៨០.០៦២ | ៩១.៤២៩ | ៣៧០.២៨៧ | ៧០.៣៩៧ | ២៨៦.៨៦៨ |
| ពន្ធបានបង់ក្នុងការិយបរិច្ឆេទ | (៣.៣២៧.៦១៥) | (១៣.៤៧៦.៨៤១) | (២.៥១៥.៦២៥) | (១០.២៥១.១៧២) | (៨៥.២៨៤) | (៣៤៥.៤០០) | (៧៩៣.៣១២) | (៣.២៣២.៧៤៦) |
| លំអៀងពីការប្តូររូបិយវត្ថុបរទេស | - | (៦២.០៣៦) | - | ១៥៨.៦៨៨ | - | ៣២ | - | ៥៧.៧៣១ |
| **សមតុល្យនាចុងការិយបរិច្ឆេទ** | **៤.៤១៥.៩៤១** | **១៧.៨៨៤.៥៦១** | **២.៤៨១.៤៩៧** | **១០.១១២.១០០** | **៤.៨៩៦** | **១៩.៨២៩** | **(១.២៤៩)** | **(៥.០៩០)** |

ប្រាក់ពន្ធបង់មុនរបស់ធនាគារនៅឆ្នាំ២០១៤ ត្រូវបានបង្ហាញក្នុងផ្នែកមួយនៃទ្រព្យសកម្មផ្សេងៗ (សូមមើលកំណត់សម្គាល់លេខ ១០)។

## ១៣.២ ពន្ធពន្យារលើប្រាក់ចំណេញ

ខាតពន្ធយោងទៅការិយបរិច្ឆេទបន្ទាប់

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ធនាគារ បានធ្វើការប៉ាន់ប្រមាណទៅលើការខាតបង់ពន្ធបង្គរចំនួន ២៩២.៥៧៥ ដុល្លារអាមេរិក ដើម្បីកាត់កងនឹងប្រាក់ចំណេញជាប់ពន្ធ នាពេលអនាគត។ ជាមួយនឹងការផ្លាស់ប្តូរម្ចាស់កម្មសិទ្ធិក្នុងឆ្នាំ២០១៥ គណៈគ្រប់គ្រងបានវាយតម្លៃថា ការខាតបង់ពន្ធបង្គរ មិនអាចត្រូវបានកាត់កងនឹងប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតបាននោះទេ។

នាកាលបរិច្ឆេទនៃតារាងតុល្យការ ពន្ធពន្យារទ្រព្យសកម្មរួមមាន៖

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ពន្ធពន្យារទ្រព្យសកម្ម | | | | | | | | |
| ចំណាយបង្គរ | ៧៦១.៧៧៥ | ៣.០៨៥.១៨៨ | ៥៤៤.២៦៥ | ២.២១៧.៨៨១ | - | - | - | - |
| សំវិធានធនលើឥណទាន និង | | | | | | | | |
| បុរេប្រទានផ្តល់អោយអតិថិជន | ២៩៦.៧៦០ | ១.២០១.៨៧៨ | ១៩៨.២១៤ | ៨០៧.៧២២ | - | - | - | - |
| មូលនិធិសោធននិវត្តន៍ | ២២១.៨៣៨ | ៨៩៦.៨២៤ | ២០៩.៧៣៧ | ៨៥៤.៦៧៨ | ២៥.៨៨៤ | ១០៤.៨៣០ | ៦៦.៦៨២ | ២៧១.៧២៩ |
| ខាតពីអត្រាប្តូរប្រាក់មិនបានទទួលស្គាល់ | ៧៩.៨២៣ | ៣២៣.២៨៣ | ១១.៨៣៤ | ៤៨.២២៣ | - | - | ១.៦៨៥ | ៦.៨៦៦ |
| ទ្រព្យ និងបរិក្ខារ | ៤៨.១៣៣ | ១៩៤.៩៣៩ | ៥៩.៧៤៧ | ២៤៣.៤៦៩ | - | - | ២៣.៥០៦ | ៩៥.៧៨៧ |
| ចំណូលមិនទាន់បំពេញសេវា | ៣១.៥៣៦ | ១២៧.៧២១ | ៣៤.១៦១ | ១៣៩.២០៦ | - | - | - | - |
| | ១.៤៣៩.៨៦៥ | ៥.៨២៩.៨៣៣ | ១.០៥៧.៩៥៨ | ៤.៣១១.១៧៩ | ២៥.៨៨៤ | ១០៤.៨៣០ | ៩១.៨៧៣ | ៩១.៨៧៣ |
| ពន្ធពន្យារបំណុល | | | | | | | | |
| ចំណេញពីអត្រាប្តូរប្រាក់មិនបានទទួលស្គាល់ | (២៥.៨៨៤) | (១០៤.៨៣០) | - | - | (២៥.៨៨៤) | (១០៤.៨៣០) | - | - |
| **ពន្ធពន្យារទ្រព្យសកម្មសុទ្ធ** | **១.៤១៣.៩៨១** | **៥.៧២៥.០០៣** | **១.០៥៧.៩៥៨** | **៤.៣១១.១៧៩** | - | - | **៩១.៨៧៣** | **៣៧៤.៣៨២** |

គណៈគ្រប់គ្រងរបស់ធនាគារ ជឿជាក់ថា វាមានការពិបាកក្នុងការស្រោចស្រង់ពន្ធពន្យារទ្រព្យសកម្ម ជាមួយនឹងការរួមបញ្ចូលគ្នានៃក្រុមហ៊ុនរួមដែលនឹងមកដល់។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ពន្ធពន្យារទ្រព្យសកម្មដែលមិនបានទទួលស្គាល់របស់ក្រុមហ៊ុនរួម និងធនាគារមានចំនួន ១២៧.៧៨០ ដុល្លារអាមេរិក។

## ១៤ ប្រាក់កម្ចី

ប្រាក់កម្ចីរបស់ក្រុមហ៊ុនបុគ្រសម្ព័ន្ធពុំមានវត្ថុធានានោះទេ និងមានរាយដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | |
|---|---|---|---|---|
| | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | កំណត់សម្គាល់២.១ | | កំណត់សម្គាល់២.១ |
| Nederlandse Financierings – Maatschappij voor Ontwikkelingslanden N.V ( 'FMO" ) | ៤៥.០០០.០០០ | ១៨២.២៥០.០០០ | ២៥.៦៥៦.៨៥១ | ១០៤.៥៥១.៦៦៨ |
| Symbiotics | ១៧.៩៩៦.០៤៩ | ៧២.៨៨៣.៩៩៨ | ១៧.៤៨១.២២៧ | ៧១.២៣៦.០០០ |
| DEG | ១២.៥០០.០០០ | ៥០.៦២៥.០០០ | ១៥.០០០.០០០ | ៦១.១២៥.០០០ |
| Micro-Finance Enhancement | ១៥.០០០.០០០ | ៦០.៧៥០.០០០ | ១០.០០០.០០០ | ៤០.៧៥០.០០០ |
| ResponsAbility SICAV | ១១.០០០.០០០ | ៤៤.៥៥០.០០០ | ១០.០០០.០០០ | ៤០.៧៥០.០០០ |
| ICBC | ១៥.០០០.០០០ | ៦០.៧៥០.០០០ | ៩.០០០.០០០ | ៣៦.៦៧៥.០០០ |
| Norfund | ៤.២០០.០០០ | ១៧.០១០.០០០ | ៧.០០០.០០០ | ២៨.៥២៥.០០០ |
| Triodos – Doen | ៥.២៥០.០០០ | ២១.២៦២.៥០០ | ៥.២៥០.០០០ | ២១.៣៩៣.៧៥០ |
| Blue Orchard | ៣.៣៣៣.៣៣៤ | ១៣.៥០០.០០៣ | ៤.៦៦៦.៦៦៧ | ១៩.០១៦.៦៦៨ |
| Cathay United Bank ( Cambodia ) Corporation Limited | ២.៨៩៦.០១៣ | ១១.៧២៨.៨៥៣ | ៤.៤៧៥.៤៧៥ | ១៨.២៣៧.៥៦១ |
| NMI | ៤.០០០.០០០ | ១៦.២០០.០០០ | ៤.០០០.០០០ | ១៦.៣០០.០០០ |
| Maruhan Investment Asia | ១០.០០០.០០០ | ៤០.៥០០.០០០ | - | - |
| Hatton National Bank Plc | ៤.៧៥០.០០០ | ១៩.២៣៧.៥០០ | - | - |
| ABA Bank | ២.៥០០.០០០ | ១០.១២៥.០០០ | - | - |
| Union Commercial Bank | ៥.០០០.០០០ | ២០.២៥០.០០០ | - | - |
| ACLEDA Bank | ២.០០០.០០០ | ៨.១០០.០០០ | | |
| DWM Funds S.C.A | - | - | ៣.០០០.០០០ | ១២.២២៥.០០០ |
| | **១៦០.៤២៥.៣៩៦** | **៦៤៩.៧២២.៨៥៤** | **១១៥.៥៣០.២២០** | **៤៧០.៧៨៥.៦៤៧** |

ចំនួនខាងលើគឺពុំមានទ្រព្យធានា តាមរយៈព័ត៌មានលម្អិតខាងក្រោម៖

(ក) តាមរូបិយប័ណ្ណ

| | ក្រុមហ៊ុនរួម | | | |
|---|---|---|---|---|
| | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | កំណត់សម្គាល់២.១ | | កំណត់សម្គាល់២.១ |
| ដុល្លារអាមេរិក | ១៥៥.៩២៩.៣៤៧ | ៦៣១.៥១៣.៨៥៦ | ១១២.៣៩២.១៤២ | ៤៥៧.៩៩៧.៩៧៩ |
| ប្រាក់រៀល | ៤.៤៩៦.០៤៩ | ១៨.២០៨.៩៩៨ | ៣.១៣៨.០៧៨ | ១២.៧៨៧.៦៦៨ |
| | **១៦០.៤២៥.៣៩៦** | **៦៤៩.៧២២.៨៥៤** | **១១៥.៥៣០.២២០** | **៤៧០.៧៨៥.៦៤៧** |

(ខ) តាមកាលវសាន

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | កំណត់សម្គាល់ ២.១ | | កំណត់សម្គាល់ ២.១ |
| តិចជាងមួយខែ | ២.០៨០.៣៥៣ | ៨.៤២៥.៤៣០ | - | - |
| មួយទៅបីខែ | ៩.៤៩១.០១៤ | ៣៨.៤៣៨.៦០៧ | ៩.៥៨១.១១៩ | ៣៩.០៤៣.០៦០ |
| បីទៅដប់ពីរខែ | ៤៣.០៣៥.៦១៧ | ១៧៤.២៩៤.២៤៨ | ៣២.២៣០.៤៤១ | ១៣១.៣៣៩.០៤៧ |
| មួយឆ្នាំទៅប្រាំឆ្នាំ | ១០៥.៨១៤.៤១២ | ៤២៨.៥៦៤.៥៦៩ | ៧១.២១៨.៦៦០ | ២៩០.២១៦.០៤០ |
| លើសពីប្រាំឆ្នាំ | - | - | ២.៥០០.០០០ | ១០.១៨៧.៥០០ |
| | **១៦០.៤២៥.៣៩៦** | **៦៤៩.៧២២.៨៥៤** | **១១៥.៥៣០.២២០** | **៤៧០.៧៨៥.៦៤៧** |

(គ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំរួមទាំងពន្ធកាត់ទុក)

| | ២០១៥ | ២០១៤ |
|---|---|---|
| រៀល | ៤,៧២% - ១១% | ៥,២១% - ១០,៥០% |
| ដុល្លារអាមេរិក | ៩,១៧% - ១០,៥០% | ៩,០០% - ១០,៥០% |

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានបំពានលក្ខខណ្ឌហិរញ្ញវត្ថុរវាង FMO និង DEG ដើម្បីរក្សាទំហំសមាមាត្រសន្ទនីយភាព១00%។ ទំហំសមាមាត្រសន្ទនីយភាពដែលបានគណនានៃក្រុមហ៊ុនបុត្រសម្ព័ន្ធគឺ ៨៦% ។ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០១៦ បុត្រសម្ព័ន្ធបានជូនដំណឹងម្ចាស់បំណុល នៃការបំពាន និងបានស្នើសុំលុបចោលទំហំសមាមាត្រសន្ទនីយភាពសម្រាប់ត្រីមាសចុងក្រោយបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

នៅថ្ងៃទី២០ ខែមករា ឆ្នាំ២០១៦ DEG បានយល់ព្រមលើសំណើលុបចោលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ។ នាកាលបរិច្ឆេទនៃរបាយការណ៍នេះ FMO មិនទាន់បានអនុម័ត លើសំណើលុបចោលនៃក្រុមហ៊ុនបុត្រសម្ព័ន្ធនៅឡើយទេ។ គណៈគ្រប់គ្រងជឿជាក់ថា ការអនុម័តនៃសំណើនេះនឹងត្រូវបានធានា ពីម្ចាស់បំណុល។

## ១៥. បំណុលបន្ទាប់បន្សំ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| **MARUHAN (Cambodia) Corporation** | ១៥.០០០.០០០ | ៦០.៧៥០.០០០ | - | - | - | - | | |
| **DEG** | ១០.០០០.០០០ | ៤០.៥០០.០០០ | ១០.០០០.០០០ | ៤០.៧៥០.០០០ | - | - | - | - |
| **MARUHAN Investment Asia Pte Ltd.** | ៥.០០០.០០០ | ២០.២៥០.០០០ | ៣៥.០០០.០០០ | ១៤២.៦២៥.០០០ | - | - | ៣០.០០០.០០០ | ១២២.២៥០.០០០ |
| **Triodos – Doen and Triodos Share Fund** | ១.៣១៣.២១៧ | ៥.៣១៨.៥២៩ | ១.៣១៣.២១៧ | ៥.៣៥១.៣៥៩ | - | - | - | - |
| **DWM Funds S.C.A** | ១.០០០.០០០ | ៤.០៥០.០០០ | ១.០០០.០០០ | ៤.០៧៥.០០០ | - | - | - | - |
| | **៣២.៣១៣.២១៧** | **១៣០.៨៦៨.៥២៩** | **៤៧.៣១៣.២១៧** | **១៩២.៨០១.៣៥៩** | - | - | **៣០.០០០.០០០** | **១២២.២៥០.០០០** |

**MARUHAN (Cambodia) Corporation**

នៅថ្ងៃទី៦ ខែមេសា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពីក្រុមហ៊ុន **MARUHAN (Cambodia) Corporation** ចំនួន ១៥.០០០.០០០ ដុល្លារអាមេរិក។ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៥ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានដកទឹកប្រាក់ចំនួន ១៥.០០០.000 ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះមានរយៈពេលប្រាំពីរឆ្នាំ ដល់កាលវសាននៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០២២ និងមានការប្រាក់ថេរចំនួន ៧,០០ %ក្នុងមួយឆ្នាំ។

**DEG**

នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពីក្រុមហ៊ុន **DEG** ចំនួន ១០.០០០.០០០ ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំមានរយៈពេល ៧ ឆ្នាំ ដល់កាលវសាននៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០២១ និងមានការប្រាក់ថេរចំនួន ១០,៦៥%ក្នុងមួយឆ្នាំ។

**MARUHAN Investment Asia Pte Ltd.**

នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពីក្រុមហ៊ុន **MARUHAN Investment Asia** ចំនួន ៥.០០០.០០០ ដុល្លារអាមេរិក។ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានដកប្រាក់ចំនួន ៥.០០០.០០០ ដុល្លារអាមេរិកនៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៣។ បំណុលបន្ទាប់បន្សំនេះមានរយៈពេល ៧ ឆ្នាំ ដល់កាលវសាននៅថ្ងៃទី១២ ខែសីហា ឆ្នាំ២០២០ ដោយមានអត្រាការប្រាក់ដុល ១០,៤៦៥១% ក្នុងមួយឆ្នាំ។

នៅថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ២០១៥ បំណុលបន្ទាប់បន្សំរវាងក្រុមហ៊ុន **MARUHAN Investment Asia** ជាមួយធនាគារបានប្រែទៅជាមូលធនបានបង់ចំនួន ៣០ លានដុល្លារអាមេរិក (ស្មើនឹង ៣០០.០០០ ភាគហ៊ុន) (សូមមើលកំណត់សម្គាល់លេខ ១៨) ដែលអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

**Triodos – Doen and Triodos Share Fund**

នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០០៧ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពី Triodos – Doen ចំនួន ១.០០០.០០០ ដុល្លារអាមេរិក និងពី Triodos Fairs Share Fund ចំនួន ១.០០០.០០០ ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះមានរយៈពេល ១០ឆ្នាំ ដែលមានកាលវសាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ និងមានអត្រាការប្រាក់ដុល ១១,៦២៧៩% ក្នុងមួយឆ្នាំ សម្រាប់ ៥ឆ្នាំដំបូង និងមានអត្រាការប្រាក់ដុលស្មើនឹងអត្រា LIBOR ១២ខែ បូក ៦% (ដែលមានអត្រាការប្រាក់ដុលអប្បបរមាតាមអត្រា ១២,២០៩៣%) សម្រាប់រយៈពេលនៅសល់ចាប់ពី ថ្ងៃទី១ ខែមករា ឆ្នាំ២០១៣។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពី Triodos – Doen ចំនួន ៥០០.០០០ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះមានអត្រាការប្រាក់ ១១,០៤៦៦% ក្នុងមួយឆ្នាំ ដែលមានកាលវសាននៅថ្ងៃទី១ ខែមករា ឆ្នាំ២០១៨។ បំណុលបន្ទាប់បន្សំពី Triodos – Doen ចំនួន ៩០០.០០០ ដុល្លារអាមេរិក និង ២៨៦.៧៨៣ ដុល្លារអាមេរិក ត្រូវបានប្តូរទៅជាមូលធនក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ និងនៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១ រៀងគ្នាដែលត្រូវបានអនុម័តដោយធនាគារជាតិនៃកម្ពុជានៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១។ ក្រោយមកភាគហ៊ុនរបស់ Triodos – Doen ត្រូវបានលក់ និងផ្ទេរមកម៉ារ៉ូហាន់ ធនាគារជប៉ុន ក្នុងឆ្នាំ២០១២។

**DWM Funds S.C.A**

នៅថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០៨ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពីក្រុមហ៊ុន DWM ចំនួន ១.០០០.០០០ ដុល្លារអាមេរិក។ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានដកចំនួន ៤០០.០០០ ដុល្លារអាមេរិក នៅក្នុងឆ្នាំ ២០០៩ និងដកបន្ថែមចំនួន ៦០០.០០០ ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១០។ បំណុលបន្ទាប់បន្សំនេះមានរយៈពេល ៨ឆ្នាំ ដែលមានកាលវសាននៅថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៦ និងមានអត្រាការប្រាក់ដុល ១២,៧៩០៧% ក្នុងមួយឆ្នាំ។

នៅថ្ងៃទី៦ ខែមករា ឆ្នាំ២០១១ ធនាគារជាតិនៃកម្ពុជាបានអនុម័តបំណុលបន្ទាប់បន្សំមួយទៀតរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធពីក្រុមហ៊ុន DWM ចំនួន ១.០០០.០០០ ដុល្លារអាមេរិក។ បំណុលបន្ទាប់បន្សំនេះមានអត្រាការប្រាក់ដុល ១១,០៥% ក្នុងមួយឆ្នាំ និងកាលវសានក្នុងរយៈពេល ៧ឆ្នាំ បន្ទាប់ពីថ្ងៃដកប្រាក់។ បំណុលបន្ទាប់បន្សំនេះត្រូវបានប្តូរទៅជាមូលធននៃក្រុមហ៊ុនបុត្រសម្ព័ន្ធ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១១ ដែលអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ២០១១។ ក្រោយមក ភាគហ៊ុនរបស់ក្រុមហ៊ុន DWM ត្រូវបានលក់ និងផ្ទេរមកធនាគារក្នុងឆ្នាំ ២០១២។

## ១៦. ភាគពុកិច្ចមូលនិធិសោធននិវត្តន៍

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| សមតុល្យដើមការិយបរិច្ឆេទ | ៤.០៨២.៦៦៦ | ១៦.៦៣៦.៨៦៤ | ២.៨៩៩.៩៥២ | ១១.៥៨៣.៣១១ | ៣៣៣.៤០៨ | ១.៣៥៨.៦៣៨ | ២៧១.៧៤៥ | ១.០៨៥.៦២១ |
| វិភាគទានក្នុងការិយបរិច្ឆេទ | ១.៦៨០.៩៥៩ | ៦.៨០៧.៨៨៤ | ១.២៥០.២២២ | ៥.០៩៤.៦៥៥ | ១៤៦.១៩៨ | ៥៩១.៨៩៩ | ១២៥.០១៣ | ៥០៩.៤២៨ |
| ការប្រាក់ | ២៦១.៣៦៩ | ១.០៥៨.៥៤៤ | ១៨០.៩១១ | ៧៣៧.២១២ | ២.៧៦៨ | ១១.២១០ | ១.៩៦០ | ៧.៩៨៧ |
| ការទូទាត់ដល់និយោជិត | (២០៨.២៦១) | (៨៤៣.៤៥៧) | (២៤៧.៩១៩) | (១.០១០.២៧០) | (៣៦.៧៧១) | (១៤៨.៩២៣) | (៦៥.៣១០) | (២៦៦.១៣៨) |
| លម្អៀងអត្រាប្តូរប្រាក់ | - | (១០២.០៦៦) | - | ២៣១.៩៥៦ | - | (៨.៣៣៤) | - | ២១.៧៤០ |
| **សមតុល្យចុងការិយបរិច្ឆេទ** | **៥.៨១៦.៧៣៣** | **២៣.៥៥៧.៧៦៩** | **៤.០៨២.៦៦៦** | **១៦.៦៣៦.៨៦៤** | **៤៤៥.៥៥៣** | **១.៨០៤.៤៩០** | **៣៣៣.៤០៨** | **១.៣៥៨.៦៣៨** |

## ១៧. ទ្រព្យអកម្មផ្សេងៗ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ចំណាយការប្រាក់បង្គរ | ៦.២០១.៩៥៩ | ២៥.១១៧.៨៣៤ | ៣.៩១២.០២៥ | ១៥.៩៤១.៥០២ | ៧០៩.៧៨៧ | ២.៨៧៤.៦៣៧ | ១.០៨៦.៨០៨ | ៤.៤២៨.៧៤៣ |
| បៀវត្ស និងលាភការដែលត្រូវបង់ | ១.២៩៩.៦៥៣ | ៥.២៦៣.៥៩៥ | ៩៥៧.៣៥៧ | ៣.៩០១.២៣០ | ២៤៩.១៥០ | ១.០០៩.០៥៨ | ២០៣.៥៨១ | ៨២៩.៥៩៣ |
| ពន្ធកាត់ទុក និងពន្ធផ្សេងៗដែលត្រូវបង់ | ៤៥៣.១៣៣ | ១.៨៣៥.១៩៩ | ៣៧១.៥៤៤ | ១.៥១៤.០៤២ | ៤៧.៤៩១ | ១៩២.៣៣៨ | ៥០.៣៦៧ | ២០៥.២៤៦ |
| បំណុលជំពាក់ទៅសម្ព័ន្ធញាតិ | ៤.៦៨០ | ៣៩២.៩៥៤ | ៦៩.៩១៣ | ២៨៤.៨៩៥ | ៨៤.៦៨០ | ៣៩២.៩៥៤ | ៦៩.៩១៣ | ២៨៤.៨៩៥ |
| សោហ៊ុយវិជ្ជាជីវៈបង្គរ | ២៩.៧០០ | ១២០.២៨៥ | ៨៤.០២៣ | ៣៤២.៣៩៤ | ២៩.៧០០ | ១២០.២៨៥ | ៣១.២៦២ | ១២៧.៣៩៣ |
| ទ្រព្យអកម្មផ្សេងៗ | ៦៣៥.៥៨៨ | ២.៥៧៤.១៣១ | ៨៤៨.៦៥៣ | ១.៩៧៤.៩៦០ | ១៤៩.៣៥៩ | ៦០៤.៩០៤ | ២២៩.៣២៣ | ៩៣៤.៤៨៩ |
| | **៨.៧០៤.៧១៣** | **៣៥.២៥៤.០៨៨** | **៥.៨៧៩.៥១៥** | **២៣.៩៥៩.០២៣** | **១.២៧០.១៦៧** | **៥.១៤៤.១៧៦** | **១.៦៧១.២៥៤** | **៦.៨១០.៣៥៩** |

ទ្រព្យអកម្មផ្សេងៗ រួមមានចំណូលមិនទាន់បំពេញសេវា គណនីឥណទេយ្យ និងចំណាយបង្គរផ្សេងៗ។

## ១៨. ដើមទុន

ព័ត៌មានលម្អិតនៃដើមទុនរបស់ធនាគារមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| ត្រូវបានអនុម័តចុះបញ្ជីបោះផ្សាយនិងទូទាត់ទាំងស្រុង៖ | | | | |
| សមតុល្យដើមការិយបរិច្ឆេទ | ៧៤.០០០.០០០ | ២៩៩.៧០០.០០០ | ៧៤.០០០.០០០ | ៣០១.៥៥០.០០០ |
| បំលែងបំណុលបន្ទាប់បន្សំ | ៣០.០០០.០០០ | ១២១.៥០០.០០០ | - | - |
| សមតុល្យចុងការិយបរិច្ឆេទ | **១០៤.០០០.០០០** | **៤២១.២០០.០០០** | **៧៤.០០០.០០០** | **៣០១.៥៥០.០០០** |

| | ចំនួនភាគហ៊ុន<br>(១០០ដុល្លារអាមេរិកក្នុងមួយភាគហ៊ុន) | | ចំនួនទឹកប្រាក់ | |
|---|---|---|---|---|
| | ២០១៥ | ២០១៤ | ២០១៥ | ២០១៤ |
| | | ដុល្លារអាមេរិក | | ដុល្លារអាមេរិក |
| បានបោះផ្សាយ និងទូទាត់ដោយ៖ | | | | |
| MARUHAN Investment Asia Pte. ("MIA") | ១.០៤០.០០០ | - | ១០៤.០០០.០០០ | - |
| MARUHAN Corporation ("MC") | - | ៣៦២.៦០០ | - | ៣៦.២៦០.០០០ |
| SONAM Co. Ltd. ("SC") | - | ៣៧៧.៤០០ | - | ៣៧.៧៤០.០០០ |
| | **១.០៤០.០០០** | **៧៤០.០០០** | **១០៤.០០០.០០០** | **៧៤.០០០.០០០** |

នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៥ ក្រុមប្រឹក្សាភិបាលរបស់ធនាគារបានព្រមព្រៀងគ្នាដើម្បីបំលែងបំណុលបន្ទាប់បន្សំជាមួយនឹង MIA ចំនួន ៣០ លានដុល្លារអាមេរិក ជាសមមូលនៃដើមទុន (ស្មើនឹង ៣០០.០០០ ភាគហ៊ុន ) ដែលបានអនុម័តដោយធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។ នាកាលបរិច្ឆេទដដែល ធនាគារជាតិនៃកម្ពុជាបានអនុម័តការផ្ទេរភាគហ៊ុនទាំងអស់ពី MC និង SC ទៅឱ្យ MIA ផងដែរ។

ប្រាក់តម្កល់ធានាលើដើមទុនចំនួន ១០% នៃដើមទុនចុះបញ្ជី ត្រូវបានរក្សាទុកនៅធនាគារជាតិនៃកម្ពុជាដូចបានបង្ហាញនៅក្នុងកំណត់សម្គាល់លេខ៩។

## ១៩. ចំណូលការប្រាក់ និងចំណូលប្រហាក់ប្រហែល

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ |
| កម្ចី | ៨៨.៣៦២.០៣០ | ៣៥៧.៨៦៦.២២២ | ៥៥.៦៥៦.៧៨៩ | ២២៦.៨០១.៤១៥ | ៧.០៧៧.៤៣៥ | ២៨.៦៦៣.៦១២ | ៦.០៨៤.៧៦៧ | ២៤.៧៩៥.៤២៦ |
| ប្រាក់បញ្ញើ | ៦៤៩.៦០០ | ២.៦៣០.៨៨០ | ២៧៦.៨១៤ | ១.១២៨.០១៧ | ៦៤២.២១០ | ២.៦០០.៩៥០ | ២៦៧.៣៦៧ | ១.០៨៩.៥២០ |
| | **៨៩.០១១.៦៣០** | **៣៦០.៤៩៧.១០២** | **៥៥.៩៣៣.៦០៣** | **២២៧.៩២៩.៤៣២** | **៧.៧១៩.៦៤៥** | **៣១.២៦៤.៥៦២** | **៦.៣៥២.១៣៤** | **២៥.៨៨៤.៩៤៦** |

## ២០. ចំណាយការប្រាក់ និងចំណាយប្រហាក់ប្រហែល

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ |
| ប្រាក់បញ្ញើពីអតិថិជន | ១៨.២៩២.៩១២ | ៧៤.០៨៦.២៩៤ | ១០.៩៣៩.៣៥៦ | ៤៤.៥៧៧.៨៧៦ | ២.៩០៩.៤៦៩ | ១១.៧៨៣.៣៤៩ | ២.៦៥៦.៨៦៣ | ១០.៨២៦.៧១៧ |
| ប្រាក់កម្ចី | ១០.៣៣៨.៦៥៨ | ៤១.៨៧១.៥៦៤ | ៦.៥៣៩.២៦៣ | ២៦.៦៤៧.៤៨៦ | - | - | - | - |
| បំណុលបន្ទាប់បន្សំ | ៤.២៥៧.០៧៦ | ១៧.២៤១.១៥៨ | ១.៩៣៣.១៥៨ | ៧.៨៧៧.៦១៩ | ៦០០.០០០ | ២.៤៣០.០០០ | ៦០០.០០០ | ២.៤៤៥.០០០ |
| | **៣២.៨៨៨.៦៤៦** | **១៣៣.១៩៩.០១៦** | **១៩.៤១១.៧៧៧** | **៧៩.១០២.៩៨១** | **៣.៥០៩.៤៦៩** | **១៤.២១៣.៣៤៩** | **៣.២៥៦.៨៦៣** | **១៣.២៧១.៧១៧** |

## ២១. ថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ |
| **ចំណូលថ្លៃឈ្នួល និងកម្រៃជើងសារបានពី៖** | | | | | | | | |
| កម្រៃឥណទានពាណិជ្ជកម្ម | ២.១៧៣.២៨៩ | ៨.៨០១.៨២០ | ១.៤៤៨.៩០៥ | ៥.៩០៤.២៨៨ | ៦០៤.២៦៤ | ២.៤៤៧.២៦៩ | ៤៥៣.២៦៥ | ១.៨៤៧.០៥៥ |
| កម្រៃពីទូរសារ និងទូរពុម្ព | ៩៨.៣៩៧ | ៣៩៨.៥០៨ | ៧២.៩៩៩ | ២៩៧.២៦៧ | ៣.៣៧៧ | ១៣.៦៧៧ | ៦.២៣៨ | ២៥.៤២០ |
| កម្រៃកិច្ចសន្យាឥណទាន | ៥០.៥៣០ | ២០៤.៦៤៧ | ២៤.៦១៤ | ១០០.៣០២ | ៥០.៥៣០ | ២០៤.៦៤៧ | ២៤.៦១៤ | ១០០.៣០២ |
| សេវាទូទាត់ | ៣៦.០៧៧ | ១៤៦.១១២ | ៩.៥៧៨ | ៣៩.០៣០ | ៣៦.០៧៧ | ១៤៦.១១២ | ៩.៥៧៨ | ៣៩.០៣០ |
| ថ្លៃឈ្នួល និងកម្រៃជើងសារផ្សេងៗ | ១០៣.៦៩៩ | ៤១៩.៩៨១ | ៥៣.៤៣១ | ២១៧.៧៣២ | ៩៤.១៩១ | ៣៨១.៤៧៣ | ៤៧.២២៧ | ១៩២.៤៥០ |
| | **២.៤៦១.៩៩២** | **៩.៩៦៧.០៦៤** | **១.៦០៩.៤៧៧** | **៦.៥៥៨.៦១៩** | **៧៨៨.៤៣៩** | **៣.១៩៣.១៧៨** | **៥៤០.៩២២** | **២.២០៤.២៥៧** |
| **ចំណាយថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធលើ៖** | | | | | | | | |
| ប្រាក់កម្ចី | (៦២៩.៧៤៧) | (២.៥៥០.៤៧៥) | (៣៩១.២៥៩) | (១.៣៩០.៦៣០) | - | - | - | - |
| សេវាទូទាត់ | (៣០.១៨០) | (១២២.២២៩) | (៦.២០៨) | (២៥.២៩៨) | (៣០.១៨០) | (១២២.២២៩) | (៦.២០៨) | (២៥.២៩៨) |
| **ថ្លៃឈ្នួល និងកម្រៃជើងសារសុទ្ធ** | **១.៨០២.០៦៥** | **៧.២៩៤.៣៦០** | **១.២១២.០១០** | **៥.១៤២.៦៩១** | **៧៥៨.២៥៩** | **៣.០៧០.៩៤៩** | **៥៣៤.៧១៤** | **២.១៧៨.៩៥៩** |

## ២២. ចំណូលប្រតិបត្តិការផ្សេងៗ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ | ដុល្លារអាមេរិក | ពាន់រៀល កំណត់ |
| ចំណេញ(ខាត) ការប្តូររូបិយវត្ថុបរទេស | ១៦៣.៩៥៦ | ៦៦០.៧៨២ | (៨.៤២៧) | (៣៤.៣៤០) | ១២៩.៤១៨ | ៥២៤.១៩៣ | (៨.៤២៧) | (៣៤.៣៣៩) |
| ឥណទានដែលប្រមូលបាន | ១២៩.៦៨៨ | ៥២៥.២៣៦ | ១០១.៩៣២ | ៤១៥.៣៧៣ | - | - | - | - |
| ចំណូលភាគលាភ (កំណត់សម្គាល់ ២៥) | ២៨.៣៦៩ | ១១៤.៨៩៤ | - | - | ២.៥២៧.២២៤ | ១០.២៣៥.២៥៧ | ១.៤៤៨.៣៦១ | ៥.៨០២.១៩៣ |
| ចំណូលផ្សេងៗ | (២៥.២២៩) | (១០២.១៧៧) | (៦.០៨៤) | (២៤.៧៩២) | (២៥.៧២២) | (១០៤.១៧៤) | (៧.៣៦៧) | (៣០.១៤៣) |
| | **២៩២.៧៨៤** | **១.១៩៨.៧៣៥** | **៨៧.៤២១** | **៣៥៦.២៤១** | **២.៦៣០.៩២០** | **១០.៦៥៥.២៧៦** | **១.៤៣២.៥៦៧** | **៥.៧៣៧.៧១១** |

## ២៣. ចំណាយរដ្ឋបាល និងចំណាយទូទៅ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| | | កំណត់សម្គាល់ ២.១ | | កំណត់សម្គាល់ ២.១ | | កំណត់សម្គាល់ ២.១ | | កំណត់សម្គាល់ ២.១ |
| បៀវត្សបុគ្គលិក និងសោហ៊ុយផ្សេងៗ | ១៩.៣៨១.៦៤៧ | ៧៨.៣៣៣.៦៧០ | ១៤.២៨២.៩៣២ | ៥៨.២០២.៩៤៨ | ១.៩១៧.០៦០ | ៧.៧៦៤.០៩៣ | ១.៨៨៤.៦៥៨ | ៧.៦៧៩.៩៨១ |
| រំលស់ | ២.៨៤៥.២៩៩ | ១១.៥២៣.៩៦១ | ២.៥១២.០៣៣ | ១០.២៣៦.៥៣៤ | ២៦៧.៣៨០ | ១.០៨២.៨៨៩ | ៥៩០.៧១៥ | ២.៤០៧.១៦៤ |
| សោហ៊ុយជួល | ២.៦៣០.០១៤ | ១០.៦៥១.៥៥៧ | ២.០៥៤.១៩១ | ៨.៣៧០.៦២៥ | ២៤០.៦៤៤ | ៩៧៤.៦០៨ | ១៦២.០០០ | ៦៦០.១៥០ |
| បោះពុម្ព ទីផ្សារ និងផ្សព្វផ្សាយ | ១.៥២៧.២៩២ | ៦.១៨៥.៥៣៣ | ១.១០៣.២៣០ | ៤.៤៩៥.៦៦២ | ១២៧.៣០៥ | ៥១៥.៥៨៥ | ១៥៧.៣២០ | ៦៤១.០៧៩ |
| ចំណាយយានយន្ត | ៥៥៥.៥៨២ | ២.២៥០.១០៧ | ៥៧៥.៧៦៦ | ២.៣៤៦.២៤៦ | ២៩.២៦៨ | ១១៨.៥៣៥ | ៣៣.០៥៥ | ១៣៤.៦៩៩ |
| តំហែទាំ និងជួលអចលនទ្រព្យ | ៦៤៣.៧៨៤ | ២.៦០៧.៣២៥ | ៥៥០.៦៨៣ | ២.២៤៤.០៣៣ | ២៣៩.៧៤៧ | ៩៧១.១៣៧ | ២៧០.៤៥០ | ១.១០២.០៨៤ |
| ចំណាយទូរគមនាគមន៍ | ៥៩៧.២៥៨ | ២.៤១៨.៨៩៥ | ៥៤៣.៨៥៨ | ២.២១៦.២២១ | ១២៨.៣៧៧ | ៥១៩.៩២៧ | ១៥០.៥៧៤ | ៦១៣.៥៨៩ |
| ចំណាយទឹកភ្លើង | ៦៤៥.២១៧ | ២.៦១៣.១២៩ | ៥៣១.៧២៩ | ២.១៦៦.៧៩៦ | ៦៨.១៩២ | ២៧៥.៩៧៥ | ៧០.៨៧៦ | ២៨៨.៨២០ |
| សោហ៊ុយសន្តិសុខ | ៣៧៩.៩៦៣ | ១.៥៣៨.៨៥០ | ២៩១.៤៧៦ | ១.១៨៧.៧៦៥ | ៣៣.៤១៧ | ១៣៥.៣៣៩ | ៣០.៧២១ | ១២៥.១៨៨ |
| សោហ៊ុយវិជ្ជាជីវៈ និងសោហ៊ុយផ្សេងៗ | ៣៨៤.២៤៨ | ១.៥៥៦.២០៤ | ១៧៥.០២៥ | ៧១៣.២២៧ | ១៨៧.០៤៤ | ៧៥៧.៥២៨ | ៩០.៤៥១ | ៣៦៨.៥៨៨ |
| សម្ភារៈផ្គត់ផ្គង់ប្រតិបត្តិការធនាគារ | ៥៨.៥០៨ | ២៣៦.៩៥៧ | ៥០.៩៦៣ | ២០៧.៦៧៤ | ៥៨.៥០៨ | ២៣៦.៩៥៧ | ៥០.៩៦៣ | ២០៧.៦៧៤ |
| សោហ៊ុយធ្វើដំណើរ | ៤១.៦៧០ | ១៦៨.៧៦៤ | ៤៩.៨០៧ | ២០២.៩៦៤ | ៤១.៦៧០ | ១៦៨.៧៦៤ | ៤៩.៨០៧ | ២០២.៩៦៤ |
| ចំណាយផ្សេងៗ | ២.៩១៦.១៩០ | ១១.៨១០.៥៧០ | ១.៨៥៦.០៦៨ | ៧.៥៦៣.៤៧៧ | ៤៥៦.៨២២ | ១.៨៥០.១៣០ | ៣០៨.១៩៨ | ១.២៥៥.៩០៦ |
| | **៣២.៥៦៦.៦៧២** | **១៣១.៨៩៥.០២២** | **២៤.៥៧៧.៧១១** | **១០០.១៥៤.១៧២** | **៣.៧៩៥.៤២៤** | **១៥.៣៧១.៤៦៧** | **៣.៨៤៩.៧៨៨** | **១៥.៦៨៧.៨៨៦** |

ចំណាយផ្សេងៗរួមមានថ្លៃក្រុមប្រឹក្សាភិបាល ការបរិច្ចាគ សមាជិកភាព ធានារ៉ាប់រង ការផ្គត់ផ្គង់ ថ្លៃអាជ្ញាប័ណ្ណ និងចំនាយមិនមែនទ្រព្យសកម្ម។

## ២៤. សាច់ប្រាក់សុទ្ធ (ប្រើក្នុង) បានពីសកម្មភាពប្រតិបត្តិការ

| | ក្រុមហ៊ុនរួម | | | | ធនាគារ | | | |
|---|---|---|---|---|---|---|---|---|
| | ២០១៥ | | ២០១៤ | | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| ចំណេញមុនបង់ពន្ធ | ២៣.២៦៨.៨៨៩ | ៩៤.២៣៩.០០២ | ១២.២៧៥.៤៧៣ | ៥០.០២២.៥៥៤ | ២.១៦១.៧៥៨ | ៨.៧៥៥.១២១ | ៨១០.៦១៤ | ៣.៣០៣.២៥២ |
| និយ័តកម្មលើះ | | | | | | | | |
| រំលស់ | ២.៨៤៥.២៩៩ | ១១.៥២៣.៤៦១ | ២.៥១២.០៣៣ | ១០.២៣៦.៥៣៤ | ២៦៧.៣៨០ | ១.០៨២.៨៨៩ | ៥៩០.៧១៥ | ២.៤០៧.១៦៤ |
| ខាត ពីការលក់ទ្រព្យ និងបរិក្ខារ | ២៥.៧២២ | ១០៤.១៧៤ | ៦.០៨៤ | ២៤.៧៩២ | ២៥.៧២២ | ១០៤.១៧៤ | ៧.៣៩៧ | ៣០.១៩៣ |
| ការលុបចោលទ្រព្យ និងបរិក្ខារ | ២៩.១៧១ | ១១៨.១៤៣ | ១៩.២៩០ | ៧៨.៦០៧ | - | - | - | - |
| ពន្ធបង់ក្នុងការិយបរិច្ឆេទ | (៣.៣២៧.៦១៥) | (១៣.៤៧៦.៨៤១) | (២.៥១៥.៦២៥) | (១០.២៥១.១៧២) | (៨៥.២៨៤) | (៣៤៥.៤០០) | (៧៩៣.៣១២) | (៣.២៣២.៧៤៦) |
| **សាច់ប្រាក់ទទួលបានពីសកម្មភាពប្រតិបត្តិការ មុនការប្រែប្រួលទ្រព្យសកម្ម និងទ្រព្យអកម្ម ប្រតិបត្តិការសុទ្ធ** | **២២.៨៤១.៤៦៦** | **៩២.៥០៧.៩៣៩** | **១២.២៩៧.២៥៥** | **៥០.១១១.៣១៥** | **២.៣៦៩.៥៧៦** | **៩.៥៩៦.៧៨៤** | **៦១៥.៤១៤** | **២.៥០៧.៨១៣** |
| ការថយចុះ (កើនឡើង) នៃទ្រព្យសកម្ម ប្រតិបត្តិការះ | | | | | | | | |
| ឥណទាន និងបុរេប្រទានចំពោះ អតិថិជន | (១៧៥.៩៨៧.៧៥៥) | (៧១២.៧៥០.៤០៨) | (១១២.៤៧៣.៧៨៨) | (៤៥៨.៣៣០.៦៨៦) | (១៥.៧៩៣.២៨៥) | (៦៣.៩៦២.៨០៤) | ១២.៨០៣.២៣១ | ៥២.១៧៣.១៦៦ |
| ប្រាក់តម្កល់ធានាលើដើមទុននិងប្រាក់ បម្រុងកាតព្វកិច្ចនៅធនាគារជាតិនៃកម្ពុជា | (៧.៩៦៨.៣៥២) | (៣២.២៧១.៨២៦) | (៩.៤៥៧.៥៦២) | (៣៨.៥៣៩.៥៦៥) | (១៥២) | (៦១៦) | (១.៤៩៩.៥០៩) | (៦.១១០.៤៩៩) |
| ទ្រព្យសកម្មផ្សេងទៀត | (៣.៧៨៨.៣១៣) | (១៥.៣៤២.៦៦៨) | (៣.២៣១.៤០៦) | (១៣.១៦៧.៩៧៩) | (៥២.៦៨៦) | (២១៣.៣៧៨) | (៤៧៤.៣៦៣) | (១.៩៣៣.០២៩) |
| ការកើនឡើង (ថយចុះ) នៃទ្រព្យអកម្ម ប្រតិបត្តិការះ | | | | | | | | |
| ប្រាក់បញ្ញើរបស់ធនាគារផ្សេងៗ | ៦.៩៧៦.៦៥៣ | ២៨.២៥៥.៤៤៥ | ៩.៥៣៨.៦០៣ | ៣៨.៨៦៩.៨០៧ | ១.០៦៥.៤០៩ | ៤.៣១៤.៩០៦ | (២២.១៥៤) | (៩០.២៧៨) |
| ប្រាក់បញ្ញើរបស់អតិថិជន | ៧២.១៦១.៧៩៤ | ២៩២.២៥៥.២៦៦ | ៩៦.៦៩៨.៤៨១ | ៣៩៤.០៤៦.៣១០ | (១៤.៤៣៧.៧១៨) | (៥៨.៤៧២.៧៥៨) | ២០.៤៥៧.៤៦១ | ៨៣.៣៦៤.១៥៤ |
| កាតព្វកិច្ចមូលនិធិសន្និធិថ្វិ៍យ | ១.៧៣៤.០៦៧ | ៧.០២២.៩៧១ | ១.១៨៣.២១៤ | ៤.៨២១.៥៩៧ | ១១២.១៩៥ | ៤៥៤.៤៨៧ | ៦១.៦៦៣ | ២៥១.២៧៧ |
| ទ្រព្យអកម្មផ្សេងៗ | ២.៨២៣.៩៤៥ | ១១.៤៣៦.៩៩៣ | ២.០០៣.១៩៥ | ៨.១៦២.៨១៦ | (៤០២.៣៣៦) | (១.៦២៩.៤៦១) | ៥៥៣.៩៩៥ | ២.២៥៧.៥៣០ |
| **សាច់ប្រាក់សុទ្ធ(ប្រើក្នុង) បានពីសកម្មភាព ប្រតិបត្តិការ** | **(៨១.២០៦.៤៩១)** | **(៣២៨.៨៨៦.២៨៨)** | **(៣.៤៤២.០៥៨)** | **(១៤.០២៦.៣៨៥)** | **(២៧.១៣៩.០៤៧)** | **(១០៩.៩១៣.១៤០)** | **៣២.៤៩៥.៧៣៨** | **១៣២.៤២០.១៣៤** |

## ២៥. ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

នាថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១២ ធនាគារបានទិញក្រុមហ៊ុនបុត្រសម្ព័ន្ធចំនួន ៣៩,២៩ លានដុល្លារអាមេរិក និងមានមូលនិធិពាណិជ្ជកម្មនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមដូចខាងក្រោម៖

| | |
|---|---|
| តម្លៃទិញ | ៣៩.២៨៥.០៨៣ |
| តម្លៃទីផ្សារនៃទ្រព្យសកម្មសុទ្ធដែលបានទិញ | ២១.៩០៥.០៥៣ |
| **មូលនិធិពាណិជ្ជកម្ម** | **១៧.៣៨០.០៣០** |

នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤ និងថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០១៤ ធនាគារជាតិនៃកម្ពុជា និងក្រសួងពាណិជ្ជកម្មបានអនុម័តលើដើមទុនបន្ថែមរបស់ធនាគារចំនួន ៨,៦៥ លានដុល្លារអាមេរិក។

ព័ត៌មានហិរញ្ញវត្ថុរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងសម្រាប់ការិយបរិច្ឆេទបញ្ចប់ មានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| ទ្រព្យសកម្មសរុប | ៥៣៩.០៨៨.០១១ | ២.១៨៣.៣០៦.៤៤៤ | ៣៦២.៥៣៥.៩៥៧ | ១.៤៧៧.៣៣៤.០២៥ |
| ទ្រព្យអកម្មសរុប | ៤៧៨.២៦៨.១២៧ | ១.៩៣៦.៩៨៥.៩១៤ | ៣១៨.០១៤.២៨៥ | ១.២៩៥.៩០៨.២១១ |
| ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | ១៨.៩៤០.៦៦១ | ៧៦.៧០៩.៦៧៧ | ១០.៥៦៩.៧៩៧ | ៤៣.០៧១.៩២២ |

នៅឆ្នាំ ២០១៥ ក្រុមហ៊ុនបុត្រសម្ព័ន្ធបានប្រកាសភាគលាភទៅធនាគារចំនួន ២,៥១ លានដុល្លារអាមេរិក(ឆ្នាំ២០១៤មាន ១,៤៥ លានដុល្លារអាមេរិក )។

## ២៦. កិច្ចសន្យា និងយថាភាព

(ក) កិច្ចសន្យាកម្ចី និងកិច្ចសន្យាផ្សេងៗ

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| ផ្នែកមិនទាន់ប្រើប្រាស់នៃ | | | | |
| ឥណទានវិបារូបន៍ | ១១.៨៨១.៣៦៣ | ៤៨.១១៩.៥២០ | ៥.៤១៥.៥៧៥ | ២២.០៦៨.៤៦៨ |
| លិខិតធានា | ៣៧.០០០ | ១៤៩.៨៥០ | - | - |
| | **១១.៩១៨.៣៦៣** | **៤៨.២៦៩.៣៧០** | **៥.៤១៥.៥៧៥** | **២២.០៦៨.៤៦៨** |

(ខ) កិច្ចសន្យាជួល

ព័ត៌មានលម្អិតអំពីការទូទាត់លើការជួលអប្បបរមាអនាគត ក្រោមកិច្ចសន្យាជួលដែលមិនអាចកែប្រែបាន

សម្រាប់ការជួលទីស្នាក់ការកណ្តាលរបស់ក្រុមហ៊ុនរួម និងធនាគារមានដូចខាងក្រោម៖

| | ក្រុមហ៊ុនរួម | | | |
|---|---|---|---|---|
| | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល<br>កំណត់<br>សម្គាល់ ២.១ |
| តិចជាង ១ ឆ្នាំ | ២.៤១៧.៦៩១ | ៩.៧៩១.៦៤៩ | ២.០៦៥.៧៥១ | ៨.៤១៧.៩៣៥ |
| ២ ទៅ ៥ឆ្នាំ | ៧.៥៣៥.៧៤៩ | ៣០.៥១៩.៧៨៣ | ៥.៧៨៤.៥២៣ | ២៣.៥៧១.៩៣១ |
| លើសពី៥ឆ្នាំ | ៣.៩២០.៦៨៦ | ១៥.៨៧៨.៧៧៨ | ២.២៧៨.៦០៥ | ៩.២៨៥.៣១៥ |
| | **១៣.៨៧៤.១២៦** | **៥៦.១៩០.២១០** | **១០.១២៨.៨៧៩** | **៤១.២៧៥.១៨១** |

| | ធនាគារ | | | |
|---|---|---|---|---|
| | ២០១៥ | | ២០១៤ | |
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| តិចជាង ១ ឆ្នាំ | ៤៧.៤០០ | ១៩១.៩៧០ | ៩៤.៥០០ | ៣៨៥.០៨៨ |
| ២ ទៅ ៥ឆ្នាំ | ៤៣.៤៥០ | ១៧៥.៩៧៣ | - | - |
| | **៩០.៨៥០** | **៣៦៧.៩៤៣** | **៩៤.៥០០** | **៣៨៥.០៨៨** |

(គ) យថាហេតុពន្ធដារ

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈថ្មី និងត្រូវបានកំណត់ដោយពន្ធច្រើនប្រភេទ និងមានការកែប្រែច្បាប់ជាញឹកញាប់ដែលជាទូទៅមានភាពមិនច្បាស់លាស់មានភាពផ្ទុយគ្នា និង ផ្សេងៗគ្នា តាមការបកស្រាយ។ ជារឿយៗ បំណកស្រាយខុសៗគ្នាតែងកើតមានឡើងនៅក្នុងចំណោមអាជ្ញាធរ និងយុត្តាធិការពន្ធដារ។ ពន្ធអាករទាំងឡាយតម្រូវឲ្យមានការត្រួតពិនិត្យ និងតាមដានពីសំណាក់អាជ្ញាធរពន្ធដារមួយចំនួនដែលមានកំណត់ក្នុងច្បាប់ដើម្បីដាក់ពិន័យធ្ងន់ធ្ងរ និងដាក់បន្ទុកការប្រាក់។ ហេតុផលទាំងនេះអាចបង្កឲ្យមានហានិភ័យពន្ធដារជាសារវន្តនៅក្នុងប្រទេសកម្ពុជាជាជាងនៅបណ្តាប្រទេសដទៃ។ គណៈគ្រប់គ្រងជឿជាក់ថាក្រុមហ៊ុនបានបង់ពន្ធគ្រប់គ្រាន់ដោយផ្អែកតាមបំណកស្រាយច្បាប់ពន្ធដារ របស់ក្រុមហ៊ុន។ ទោះយ៉ាងនេះក្តីអាជ្ញាធរពាក់ព័ន្ធអាចនឹងមានបំណកស្រាយផ្សេងពីនេះដែលអាចជះឥទ្ធិពលដល់ក្រុមហ៊ុននិងបុត្រសម្ព័ន្ធ។

(ឃ) ជម្រើសនៃការទិញម្ចាស់ភាគហ៊ុនអប្បភាគ

ធនាគារបានផ្តល់អោយក្រុមហ៊ុន Cambodia Community Building ("CCB") ដែលជាភាគទុនិករបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនូវជម្រើសក្នុងការលក់ភាគហ៊ុននៅសល់ក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធមកអោយធនាគារ។ ជម្រើសលក់អាចនឹងត្រូវបានអនុវត្តដោយ CCB គ្រប់ពេលវេលាក្នុងអំឡុងពេលជម្រើសលក់ដែលគិតចាប់ពីថ្ងៃទីមួយនៃថ្ងៃជម្រើសលក់ដល់ថ្ងៃចុងក្រោយនៃរយៈពេលកំណត់បីឆ្នាំ។ ក្នុងករណីដែCCមិនអនុវត្តជម្រើសលក់របស់ខ្លួនហើយជម្រើសលក់នោះត្រូវបានផុតកំណត់ធនាគារមានសិទ្ធិ និងជម្រើសគ្រប់ពេលក្នុងការទិញភាគហ៊ុននៅសល់បន្ទាប់ពីអំឡុងពេលជម្រើសលក់ផុតកំណត់។

តម្លៃអនុវត្តនៃជម្រើសលក់និងជម្រើសទិញនឹងត្រូវគណនាតាមចំនួន ២,២ដងនៃតម្លៃចុះបញ្ជីនៃភាគហ៊ុនសរុប (ផ្អែកលើតម្លៃចុះបញ្ជីដែលត្រូវបានធ្វើសវនកម្មនៅឆ្នាំហិរញ្ញវត្ថុចុងក្រោយមុនឆ្នាំដែលជម្រើសលក់ឬទិញត្រូវបានអនុវត្ត)។ ប្រសិនបើ CCB អនុវត្តជម្រើសលក់របស់ខ្លួននៅចន្លោះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ និងថ្ងៃផុតកំណត់នៃជម្រើសលក់ការគណនាតម្លៃហិរញ្ញវត្ថុអនុវត្តត្រូវផ្អែកលើតម្លៃចុះបញ្ជីដែលបានធ្វើសវនកម្មនៅឆ្នាំហិរញ្ញវត្ថុ ២០១៥។

ប្រសិនបើមានការដាក់បញ្ចូលដើមទុនបន្ថែមឬបំណុលបន្ទាប់បន្សំត្រូវបានផ្តល់ដោយធនាគារទៅក្រុមហ៊ុនបុត្រសម្ព័ន្ធនោះការដាក់បញ្ចូលដើមទុនបន្ថែម ឬបំណុលបន្ទាប់បន្សំនឹងត្រូវបានដកចេញក្នុងគោលបំណងនៃការកំណត់តម្លៃអនុវត្ត។

ជម្រើសនេះត្រូវបានអនុវត្តនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ។

## ២៧. ប្រតិបត្តិការ និងសមតុល្យរវាងសម្ព័ន្ធញាតិ

១. ប្រតិបត្តិការសំខាន់ៗ របស់ធនាគារជាមួយសម្ព័ន្ធញាតិមានដូចខាងក្រោម៖

| | ២០១៥ | | ២០១៤ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| បំលែងបំណុលបន្ទាប់បន្សំជាមូលធនដោយក្រុមហ៊ុន MIA | ៣០.០០០.០០០ | ១២១.៥០០.០០០ | - | - |
| ចំណូលការប្រាក់ពីក្រុមហ៊ុនបុត្រសម្ព័ន្ធ | ៨១៨.២៨៦ | ៣.៣១៤.០៥៨ | ៥៧៤.៧១៥ | ២.៣៤១.៩៦៤ |

ប្រតិបត្តិការសំខាន់ៗរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធមានដូចខាងក្រោម៖

| សម្ព័ន្ធញាតិ | ប្រតិបត្តិការ | ២០១៥ | | ២០១៤ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ | ដុល្លារអាមេរិក | ពាន់រៀល កំណត់សម្គាល់ ២.១ |
| ធនាគារ | ភាគលាភដែលបានប្រកាស | ២.៥១២.៩៦៨ | ១០.១៧៧.៥២០ | ១.៤៤៨.៣៩១ | ៥.៩០២.១៩៣ |
| | ប្រាក់កម្ចី | - | - | ៥០០.០០០ | ២.០៣៧.៥០០ |
| | បំណុលបន្ទាប់បន្សំ | - | - | ៤.០០០.០០០ | ១៦.៣០០.០០០ |
| | ការទូទាត់ប្រាក់កម្ចី | ១៩២.១៦០ | ៧៧៨.២៤៨ | ៦៤២.១៦០ | ២.៦១៦.៨០២ |
| | ចំណាយការប្រាក់ | ៨១៧.៧៩៩ | ៣.៣១២.០៨៨ | ៤៩៤.៣៣៧ | ២.០១៤.៤២៣ |
| | ប្រាក់បញ្ញើ | ១.៤១៤.៣៨១ | ៥.៧២៨.២៤៣ | ៥៤៨.៤៦៤ | ២.២៣៤.៩៩១ |
| ក្រុមប្រឹក្សាភិបាល | លាភការ | ៣៥៣.០០០ | ១.៤២៩.៦៥០ | ២៩១.៩៣៦ | ១.១៨៩.៦៣៩ |
| | ថ្លៃឈ្នួល និងចំណាយពាក់ព័ន្ធផ្សេងៗ | ១៣៣.៨៦៣ | ៥៤២.១៩៥ | ៧៧.១៧៦ | ៣១៤.៤៩១ |

២. ទឹកប្រាក់ត្រូវសងនិងត្រូវទទួលពីសម្ព័ន្ធញាតិ មានដូចខាងក្រោម៖

| | | ២០១៥ | | ២០១៤ | |
